ពៀក-ថែម

# អនុពុទ្ធប្បវត្តិ

សម្រាប់សាលាធម្មវិន័យ

ថ្នាក់ទោ

ទីណោយពីលោក ខៀវ ឃុនសារិទ្ធ ដល់ករុណាវិទ្យា
សម្រាប់ដាក់ទុក ក្នុង eLibrary of Cambodia

# ប្រវត្តិព្រះសាវ័កធំទាំងឡាយដែលខ្ញុំបានរួបរួមទុកក្នុង
## សៀវភៅនេះ


| (ពាក្យក្នុងវង់ក្រចកប្រាប់តំណែងឯតទគ្គៈ) គឺ | | ទំព័រ |
|---|---|---|
| ១- | ប្រវត្តិ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ (រត្តញ្ញូ) | ១ |
| ២- | " ព្រះវប្បត្ថេរ | ៤ |
| ៣ | " ព្រះភទ្ទិយត្ថេរ | ៥ |
| ៤- | " ព្រះមហានាមត្ថេរ | ៥ |
| ៥ | " ព្រះអស្សជិត្ថេរ | ៦ |
| ៦- | " ព្រះយសត្ថេរ | ៨ |
| ៧- | " ព្រះវិមលត្ថេរ | ៩ |
| ៨- | " ព្រះសុពាហុត្ថេរ | ១១ |
| ៩ | " ព្រះបុណ្ណជិត្ថេរ | ១១ |
| ១០- | " ព្រះគវម្បតិត្ថេរ | ១១ |
| ១១- | " ព្រះឧរុវេលកស្សបត្ថេរ (មានបរិស័ទបរិវារច្រើន) | ១២ |
| ១២- | " ព្រះនទីកស្សបត្ថេរ | ១២ |
| ១៣- | " ព្រះគយាកស្សបត្ថេរ | ១២ |
| ១៤- | " ព្រះសារីបុត្តត្ថេរ (មានបញ្ញាឯក) | ១៦ |
| ១៥- | " ព្រះមហាមោគ្គល្លានត្ថេរ (មានរិទ្ធីឯក) | ១៩ |
| ១៦- | " ព្រះមហាកស្សបត្ថេរ | ២២ |
| ១៧- | " ព្រះមហាកច្ចាយនត្ថេរ (បែកខាងចែកបំបែកសេចក្ដីដែលទ្រង់សំដែងដោយសង្ខេបឱ្យពិស្ដារ) | ២៤ |

៦០- ប្រវត្តិ ព្រះពាហិយទារុចិយត្ថេរ ( ខិប្បាភិញ្ញា) ---------- ១០៤
៦១- " ព្រះពាកុលត្ថេរ ( មានអាពាធតិច) ---------------- ១០៦
៦២- " ព្រះទព្វមល្លបុត្តត្ថេរ ( រៀបចំក្រាលសេនាសនៈ) ------ ១០៨
៦៣- " ព្រះសុភូតិត្ថេរ ( អរណាវិហារនឹងទក្ខិណេយ្យបុគ្គល) ---- ១០៩
៦៤- " ព្រះកង្ខារេវត្តត្ថេរ ( ត្រេកអរក្នុងឈានសមាបត្តិ) ----- ១១០
៦៥- " ព្រះនាលកត្ថេរ ( បំពេញមោនេយ្យបដិបត្តិ) --------- ១១១
៦៦- " ព្រះអង្គុលិមាលត្ថេរ ---------------------------- ១១២
៦៧- " ព្រះភគុ ---------------------------------- ១១៧
៦៨- " ព្រះកម្ពិលៈ ------------------------------- ១១៧
៦៩- " ព្រះលកុណ្ឌកភទ្ទិយៈ --------------------------- ១១៧
៧០- " ព្រះកុណ្ឌធាន ------------------------------ ១១៨
៧១- " ព្រះបិលិន្ទវច្ឆៈ ---------------------------- ១១៨
៧២- " ព្រះឧទាយី ------------------------------ ១១៩
៧៣- " ព្រះឧបវាណៈ ----------------------------- ១១៩
៧៤- " ព្រះ មេឃិយៈ ----------------------------- ១២០
៧៥- " ព្រះនាគិតៈ ------------------------------ ១២០
៧៦- " ព្រះចុន្ទៈ ------------------------------- ១២១
៧៧- " ព្រះយសោជៈ ----------------------------- ១២២
៧៨- " ព្រះសភិយៈ ------------------------------ ១២៣
៧៩- " ព្រះសេលៈ ------------------------------- ១២៣
៨០- " ព្រះមហាបន្ថកៈ -------------------------- ១២៤

# ប្រវត្តិព្រះសាវ័កទាំងឡាយដែលខ្ញុំបានរួបរួមទុកក្នុង

## សៀវភៅនេះ

(ពាក្យក្នុងវង់ក្រចកប្រាប់តំណែងឯតទគ្គៈ) គឺ ទំព័រ


១- ប្រវត្តិ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ (រត្តញ្ញូ) ---------- ១

២- " ព្រះវប្បត្ថេរ ---------- ៤

៣ " ព្រះភទ្ទិយត្ថេរ ---------- ៥

៤- " ព្រះមហានាមត្ថេរ ---------- ៥

៥ " ព្រះអស្សជិត្ថេរ ---------- ៦

៦- " ព្រះយសត្ថេរ ---------- ៨

៧- " ព្រះវិមលត្ថេរ ---------- ៩

៨- " ព្រះសុពាហុត្ថេរ ---------- ១១

៩ " ព្រះបុណ្ណជិត្ថេរ ---------- ១១

១០- " ព្រះគវម្បតិត្ថេរ ---------- ១១

១១- " ព្រះឧរុវេលកស្សបត្ថេរ (មានបរិស័ទបរិវារច្រើន) ---------- ១២

១២- " ព្រះនទីកស្សបត្ថេរ ---------- ១២

១៣- " ព្រះគយាកស្សបត្ថេរ ---------- ១២

១៤- " ព្រះសារីបុត្តត្ថេរ (មានបញ្ញាឯក) ---------- ១៦

១៥- " ព្រះមហាមោគ្គល្លានត្ថេរ (មានរិទ្ធិឯក) ---------- ១៩

១៦- " ព្រះមហាកស្សបត្ថេរ ---------- ២២

១៧- " ព្រះមហាកច្ចាយនត្ថេរ (បើកខាងចែកបំបែកសេចក្តីដែលទ្រង់សំដែងដោយសង្ខេបឱ្យពិស្តារ) ---------- ២៤

ទើបលោកតាំងចិត្តទុកតាំងអំពីកាលពេលនោះមកថា កាលណាព្រះអង្គស្ដេចចេញទ្រង់ព្រះផ្នួស នឹងចេញបួសតាមព្រះអង្គ ។

អំណើះកាលតមក ព្រះមហាបុរសស្ដេចចេញទ្រង់ព្រះផ្នួសហើយក៏ពុងធ្វើ ទុក្ករកិរិយា កោណ្ឌញ្ញព្រាហ្មណ៍ក៏បានជ្រាបដំណឹង ទើបបបួលព្រាហ្មណ៍៤នាក់ទៀតគឺវប្បៈ ភទ្ទិយៈ មហានាម នឹងអស្សជិ រួមទាំង៥នាក់នេះហៅថាបញ្ចវគ្គីយ៍ ប្រែថាមានពួក ៥ ឬប្រកបដោយពួក ៥ នាក់ នាំគ្នាចេញទៅបួសតាមព្រះអង្គ គាល់បំរើប្រតិបត្តិព្រះអង្គជាប់ជានិច្ច ដោយនឹកសង្ឃឹមថា កាលណាព្រះអង្គបានត្រាស់ហើយ នឹងទ្រង់ប្រោសទូន្មានខ្លួនឱ្យចេះដឹងផង ។ លុះគ្រាក្រោយមក កោណ្ឌញ្ញព្រាហ្មណ៍ព្រមទាំងព្រាហ្មណ៍ ៤ រូបទៀតបានឃើញថា ព្រះអង្គលះបង់ទុក្ករកិរិយា ទ្រង់ផ្ដើមសេចក្ដីព្យាយាមខាងផ្លូវចិត្ត ក៏អស់សេចក្ដីជ្រះថ្លាទើបនាំគ្នាគេចចេញពីនោះ ទៅអាស្រ័យនៅព្រៃឥសិបតនមិគទាយវ័ន ខេត្តដែនក្រុងពារាណសី ។

កាលព្រះអង្គបានត្រាស់ហើយ ទ្រង់ត្រិះរិះរកបុគ្គលដែលគួរស្ដាប់ធម្មទេសនា ក៏បានទ្រង់ព្រះប្រារព្ធដល់ភិក្ខុបញ្ចវគ្គីយ៍ ដែលធ្លាប់ឧបសម្ព័ទក្នុងព្រះពុទ្ធសាសនា ទើបស្ដេចយាងចូលទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រជាបឋមទេសនា ។ ក្នុងទីបំផុតនៃព្រះធម្មទេសនានេះ លោកកោណ្ឌញ្ញៈបានសម្រេចធម្មចក្ខុ (ភ្នែកមើលឃើញធម៌ ក៏សោតាបត្តិផល) ទើបព្រះបរមសាស្ដាទ្រង់បន្លឺឧទានវាចាថា **អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ** ២ ប្រែថា

ទើបលោកតាំងចិត្តទុកតាំងអំពីកាលពោះមកថា កាលណាព្រះអង្គស្ដេចចេញ
ទ្រង់ព្រះផ្នួស នឹងចេញបួសតាមព្រះអង្គ ។

អំណើះកាលតមក ព្រះមហាបុរសស្ដេចចេញទ្រង់ព្រះផ្នួសហើយក៏ពុង
ធ្វើ ទុក្ករកិរិយា កោណ្ឌញ្ញព្រាហ្មណ៍ក៏បានជ្រាបដំណឹង ទើបបបួលព្រាហ្មណ៍៤
នាក់ទៀតគឺវប្បៈ ភទ្ទិយៈ មហានាម នឹងអស្សជិ រួមទាំង៥នាក់នេះហៅថា
បញ្ចវគ្គិយ៍ ប្រែថាមានពួក ៥ ឬប្រកបដោយពួក ៥ នាក់ នាំគ្នាចេញទៅបួស
តាមព្រះអង្គ គាល់បំរើប្រតិបត្តិព្រះអង្គជាប់ជានិច្ច ដោយនឹកសង្ឃឹមថា កាល
ណាព្រះអង្គបានត្រាស់ហើយ នឹងទ្រង់ប្រោសទូន្មានខ្លួនឱ្យចេះដឹងផង ។ ពុះ
គ្រាក្រោយមក កោណ្ឌញ្ញព្រាហ្មណ៍ព្រមទាំងព្រាហ្មណ៍ ៤ រូបទៀតបានឃើញ
ថា ព្រះអង្គលះបង់ទុក្ករកិរិយា ទ្រង់ផ្ដើមសេចក្ដីព្យាយាមខាងផ្លូវចិត្ត ក៏អស់
សេចក្ដីជ្រះថ្លាទើបនាំគ្នាគេចចេញពីនោះ ទៅអាស្រ័យនៅព្រៃឥសិបតនមឬគ-
ទាយវ័ន ខេត្តដែនក្រុងពារាណសី ។

កាលព្រះអង្គបានត្រាស់ហើយ ទ្រង់ត្រិះរិះរកបុគ្គលដែលគួរទទួលព្រះធម្ម
ទេសនា ក៏បានទ្រង់ព្រះប្រារព្ធដល់ភិក្ខុបញ្ចវគ្គិយ៍ ដែលធ្លាប់ឧបសម្បទក្នុងព្រះ
ពុទ្ធសាសនា ទើបស្ដេចយាងចូលទៅកាន់ព្រៃឥសិបតនមឬគទាយវ័ន ទ្រង់
សំដែងធម្មចក្កប្បវត្តនសូត្រជាបឋមទេសនា ។ ក្នុងទីបំផុតនៃព្រះធម្មទេសនា
នេះ លោកកោណ្ឌញ្ញៈបានសម្រេចធម្មចក្ខុ (ភ្នែកមើលឃើញធម៌ ក៏សោតាបត្តិ
ផល) ទើបព្រះបរមសាស្ដាទ្រង់បន្លឺឧទានវាចាថា អញ្ញាសិ វត ភោ
កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ ២ ប្រែថា

"កោណ្ឌញ្ញ បានដឹងហើយហ្ន៎!" ។ ព្រោះអាស្រ័យព្រះឧទានថា "អញ្ញាសិ" ដែលប្រែថា "បានដឹងហើយ" នេះឯងទើបពាក្យអញ្ញាកោណ្ឌញ្ញៈ ជាប់ជានាមរបស់លោកតាំងអំពីកាលនោះមក ។

លុះព្រះអញ្ញាកោណ្ឌញ្ញៈបានសម្រេចកម្ពុជកុហើយ ទើបក្រាបបង្គំទូលសូមឧបសម្បទក្នុងព្រះពុទ្ធសាសនា ។ ព្រះបរមសាស្ដាទ្រង់អនុញ្ញាតឱ្យលោកបានសម្រេចជាភិក្ខុដោយវិធីឯហិភិក្ខុឧបសម្បទា តមកលោកមានឥន្ទ្រិយធម៌ចាស់គួរចំរើនវិបស្សនាធម៌ ដើម្បីវិមុត្តិហើយ ទើបព្រះអង្គទ្រង់សំដែងអនត្ត-លក្ខណៈសូត្រ ក្នុងវេលាចប់ព្រះធម្មទេសនា លោកព្រមដោយភិក្ខុ ៤ រូបទៀតក៏បានសម្រេចព្រះអរហត្ត ។ តមកលោកបានជួយជាកំឡាំងព្រះបរមសាស្ដា ក្នុងការប្រកាសផ្សាយព្រះសាសនា ហើយលោកបានទទួលសេចក្ដីសរសើរអំពីព្រះអង្គ ក្នុងតំណែងឯតទគ្គៈ គឺជាកំពូលនៃភិក្ខុទាំងឡាយដែលជារត្តញ្ញូ ប្រែថាអ្នកដឹងរាត្រី គឺជាព្រះថេរចាស់ទុំជាងគេ ជាព្រះសាវកអង្គដំបូងនៃព្រះបរមសាស្ដា ។ សេចក្ដីដំណាលថា លោកបាននិមន្តត្រឡប់ទៅស្រុកព្រាហ្មណ៍ ដែលហៅថាទោណវត្ថុជាតិភូមិរបស់លោកហើយបានដឹកនាំបុណ្ណមាណពដែលជាក្មួយរបស់លោក ឱ្យបានបព្វជ្ជាឧបសម្បទា ហើយនាំមកកាន់ព្រះពុទ្ធសំណាក់។ ខ្លួនលោកចាស់ជរាហើយនៅក្នុងទីសេនាសនៈជិតស្រុកមិនសូវសប្បាយ ទើបលោកក្រាបបង្គំទូលលាព្រះបរមសាស្ដា ទៅនៅចាំវស្សាក្នុងព្រៃហិមពាន្តអដ្ឋកថាថា ស្រះឆទ្ទន្ត ជាសុខសប្បាយប្រមាណ ១២ ឆ្នាំ ក៏បរិនិព្វានទៅទីនោះឯង មុនព្រះពុទ្ធបរិនិព្វាន ។

# ២~ប្រវត្តិព្រះវប្បត្ថេរ

ព្រះវប្បត្ថេរ ជាបុត្រព្រាហ្មណ៍ម្នាក់ ដែលត្រូវជ្រើសរើសជាអ្នកព្យាករ ថ្វាយទំនាយ ព្រះលក្ខណៈនៃព្រះមហាបុរស ។ ព្រោះលោកបានជ្រាបដំណឹង អំពីព្រាហ្មណ៍ជាបិតា ដែលអនិច្ចកម្មទៅហើយថា ព្រះមហាបុរស មានព្រះលក្ខណៈត្រូវតាមគម្រោមមហាបុរសបុរិសលក្ខណព្យាករណ៍សាស្ត្រ ហេតុនេះបានជាលោកមានសេចក្ដីគោរពជ្រះថ្លាចំពោះព្រះអង្គណាស់ ។ លុះព្រះអង្គស្ដេចចេញទ្រង់ព្រះផ្នួស លោកព្រមជាមួយព្រាហ្មណ៍ ៤ នាក់ទៀត មានកោណ្ឌញ្ញព្រាហ្មណ៍ជាប្រធាន នាំគ្នាចេញបួសបំរើព្រះអង្គរាល់ព្រឹកល្ងាចដរាបមក ដោយមានសង្ឃឹមថាព្រះអង្គទ្រង់ត្រាស់ដឹងធម៌ពិតក្នុង និងទ្រង់ទូន្មានធម៌នោះដល់ខ្លួនផង ។

កាលតមក ព្រះមហាបុរសទ្រង់លើកលែងប្រព្រឹត្តទុក្ករកិរិយាដែលខ្លួនធ្លាប់ភាប់អានថា ជាកុសលវត្តដ៏ប្រសើរបំផុតនោះហើយ ក៏កើតចិត្តនឿយណាយពីព្រះអង្គ ហើយនាំគ្នាលះបង់គេចរត់ទៅព្រៃឥសិបតនមិគទាយវ័ន ។ លុះព្រះបរមសាស្ដាបានត្រាស់ដឹងហើយ ស្ដេចយាងទៅប្រោសប្រទានព្រះធម្មទេសនាធម្មចក្កប្បវត្តនសូត្រនិងបកិណ្ណកទេសនា ព្រះវប្បត្ថេរ ក៏បានសម្រេចសោតាបត្តិផល ។ តមក លោកបានស្ដាប់អនត្តលក្ខណៈសូត្រដែលព្រះអង្គទ្រង់សំដែង ក៏បានសម្រេចអរហត្តផល ជាអសេខបុគ្គលក្នុងព្រះពុទ្ធសាសនា ។ លោកបានជួយជាកំឡាំងដល់ព្រះបរមសាស្ដាក្នុងការប្រកាសផ្សាយ

សាសនធម៌ ដល់មហាជន បានធ្វើជាឧបជ្ឈាយ៍បំបួសកុលបុត្រក្នុងគ្រាបឋមពោធិកាល ដោយសមគួរដល់សាវកករណីយកិច្ច ។ តមក លោកមានអាយុសង្ខារ សមគួរដល់កាលកំណត់ហើយ ក៏បរិនិព្វាន ។

# ៣-ប្រវត្តិព្រះភទ្ទិយត្ថេរ

ព្រះភទ្ទិយត្ថេរ ជាបុត្រព្រាហ្មណ៍ម្នាក់ ក្នុងពួកព្រាហ្មណ៍ ៨ នាក់ ដែលត្រូវជ្រើសឲ្យជាអ្នកពិនិត្យថ្វាយទំនាយព្រះលក្ខណៈព្រះមហាបុរស កាលព្រះអង្គទើបប្រសូតថ្មីៗ ។ លោកបានជ្រាបដំណឹងអំពីបិតាលោក មុនបិតាលោកធ្វើកាលកិរិយាថា ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ ទើបលោកមានសេចក្តីគោរពព្រះអង្គយ៉ាងក្រៃលែង ។ (រឿងរ៉ាវរបស់ព្រះថេរៈអង្គនេះបានទំនងប្រហែលព្រះវប្បត្ថេរដែរ) ។

នៅទីបំផុត លោកបានស្តាប់ព្រះធម្មចក្កប្បវត្តនសូត្រនឹងអនត្តលក្ខណៈសូត្រ ចិត្តរបស់លោក ក៏ផុតចាកអាសវៈបានសម្រេចព្រះអរហត្តផល ហើយបានជួយជាកម្លាំងដល់ព្រះបរមសាស្តា ក្នុងការប្រកាសផ្សាយព្រះសាសនាក្នុងគ្រាបឋមពោធិកាល លុះលោកមានអាយុសង្ខារសមគួរនឹងកាលកំណត់ហើយក៏បរិនិព្វានទៅ ។ល។

# ៤-ប្រវត្តិព្រះមហានាមត្ថេរ

លោកជាបុត្រព្រាហ្មណ៍ម្នាក់ នៅក្រុងកបិលពស្តុ បិតាលោកជា

ព្រាហ្មណ៍ម្នាក់ក្នុងចំនួន ៨ នាក់ ដែលត្រូវជ្រើសឲ្យពិនិត្យថ្វាយទំនាយព្រះលក្ខណៈព្រះមហាបុរស ។

(មានរឿងរ៉ាវដូចព្រះថេរមុនៗ នេះដែរ)

នៅទីបំផុតលោកបានស្តាប់ធម្មទេសនា ដែលព្រះអង្គទ្រង់សំដែងអំពីធម្មចក្កប្បវត្តនសូត្រ និងអនត្តលក្ខណៈសូត្រ ក៏បានសម្រេចអរហត្តផល ហើយលោកបានជួយជាកម្លាំងព្រះបរមសាស្តា ក្នុងការប្រកាសផ្សាយព្រះសាសនានៅគ្រាបឋមពោធិកាល ដរាបដល់លោកបរិនិព្វាន ។

## ៥-ប្រវត្តិព្រះអស្សជិត្ថេរ

ព្រះអស្សជិត្ថេរអង្គនេះ កើតក្នុងត្រកូលព្រាហ្មណ៍មហាសាល នាក្រុងកបិលពស្តុជាបុត្រព្រាហ្មណ៍ម្នាក់ក្នុងចំនួន ១០៨ នាក់ ដែលបានទទួលព្រះរាជទានស្បៀងភោជនាហារ ក្នុងគ្រាថ្វាយទំនាយព្រះលក្ខណៈព្រះមហាបុរស ។ លោកបានជ្រាបដំណឹងអំពីបិតាលោកប្រាប់ថា ព្រះមហាបុរសមានព្រះលក្ខណៈ ត្រូវតាមគម្រាមហាបុរិសលក្ខណព្យាករណសាស្ត្រ ។ តមកលោកបានចេញបួសជាមួយនឹងព្រាហ្មណ៍ ៤ នាក់ទៀតគឺកោណ្ឌញ្ញៈ វប្បៈ ភទ្ទិយៈ មហានាមៈ នាំគ្នាតាមឧបដ្ឋាក ព្រះមហាបុរស ក្នុងគ្រាដែលព្រះអង្គកំពុងធ្វើទុក្ករកិរិយា ។ កាលព្រះអង្គលើកលែងធ្វើទុក្ករកិរិយា ត្រឡប់មកតាំងសេចក្តីព្យាយាមខាងផ្លូវចិត្តវិញ ក៏កើតគំនិតយល់ស្របគ្នាថា ព្រះអង្គគង់មិនបានត្រាស់ដឹងជាប្រាកដ ទើបនាំគ្នាឡើយណាយគេចទៅនៅព្រៃឥសិបតនមិគទាយវន

ដូចពោលមកហើយក្នុងប្រវត្តិព្រះអញ្ញាកោណ្ឌញ្ញត្ថេរខាងលើនេះ ។

កាលព្រះអង្គបានត្រាស់ដឹងហើយ ស្តេចទៅប្រទានធម្មទេសនាធម្មចក្កប្បវត្តនសូត្រនឹងអនត្តលក្ខណសូត្រ អស្សជិភិក្ខុក៏បានសម្រេចព្រះអរហត្ត ។ គ្រាក្រោយមក កាលមានព្រះអរហន្តច្រើនអង្គក្នុងលោក ហើយព្រះអង្គទ្រង់អញ្ជើញព្រះសាវ័កទៅប្រកាសផ្សាយព្រះសាសនា ក្នុងនានាទិសទេស ព្រះអស្សជិជាព្រះសាវ័កអង្គ ១ ក្នុងចំនួននោះ ដែលបានចេញប្រកាសផ្សាយព្រះសាសនាតាមព្រះពុទ្ធប្រាស់ ។

ថ្ងៃមួយ លោកនិមន្តទៅបិណ្ឌបាត្រ ក្នុងក្រុងរាជគ្រឹះក៏បានជួបនឹងឧបតិស្សបរិព្វាជក បានសំដែងគោលធម៌របស់ពុទ្ធសាសនាឱ្យឧបតិស្សស្តាប់ ឧបតិស្សក៏បានសម្រេចធម្មចក្ខុ ហើយនាំទៅកាន់សំណាក់ព្រះបរមសាស្តា ដើម្បីទទួលបព្វជ្ជាឧបសម្បទា ។ ឧបតិស្សបរិព្វាជកនេះហើយ ដែលជាអគ្គសាវ័កស្តាំរបស់ព្រះអង្គគឺព្រះសារីបុត្ត ។ តាំងអំពីនោះមក ព្រះសារីបុត្តមានសេចក្តីគោរពលោកណាស់ កាលបើដឹងថា ព្រះអស្សជិគង់នៅទិសតំបន់ណា វេលាលោកនឹងសឹង តែងនមស្សការទៅកាន់ទិសនោះហើយលោកសឹងបែរព្រះសិរទៅខាងទិសនោះដែរ ។

ព្រះអស្សជិត្ថេរ មានអាយុសង្ខារសមគួរដល់កាលកំណត់ហើយ ក៏រលត់ខន្ធចូលកាន់បរិនិព្វាន ។

**✦✦**

# ៦~ ប្រវត្តិព្រះយសត្ថេរ

ព្រះយសនេះជាបុត្រសេដ្ឋីនៅក្រុងពារាណសី មានគ្រឹះស្ថាន ៣ ខ្នង សម្រាប់នៅក្នុងរដូវទាំង ៣ ។ គ្រាពេលនោះ ជារដូវភ្លៀងយសកុលបុត្រនៅក្នុងប្រាសាទសម្រាប់រដូវភ្លៀង គេប្រគំបំរើដោយតន្ត្រីសុទ្ធតែពួកស្ត្រីឥតមានបុរសលាយឡំ ។ វេលាយប់ថ្ងៃមួយ យសកុលបុត្រដេកលក់ទៅមុន ពួកស្ត្រីបរិវារដេកលក់តាមក្រោយ ពន្លឺភ្លើងក៏នៅភ្លឺស្វាង យសកុលបុត្រភ្ញាក់ឡើងមុន ស្រាប់តែឃើញពួកបរិវារកំពុងដេកលក់ មានអាការវិកលផ្សេងៗ គឺនាងខ្លះមានពិណធ្លាក់មកនៅនឹងក្លៀក. នាងខ្លះមានស្គរសំភោរនៅខាងក. នាងខ្លះរំសាយសក់. នាងខ្លះដេកហូរទឹកមាត់. នាងខ្លះដេកសង្កៀតធ្មេញមមើនិយាយផ្ដេសផ្ដាស មិននាំឱ្យកើតជាប្រេកត្រេកត្រអាលដូចរបប់មុនៗ ប្រាកដដល់យសកុលបុត្រ ដូចជាសាកសពដែលគេយកទៅបោះចោលនៅព្រៃខ្មោច ។ យសកុលបុត្របានឃើញដូច្នោះហើយក៏កើតសង្វេគស្លុតចិត្តពុញព្រាន់ ទើបបន្លឺឧទានថា "ទីនេះវរវីកណាស់ៗ" ។ យសកុលបុត្រនឹករំខានចិត្តណាស់ ក៏ពាក់ស្បែកជើងដើរចេញចុះពីមាត់ទ្វារផ្ទះ ហើយចេញទៅតាមទ្វារស្រុក រួចសំដៅទៅព្រៃឥសិបតនមិគទាយវ័ន ។ ពេលនោះជិតភ្លឺហើយ ព្រះបរមសាស្តាកំពុងចង្ក្រមក្នុងឱកាសស្រឡះ ទ្រង់បានឮសំឡេងយសកុលបុត្រពោលឧទានដូច្នោះ ដើរចូលមកជិតព្រះអង្គៗ ទ្រង់ត្រាស់ថា "ទីនេះមិនវរវីក ទីនេះឥតទាក់ទិន ចូរអ្នកចូលមកអង្គុយនៅទីនេះចុះ តថាគតនឹងសំដែងធម៌ឱ្យអ្នកស្តាប់" ។

លុះយសកុលបុត្របានឮព្រះវាចាដូច្នោះហើយ ក៏គិតថា ឮថាទីនេះ មិនរវើក. ទីនេះមិនមានទាក់ទិន ទើបដោះស្បែកជើងចេញដើរចូលទៅក្រាបថ្វាយបង្គំ ហើយអង្គុយក្នុងទីដ៏គួរសមមួយ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងអនុបុព្វីកថា ដុះខាតចិត្តយសកុលបុត្រឱ្យឃ្លាតឆ្ងាយ ចាកសេចក្ដីត្រេកអរក្នុងកាម គួរទទួលធម្មទេសនាឱ្យកើតប្រយោជន៍ ដូចសំពត់ដែលស្អាតឥតមន្ទិលគួរទទួលទឹកជ្រលក់ដូច្នោះហើយ ទើបព្រះអង្គទ្រង់ប្រកាសសំដែងអរិយសច្ចទាំង ៤ ជាលំដាប់តទៅ ។ យស-កុលបុត្របានសម្រេចធម្មចក្ខុនៅទីនោះឯង ហើយបានពិចារណាភូមិធម៌ ដែលខ្លួនបានឃើញជាក់ច្បាស់ហើយនោះ ចិត្តក៏ផុតស្រឡះចាកអាសវៈ មិនប្រកាន់មាំដោយឧបាទាន ។

ចំណែកខាងមាតាយសកុលបុត្រ វេលាព្រឹកឡើងទៅលើប្រាសាទកូនមិនឃើញកូន ទើបជម្រាបដល់សេដ្ឋីជាស្វាមី។ ក៏ប្រើមនុស្សឱ្យទៅតាមរកក្នុងទិសទាំង ៤ ហើយខ្លួនឯងក៏ចេញដើររកដែរ ចួនជាដើរទៅចំផ្លូវទៅព្រៃឥសិបតនមិគទាយវ័ន បានឃើញស្បែកជើងកូនដាក់ចោលនៅទីនោះ ក៏ដើរចូលទៅដល់សំណាក់ព្រះសាស្ដា។ ទ្រង់សំដែងអនុបុព្វីកថានឹងអរិយសច្ចទាំង ៤ ឱ្យសេដ្ឋីបានឃើញធម៌ហើយ សេដ្ឋីក្រាបទូលសរសើរព្រះធម្មទេសនាថ្វាយខ្លួនជាឧបាសកសូមដល់ព្រះរតនត្រៃជាទីពឹងទីរលឹកមុនឧបាសកទាំងពួងក្នុងលោក ។

សេដ្ឋីជាបិតាមិនដឹងថា យសកុលបុត្ររស់អាសវៈហើយទើបប្រាប់ថា យសៈ ម្ដាយបាយសោកកន្ទក់កន្ទេញដល់បាខ្លាំងណាស់ ចូរបាឱ្យជីវិតដល់

ម្តាយបាផង" ។ យសកុលបុត្រក្រឡេកមើលព្រះបរមសាស្តា ។ ទ្រង់ត្រាស់នឹងសេដ្ឋីថា "យសកុលបុត្រមានចិត្តផុតចាកអាសវៈមិនប្រកាន់ជាប់ដោយឧបាទាន មិនគួរត្រឡប់ទៅបរិភោគកាមគុណ ដូចអំពីមុនទេ" ។ សេដ្ឋីក្រាបបង្គំទូលសរសើរសំណាងយសកុលបុត្រហើយ ទើបក្រាបទូលអារាធនាព្រះអង្គព្រមទាំងព្រះយសជាបច្ឆាសមណៈ ឱ្យស្តេចទទួលបិណ្ឌបាតក្នុងវេលាព្រឹកថ្ងៃនុះឯង ។

លុះសេដ្ឋីក្រាបថ្វាយបង្គំត្រឡប់ទៅវិញហើយ ទើបព្រះយសក្រាបបង្គំទូលសូមឧបសម្បទ ព្រះអង្គទ្រង់ប្រទានដោយវិធីឯហិភិក្ខុឧបសម្បទានៅគ្រានោះ មានព្រះអរហន្តកើតឡើងក្នុងលោករួម៧អង្គទាំងព្រះយស ។

វេលាព្រឹកថ្ងៃនោះ ព្រះបរមសាស្តានឹងព្រះយសស្តេចទៅដល់ផ្ទះសេដ្ឋីហើយ ទើបមាតានឹងភរិយាសចាស់របស់ព្រះយស ចូលមកក្រាបបង្គំគាល់ ព្រះអង្គទ្រង់សំដែងអនុបុព្វីកថានិងអរិយសច្ចទាំង ៤ ឱ្យស្ត្រីទាំងពីរនាក់បានឃើញធម៌ច្បាស់ ។ ស្ត្រីទាំងពីរក៏ក្រាបទូលសរសើរព្រះធម្មទេសនា ថ្វាយខ្លួនជាឧបាសិកាដល់ព្រះរតនត្រៃមុនស្ត្រីទាំងពួងក្នុងលោក ។ កាលដល់ពេលវេលាហើយមាតាបិតានិងភរិយាចាស់របស់ព្រះយស ក៏អង្គាសព្រះបរមសាស្តានិងព្រះយស ដោយខាទនីយភោជនីយាហារដ៏ប្រណីតដោយដៃខ្លួនឯង ។ លុះឆាន់ស្រេចហើយទ្រង់សំដែងធម្មិកថាឱ្យទានជនទាំង ៣ ឱ្យរីករាយក្លាហានក្នុងធម៌ហើយ ទើបស្តេចត្រឡប់ទៅព្រៃឥសិបតនមឬទាយវ័នវិញ ។

ចំណែកសម្លាញ់ព្រះយស ៤ នាក់ជាបុត្រសេដ្ឋីនៅក្រុងពារាណសីបានឮដំណឹងថា យសកុលបុត្រចេញទៅបួសហើយ ក៏គង់យល់ឃើញថា ធម្មវិន័យ

ដែលព្រះយសកុលបុត្រចេញទៅបួសនោះ គង់មិនថោកទាបពិតប្រាកដ ទើបនាំគ្នាចេញទៅបួសតាមព្រះយស ហើយបានសម្រេចអរហត្តផលនៅវេលាគ្រានោះ ទើបកើតទាន់ព្រះអរហន្ត ។

ឯសម្លាញ់ព្រះយស ៥០ នាក់ទៀត នៅក្នុងជនបទខេត្តក្រៅ បានដឹងដំណឹងដូច្នោះ ក៏មានគំនិតគិតឃើញដូចទំនងមុននេះដែរ ក៏ស្រុះចិត្តគ្នាចេញបួសតាមព្រះយសត្ថេរ ហើយបានសម្រេចអរហត្តផលទាំងអស់អង្គ រួមព្រះអរហន្តក្នុងលោកនាកាលណោះ ៦១ អង្គ ។

ព្រះយសត្ថេរបានជាកម្លាំងព្រះបរមសាស្តា ក្នុងការពង្រីកព្រះពុទ្ធសាសនាក្នុងគ្រាបឋមពោធិកាល ។ លុះលោកមានអាយុសង្ខារ សមគួរនឹងកាលកំណត់ ហើយក៏បរិនិព្វាន ។

## ៧- ប្រវត្តិព្រះវិមលត្ថេរ

## ៨- ប្រវត្តិព្រះសុពាហុត្ថេរ

## ៩- ប្រវត្តិព្រះបុណ្ណជិត្ថេរ

## ១០- ប្រវត្តិព្រះគវម្បតិត្ថេរ (១)

ព្រះថេរៈទាំង ៤ អង្គនេះ ជាបុត្រសេដ្ឋីនៅក្រុងពារាណសី ហើយជា

---

១- ព្រះថេរទាំង ៤ អង្គ មានរឿងរ៉ាវដែលនាំឱ្យលោករួមកាន់ធម្មវិន័យប្រហែលគ្នា ទាំងជាតិភូមិរបស់លោកក៏នៅក្នុងតំបន់ជាមួយគ្នា ទើបផ្គួបតំណាលប្រវត្តិរបស់លោករួមទាំង ៤ អង្គតែម្តង ។

សំឡាញ់ពេញចិត្តរបស់ព្រះយសត្ថេរបានជ្រាបពតិហេតុថា យសកុលបុត្រ សំឡាញ់របស់ខ្លួន១ ចេញទៅបួសក្នុងព្រះពុទ្ធសាសនាហើយ ក៏បានពិចារណា ឃើញស្របគ្នាថា ធម្មវិន័យដែលយសកុលបុត្របានប្រព្រឹត្តនោះមិនមែនជា របស់ថោកទាបទេ គង់ជាធម្មវិន័យប្រសើរខ្ពង់ខ្ពស់ ទើបបបួលគ្នាទាំង ៤ នាក់ ចូលទៅរកព្រះយសត្ថេរ ។ ក៏នាំសំឡាញ់ទាំង ៤ ចូលទៅក្រាបថ្វាយបង្គំព្រះ បរមសាស្តា។ ទ្រង់សំដែងអនុបុព្វីកថា គឺទ្រង់ពណ៌នាអំពីទាន-សីល បានសួគ៌ ទោសរបស់កាម នឹងអានិសង្សនៃផ្នួសជាឧបាយដុសខាត់ចិត្តពិតនៃកុលបុត្រ ទាំងនោះ ឱ្យឡើយណាយចាកកាមហើយទើបទ្រង់សំដែងអរិសច្ចទាំង ៤ ជា លំដាប់តទៅ ។

ក្នុងទីបំផុតនៃព្រះធម្មទេសនា កុលបុត្រទាំងនោះបានសម្រេចអរហត្ត មិនប្រកាន់មាំដោយឧបាទាន ហើយក្រាបបង្គំទូលសូមឧបសម្បទ ព្រះបរម សាស្តាក៏ទ្រង់អនុញ្ញាតដោយវិធីឯហិភិក្ខុឧបសម្បទា ។ ព្រះថេរៈទាំង៤អង្គ នេះ បានជួយជាកំឡាំងព្រះបរមសាស្តា ក្នុងការប្រកាសផ្សាយព្រះសាសនា ក្នុងនានាជនបទ គ្រាបថមពោធិកាលគ្រាតែគ្រប់កំណត់អាយុសង្ខាររបស់ លោកទើបបរិនិព្វាន ។

## ១១~ ប្រវត្តិព្រះឧរុវេលកស្សបត្ថេរ

## ១២~ ប្រវត្តិព្រះនទីកស្សបត្ថេរ.

## ១៣~ ប្រវត្តិព្រះគយាកស្សបត្ថេរ.

ព្រះថេរទាំង ៣ អង្គនេះ កើតក្នុងត្រកូលព្រាហ្មណ៍កស្សបគោត្រ ហើយជាបងប្អូនគ្នាទាំង ៣ អង្គ បងច្បងមាននាមថា ឧរុវេឡកស្សប ប្អូនបន្ទាប់មាននាមថា នទីកស្សប ប្អូនពៅមាននាមថា គយាកស្សប ។ ដែលហៅថាកស្សបព្រោះហៅឈ្មោះតាមគោត្រ ដែលហៅថាឧរុវេឡក្តី នទីក៏ គយាក្តី ហៅតាមឈ្មោះតំបន់ដែលលោកទៅតាំងអាស្រម អាស្រ័យនៅក្នុងពេលបួសជាជដិល ។ លោកទាំង ៣ អង្គនេះ មានជាតិភូមិនៅទីតំបន់ណា ព្រះគន្ថរចនាចារ្យមិនបានពោលទុក ។

លោកទាំង ៣ អង្គកាលនៅក្នុងវ័យកុមារ បានសិក្សារៀនសូត្រចេះចប់គម្ពីរត្រៃវេទ តាមលទ្ធិព្រាហ្មណ៍ ។ ជនទាំង ៣ ពិចារណាផលនៃការសិក្សាក្នុងលោកីយនេះមិនមានខ្លឹមសារ ទើបប្រាថ្នាផលក្នុងផ្លូវបរលោកទៅទៀត ហើយនាំគ្នាចេញបួសជាជដិល គឺអុកបួសទុកសក់វែងព្រមទាំងបរិវារ ។ បងច្បងតាំងអាស្រមនៅតំបន់ឧរុវេលា ទើបមាននាមឆាយាថា ឧរុវេលកស្សប ។ ប្អូនបន្ទាប់តាំងអាស្រមនៅត្រង់ទន្លេគង្គា ទើបមាននាមឆាយាថា នទីកស្សប ។ ប្អូនពៅ តាំងអាស្រមនៅត្រង់តំបន់គយាសីសៈ ទើបមាននាមឆាយាថា គយាកស្សប ។

ឧរុវេលកស្សបមានជដិល ៥០០ ជាបរិវារ ។ នទីកស្សបមានជដិល ៣០០ ជាបរិវារ ។ គយាកស្សបមានជដិល ២០០ ជាបរិវារ ។ នាយកជដិលទាំង ៣ រូបនេះ នាំគ្នាប្រព្រឹត្តវត្តបូជាភ្លើងឆ្អើរកិលេសតាមលទ្ធិព្រាហ្មណ៍ ។

កាលព្រះមហាបុរសបានត្រាស់ដឹងហើយ ព្រះអង្គមានព្រះបំណងនឹង

ព្រះអង្គក៏ទ្រង់ប្រទានពាក្យរៀនដូចអ៊ីយហុនចេះដែរ ។

ព្រះបរមសាស្ដា ស្ដេចប្រថាប់ក្នុងតំបន់ឧរុវេលកស្សបពាបសមគួរហើយ ស្ដេច ព្រមដោយភិក្ខុសង្ឃទាំងនោះ យាងទៅកាន់តំបន់គយាសីសៈប្រទេស ជិតអស្ពួតភោ ទ្រង់ត្រាស់ហៅប្រជុំភិក្ខុទាំងនោះមកជុំហើយ ទ្រង់សំដែងអាទិត្តបរិយាយសូត្រ គឺទ្រង់សំដែងអំពីសភាវធម៌ទាំងពួងជារបស់ក្ដៅដើម្បីឱ្យសាបដល់បុព្វចរិយារបស់ពួកបុរាណជដិល ដែលធ្លាប់អប់រំមកក្នុងការបូជាភ្លើង ។ វេលាចប់ព្រះធម្មទេសនា ចិត្តរបស់ភិក្ខុទាំងនោះក៏ផុតស្រឡះចាកអាសវក្កិ-លេសទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន (សម្រេចព្រះអរហត្ត) ។

តពីនោះ ព្រះអង្គព្រមដោយភិក្ខុសាវក ១០០៣ អង្គ ស្ដេចត្រេចចារិកទៅដោយលំដាប់ ដល់ក្រុងរាជគ្រឹះចូលប្រថាប់ក្នុងសួនត្នោតសាវដែលហៅថាវេឡុវ័ន ។ ព្រះបាទពិម្ពិសារនៃមគធរដ្ឋ ទ្រង់ជ្រាបដំណឹង ទើបស្ដេចព្រមដោយសេវកាមាត្យរាជបរិវារជាច្រើន ចូលទៅគាល់ព្រះបរមសាស្ដា ។ ទ្រង់ទតព្រះនេត្រឃើញរាជបរិវារមានអាការផ្សេងៗ មិនរៀបរយ ។ ទ្រង់មានព្រះពុទ្ធដីកានឹងព្រះឧរុវេលកស្សប ដែលជាទីគោរពរាប់អាននៃជនទាំងនោះ ឱ្យថ្លែងប្រកាសដល់ការមិនមានខ្លឹមនៃលទ្ធិចាស់ដើម្បីបង្អោនចិត្តនៃរាជបរិវារឱ្យប្រុងចាំស្ដាប់ ព្រះធម្មទេសនារបស់ព្រះអង្គ ទើបទ្រង់ប្រោសសំដែងអនុបុព្វីកថា នឹងអរិយសច្ចទាំង ៤ ។ វេលាចប់ព្រះធម្មទេសនា ព្រះបាទពិម្ពិសារនឹងរាជបរិវារចែងជា ១២ ភាគ ១១ ភាគ បានសម្រេចធម្មចក្ខុ ១ ភាគទៀត តាំងនៅក្នុងត្រៃសរណគមន៍ ។

ហេតុដូច្នេះ ទើបឃើញថាព្រះឧរុវេលកស្សបផ្ទេរជាកំឡាំងយ៉ាងធំក្នុងការជួយប្រកាសព្រះសាសនា ដើម្បីប្រតិស្ឋានព្រះពុទ្ធសាសនាក្នុងក្រុងរាជគ្រឹះ ហើយព្រះថេរអង្គនេះជាអ្នកមានបរិស័ទបរិវារច្រើន ដែលជាផលនៃការចេះយកចិត្តបរិស័ទ ចេះសង្គ្រោះដោយអាមិសផង ដោយធម៌ផង ។ ព្រះថេរៈប្រកបដោយគុណសម្បត្តិបែបនេះ បរិស័ទតែងស្រឡាញ់រាប់អាន ជាគុណដែលគួរគប្បីប្រាថ្នាក្នុងសាវកមណ្ឌលហេតុនេះ បានជាព្រះបរមសាស្ដាទ្រង់ដំកើងលោក ក្នុងដំណែងឯតទគ្គៈជាកំពូលនៃភិក្ខុទាំងឡាយ ដែលមានបរិស័ទច្រើន ។

# ១៤~ប្រវត្តិព្រះសារីបុត្តត្ថេរ

ព្រះសារីបុត្តត្ថេរនេះ ជាបុត្រព្រាហ្មណ៍មេតំបន់ម្នាក់ឈ្មោះវង្គន្តៈនឹងនាងសារីក្នុងស្រុកនាលកៈ ឬនាលន្ទៈ ជិតក្រុងរាជគ្រឹះ ។ ពីមុនមកលោកឈ្មោះ ឧបតិស្សៈ ហៅឈ្មោះតាមដែលជាបុត្រនាងសារីថា សារីបុត្រ ។ កាលលោកបានចូលមកឧបសម្បទ ក្នុងធម្មវិន័យនេះហើយ ពួកសព្រហ្មចារីភិក្ខុនិយមហៅឈ្មោះលោកថា សារីបុត្រតែឈ្មោះមួយរហូតមក ។

ព្រះគន្ថរចនាចារ្យបានពោលទុកថា ឧបតិស្សមាណពនេះជាបុត្រនៃត្រកូលដែលបរិបូណ៌ដោយភោគសម្បត្តិនឹងបរិវារបានរៀនសូត្រចេះដឹងសិល្បសាស្ត្រស្ទាត់ជំនាញ ហើយមានមិត្រស្និទ្ធស្នាលម្នាក់ឈ្មោះកោលិកមាណពមោគ្គល្លានគោត្រ មានវយៈស្របករគ្នា ជាព្រហ្មបេស្ដកស្តុ្បដូចផ្កា ។ សម្លាញ់ទាំងពីរនាក់នេះ តែងនាំគ្នាទៅមើលមហោស្រពក្នុងក្រុងរាជគ្រឹះជាមួយគ្នាជា

រឿយៗ លុះតមកថ្ងៃមួយសំឡាញ់ទាំងពីរកំពុងតែមើលល្បែង ដែលគេកំពុងលេងនោះ ស្រាប់តែកើតចិត្តនឿយណាយពុញទ្រាន់ ហាក់ពុំព្រះស្រាបផ្លូវ មើលល្បែងឥតប្រយោជន៍គួរស្វែងរកមោក្ខធម៌វិញគាប់ប្រសើរជាង ទើបនាំគ្នាទៅបួសក្នុងសំណាក់សញ្ជ័យបរិព្វាជកព្រមទាំងបរិវារ ។ លុះសិក្សាលទ្ធិ-សញ្ជ័យបរិព្វាជកចេះចប់ហើយ ពិចារណាទៅឃើញថា មិនមានខ្លឹមសារអាចនឹងលុះដល់មោក្ខធម៌បាន ទើបធ្វើកតិកាប្តេជ្ញាគ្នា បើអ្នកណាបានសម្រេចមោក្ខធម៌បាន ត្រូវសំដែងប្រាប់គ្នាទៅវិញទៅមក ។

ថ្ងៃមួយ ឧបតិស្សបរិព្វាជកបានឃើញព្រះអស្សជិត្ថេរ ព្រះបរមសាស្តាទ្រង់បញ្ជូនឱ្យចេញទៅប្រកាសព្រះសាសនា បានឃើញអាការលោកគួរឱ្យជ្រះថ្លា ទើបចូលទៅសាកសួរព្រះអស្សជិត្ថេរៗ បានសំដែងគោលធម៌យ៉ាងសង្ខេបឱ្យឧបតិស្សបរិព្វាជកស្តាប់ ក៏បានសម្រេចសោតាបត្តិផលទើបសួរព្រះថេរៈថា ព្រះបរមសាស្តាស្តេចគង់នៅទីណា ។ ឧបតិស្សបរិព្វាជកបានដឹងថា ព្រះអង្គគង់នៅវេឡុវ័នទើបត្រឡប់ទៅប្រាប់កោលិតបរិព្វាជក ហើយសំដែងធម៌នោះឱ្យស្តាប់ ។ កោលិតបរិព្វាជក ក៏បានសម្រេចសោតបត្តិផលដែរ រួចនាំគ្នាចូលទៅលាសញ្ជ័យបរិព្វាជកដែលជាគ្រូដើម ហើយសម្លាញ់ទាំងពីរនាំបរិវារចូលទៅគាល់ព្រះបរមសាស្តា ក្រាបបង្គំទូលសុំឧបសម្បទ ព្រះអង្គក៏ទ្រង់អនុញ្ញាតឱ្យបានសម្រេចជាភិក្ខុទាំងអស់គ្នា ។ ក្នុងចំណោមភិក្ខុទាំងនោះ ពួកភិក្ខុដែលជាបរិវារបានសម្រេចអរហត្តមុន។ ព្រះមោគ្គល្លានបានឧបសម្បទហើយ ៧ ថ្ងៃទើបបានសម្រេច ។ តាំងពីឧបសម្បទកន្លងទៅបានកន្លះខែ ទើបព្រះសារីបុត្រ

បានសម្រេចព្រះអរហត្ត ។

មានរឿងដំណាល អំពីដំណើរដែលលោកសម្រេចអរហត្តថា ថ្ងៃមួយ ព្រះសាស្ដាគង់នៅក្នុងគុហា សូករខាតា ភ្នំគិជ្ឈកូដ ដែនក្រុងរាជគ្រឹះទ្រង់សំដែងទិដ្ឋិ៣ ប្រការ [១] ដល់បរិព្វាជកម្នាក់ឈ្មោះទីឃនខៈអគ្គិវេស្សនៈគោត្រ ដែលចូលគាល់ក្រាបទូលប្រស្រ័យនឹងព្រះអង្គ ។ ខណៈនោះ ព្រះសារីបុត្របក់ពាត់ថ្វាយព្រះបរមសាស្ដា បានពិចារណាធម៌ដែលទ្រង់សំដែងនោះ ចិត្តរបស់លោកក៏ផុតស្រឡះចាកអាសវៈមិនប្រកាន់មាំដោយឧបាទាន ។ ឯទីឃនខៈ-បរិព្វាជក បានសម្រេចធម្មចក្ខុ ក្រាបទូលសរសើរព្រះធម្មទេសនា ហើយថ្វាយខ្លួនជាឧបាសក ។

ព្រះសារីបុត្រនេះ ល្បីល្បាញថា លោកមានសតិបញ្ញាក្លាហានក្រៃលែងជាងព្រះសាវកដទៃទៀត ទើបព្រះអង្គទ្រង់សរសើរថាជាឯតទគ្គ គឺជាកំពូលនៃភិក្ខុទាំងឡាយដែលមានបញ្ញា អាចសំដែងព្រះធម្មចក្រនឹងចតុរារិយសច្ចប្រហែលព្រះអង្គបាន ។ បើមានពួកភិក្ខុក្រាបទូលលាមីងត្រេចចារិកទៅកាន់ផ្លូវឆ្ងាយ ព្រះអង្គច្រើនត្រាស់ឱ្យអស់លោកទាំងនោះ ទៅទូលលាព្រះសារីបុត្រជាមុន ដើម្បីឱ្យលោកឲ្វទានភិក្ខុទាំងនោះ ។ ព្រះសារីបុត្រនេះ ព្រះបរម-សាស្ដាទ្រង់តាំងដំកើងជាអគ្គសាវកខាងស្ដាំ ជាគូនឹងព្រះមោគ្គល្លាន (ដូចមានប្រវត្តិខាងមុខនេះ) ជាអគ្គសាវកខាងឆ្វេង ជាអ្នកអនុគ្រោះសហធម្មិកផងគ្នា

---

១- មើលសេចក្ដីពិស្ដារ ក្នុងគម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ។

ទ្រង់ប្រៀបព្រះសារីបុត្រដូចមាតាដែលបង្កើតកូន អាចណែនាំកុលបុត្រឱ្យឋិតនៅក្នុងសោតាបត្តិផល ។ បើលើកយកពុទ្ធភាសិតចេញហើយភាសិតរបស់លោកបានច្រើនជាងព្រះសាវ័កឯទៀត ដូចសម្មាទិដ្ឋិសូត្រជាដើម ។ លោកមានគុណប្រាកដថាជាអ្នកមានកតញ្ញូកតវេទីណាស់សូម្បីតែធ្វើទានលោកដោយបាយ ១ វែកក៏មិនភ្លេចដែរ ។ លោកមានជន្មាយុរហូតមកដល់បច្ឆិម-ពោធិកាល ក្នុងវស្សាទី ៤៥ ។ លុះលោកជិតបរិនិព្វាន មានប្រាថ្នានឹងប្រោសមាតាលោកជាគ្រាចុងក្រោយបង្អស់ ទើបលោកក្រាបទូលលាព្រះដ៏មានបុណ្យនាំព្រះចុន្ទត្ថេរជាប្អូនព្រមទាំងបរិវារ និមន្តទៅកាន់ស្រុកកំណើត ក៏កើតរោគបក្ខន្ទិកាពាធឡើងក្នុងវេលានោះ លោកខំទេសនាប្រោសមាតាលោកទាំងកំពុងអាពាធ ត្រាតែមាតាលោកបានសម្រេចសោតាបត្តិផល លុះពេលបច្ចូសសម័យជាថ្ងៃពេញបូណ៌មីខែកត្តិកព្រះអគ្គសាវ័កក៏បរិនិព្វាន ។ ដល់ព្រឹកឡើងព្រះចុន្ទត្ថេរក៏ចាត់ចែងធ្វើឈាបនកិច្ចសពលោក រើសអដ្ឋិធាតុនាំទៅថ្វាយព្រះបរមសាស្តា ។ ព្រះអង្គទ្រង់ត្រាស់ឱ្យកព្រះចេតិយបញ្ចុះអដ្ឋិធាតុលោកទុកជាទីសក្ការបូជានៃមហាជនក្នុងវត្តព្រះជេតវន ក្រុងសាវត្ថី ។

## ១៥-ប្រវត្តិមោគ្គល្លានត្ថេរ

ព្រះមោគ្គល្លានត្ថេរ កើតក្នុងតំបន់ជិតក្រុងរាជគ្រឹះជាបុត្រព្រាហ្មណ៍នាយតំបន់ម្នាក់ឈ្មោះកោលិតៈ ម្តាយលោកឈ្មោះមោគ្គល្លី ។ គេហៅឈ្មោះលោកតាមគោត្របិតាថា កោលិតៈ ។ គេហៅឈ្មោះលោកម្យ៉ាងទៀតតាម

ដែលជាបុត្ររបស់នាងមោគ្គល្លីថា មោគ្គល្លាន: លុះលោកចូលបួសក្នុងធម៌វិន័យនេះហើយ ពួកព្រហ្មចារីហៅឈ្មោះលោកថា មោគ្គល្លាន: តែឈ្មោះមួយនេះរហូតមក ។ តាំងពីកាលលោកនៅក្នុងវ័យកុមារជាមិត្រស្និទ្ធស្នាលនឹងព្រះសារីបុត្រ មានអាយុស្រករគ្នា បានសិក្សាសិល្បសាស្ត្រជាមួយគ្នា ចូលបួសជាបរិព្វាជកជាមួយគ្នាហើយចូលមកឧបសម្បទក្នុងធម្មវិន័យនេះជាមួយគ្នា ដូចមានក្នុងប្រវត្តិព្រះសារីបុត្រខាងលើនេះស្រាប់ ។ ក្នុងទីនេះនឹងពោលចំពោះតែប្រវត្តិរបស់លោកដោយឡែកតទៅ ។

ចាប់តាំងពីកាលដែលលោកបានបួសបានឧបសម្បទហើយ ៧ ថ្ងៃ លោកទៅធ្វើសេចក្តីព្យាយាមចំរើនធម៌ នៅស្រុកកល្លវាលបុត្តគ្រាមខែត្រដែនមគធរដ្ឋ ទន់ខ្សោយកម្លាំងចិត្តអង្គុយងោក ។ ព្រះដ៏មានបុណ្យស្តេចយាងទៅកាន់ទីនោះ ទើបទ្រង់ពន្យល់ឧបាយសម្រាប់រម្ងាប់ងងុយងោក ហើយត្រាស់ទូន្មានមិនឱ្យប្រកាន់ខ្លួនចូលទៅកាន់ត្រកូល ឱ្យនៅក្នុងទីសេនាសនៈស្ងាត់ គួរជាទីស្ងប់អារម្មណ៍តាមសមណៈវិស័យ [១] ។ ព្រះមោគ្គល្លានប្រតិបត្តិតាមព្រះពុទ្ធឱវាទ ដែលទ្រង់ទូន្មាន ក៏បានសម្រេចអរហត្តក្នុងថ្ងៃនុ៎ះឯង ។

ព្រះបរមសាស្តាទ្រង់សរសើរព្រះមោគ្គល្លាន ជាគូនឹងព្រះសារីបុត្រថាជាអ្នកមានឧបការៈដល់ពួកភិក្ខុឧបសម្ប័ទថ្មី ហើយជាព្រះអគ្គសាវកខាងឆ្វេងដូចពោលមកហើយ ។

---

១- មើលសេចក្តីពិស្តារ ក្នុងអង្គុត្តរនិកាយ សត្តកនិបាត ។

មួយវិញទៀត ទ្រង់ដំកើងលោកក្នុងតំណែងជាឯតទគ្គៈ គឺជាកំពូលនៃភិក្ខុទាំងឡាយដែលមានឫទ្ធិ ។ ព្រះបរមសាស្ដាបានសាវកដែលមានបញ្ញាឯក មានឫទ្ធិឯក ។ ទាំងពីរអង្គទុកក្នុងតំណែងអគ្គសាវក ជាកម្លាំងយ៉ាងធំក្រៃលែងរបស់ព្រះអង្គ ក្នុងការប្រកាសផ្សាយព្រះសាសនា ឱ្យកាន់តែរីកចំរើនឡើងក្នុងទិសទាំងពួង ។

ធម្មទេសនារបស់ព្រះមោគ្គល្លាន មិនសូវមានសម្បូរក្នុងគម្ពីរទាំងឡាយ ឃើញពោះតែអនុមានសូត្រ ដែលលោកបានឱ្យឱវាទដល់ភិក្ខុសង្ឃ ព្រះធម្មសង្គាហកាចារ្យបានរួបរួមក្នុងគម្ពីរមជ្ឈិមនិកាយ ។

ព្រះមោគ្គល្លាននេះ ប្រកបដោយឫទ្ធិឈ្លាសខាងការនវកម្មទើបទ្រង់ប្រោសជានវកម្មាធិដ្ឋាយី គឺអ្នកមើលការនវកម្មនៃវិហារបុព្វារាម នៅក្រុងសាវត្ថី ដែលមហាឧបាសិកាវិសាខាបានកសាងឡើង ។

មានសេចក្ដីដំណាលមុនលោកបរិនិព្វានថា កាលគ្រាដែលលោកទៅគង់នៅដំបន់កាឡសិលា ដែនមគធរដ្ឋ ពួកអន្យតិរ្ថិយប្រឹក្សាគ្នាថា ព្រះមោគ្គល្លាននោះជាកម្លាំងធំណាស់របស់ព្រះពុទ្ធ អាចនាំដំណឹងពីឋានសួគ៌នឹងឋាននរក មកថ្លែងដល់មនុស្សលោក បើយើងកំចាត់ព្រះមោគ្គល្លានចេញទៅបានហើយ លទ្ធិខាងពួកយើងនឹងចំរើនរុងរឿងឡើង ទើបជួលពួកចោរឱ្យទៅលបលួចសម្លាប់លោក ។ ពួកចោរនាំគ្នាចូលស្ទាក់ចាប់សម្លាប់លោកដល់ពីរលើក លោកគេចផុតទៅទាំងពីរលើក ដល់មកលើកទីបី លោកពិចារណាឃើញកម្មចាស់តាមមកទាន់ ទើបលោកមិនគេច ។ ពួកចោរក៏ចាប់លោកវាយដំត្រាតែល្អិតខ្ទេច

ហើយយកសរីរៈលោកទៅលាក់ទុកក្នុងស៊ុមទ្រុមព្រៃមួយអន្លើ ហើយនាំគ្នាគេចរត់ទៅ ។ ព្រះថេរៈមិនទាន់ដល់មរណៈទេ លោកខំរក្សាព្យាបាលអត្តភាពដោយចេកម្លាំងឈាន និមន្តទៅគាល់ព្រះបរមសាស្តា ក្រាបទូលលាសូមបរិនិព្វាន ហើយវិលមកបរិនិព្វានទៅកន្លែងដើមវិញ ក្នុងថ្ងៃ ១៥ រោចខែកត្តិក ខាងក្រោយព្រះសារីបុត្របរិនិព្វានទៅកន្លះខែ ។ ព្រះដ៏មានបុណ្យស្តេចទៅធ្វើឈាបនកិច្ចសពលោក រួចមានព្រះពុទ្ធដីកាឱ្យរើសយកអដ្ឋិធាតុមកកចេតិយបញ្ចុះទុកជិតស៊ុមទ្វារនៃវិហារវេឡុវន ។

## ១៦-ប្រវត្តិព្រះមហាកស្សបត្ថេរ

ព្រះមហាកស្សបត្ថេរនេះ ជាបុត្រកបិលព្រាហ្មណ៍កស្សបគោត្រក្នុងស្រុកមហាតិត្ថៈ ដែនមគធរដ្ឋ នាមដើមហៅថា បិប្ផលិ ដល់អាយុ ២០ ឆ្នាំ បានធ្វើអាវាហមង្គលនឹងនាងភទ្ទកាបិលានីអាយុ ១៦ ឆ្នាំ ជាបុត្រីព្រាហ្មណ៍កោសិយ-គោត្រ នៅសាគលនគរ ដែនមគធៈដែរ ។ ត្រកូលនៃស្វាមីភរិយាគូនេះ មានសម្បត្តិស្តុកស្តម្ភណាស់ មានការងារជាទីកើតនៃភោគសម្បត្តិច្រើន មានមនុស្សនឹងសត្វពាហនៈសម្រាប់ប្រើការក៏ច្រើន ប៉ុន្តែឥតមានបុត្រធីតាសោះ ។ លុះមាតាបិតាធ្វើកាលកិរិយាទៅហើយ បបួលមាណពបានគ្រប់គ្រងទ្រព្យសម្បត្តិនោះ ។ តមកស្វាមីភរិយាគូនេះពិចារណាឃើញថា អ្នកនៅគ្រប់គ្រងផ្ទះត្រូវទទួលបាប ព្រោះការងារដែលជនដទៃធ្វើល្អខ្លះមិនល្អខ្លះ ទើបកើតចិត្តនឿយណាយខាងឃរាវាស ហើយបបួលគ្នាចេញទៅបួស ។ បបួលមាណពបានចេញ

បួស ឧទ្ទិសចំពោះព្រះអរហន្តក្នុងលោក ហើយបានជួបប្រទះនឹងព្រះដ៏មានបុណ្យ ព្រះអង្គគង់ក្រោមម្លប់ដើមជ្រៃដែលមានឈ្មោះថា ពហុបុត្តកនិគ្រោធ ស្ថិតនៅចន្លោះព្រំដែននៃក្រុងរាជគ្រឹះនឹងស្រុកនាលន្ទ ក៏មានសេចក្ដីជ្រះថ្លាថ្វាយខ្លួនជាសាវ័ក ។ ព្រះបរមសាស្ដា ទ្រង់អនុញ្ញាតឱ្យលោកបានសម្រេចជាភិក្ខុ ដោយទ្រង់ប្រទានឱវាទ ៣ ខថា "ម្នាលកស្សប អ្នកគប្បីសិក្សាថា យើងនឹងតាំងដំកល់នូវសេចក្ដីអៀនខ្មាស នឹងសេចក្ដីកោតក្រែងចំពោះភិក្ខុចាស់ថ្មីនឹងជាន់កណ្ដាលយ៉ាងមុឹងមាត់ប្រការ ១ ថាយើងស្ដាប់ធម៌ឯណានីមួយដែលប្រកបដោយកុសល គប្បីផ្ទៀងត្រចៀកស្ដាប់ធម៌នោះ ពិចារណាយកសេចក្ដីប្រការ ១ ថាយើងនឹងមិនលះបង់សតិដែលប្រព្រឹត្តទៅក្នុងកាយ គឺពិចារណារាងកាយជាអារម្មណ៍ប្រការ ១" ។

លោកទទួលយកព្រះពុទ្ធោវាទដោយសេចក្ដីគោរពថ្វាយ ជាអ្នកមិនប្រមាទខំបំពេញព្យាយាម មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តក្នុងថ្ងៃគំរប់ ៨ រាប់ពីថ្ងៃបានឧបសម្បទមក ។ ព្រះថេរៈអង្គនេះ បានទទួលសេចក្ដីសរសើរអំពីព្រះបរមសាស្ដា ថាមានវិហារធម៌ស្មើដោយព្រះអង្គ ហើយទ្រង់ធ្លាប់ទទួលយកសំពត់សង្ឃាដិរបស់លោកមកទ្រង់ ទ្រង់ប្រទានសំពត់សង្ឃាដិរបស់ព្រះអង្គទៅលោក ទ្រង់សរសើរលោកថា ជាអ្នកប្រតិបត្តិសល្លេខប្រាថ្នាតិច ប្រព្រឹត្តខ្លួនជាអ្នកថ្មីជានិច្ច មិនសំដែងសេចក្ដីស្និទ្ធស្នាលមិនរើសកាយវាចា មានចិត្តមិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយ ។ មួយ

វិញទៀត ព្រះអង្គទ្រង់ដំកើងលោកក្នុងដំណែងឯតទគ្គៈ គឺជាកំពូលនៃភិក្ខុទាំងឡាយ អ្នកទ្រទ្រង់ធុតង្គ ដោយប្រក្រតីលោកកាន់ធុតង្គ ៣ យ៉ាង គឺទ្រទ្រង់សំពត់បង្សុកូលជាវត្ត ១ កាន់ត្រេចបិណ្ឌបាតជាវត្ត ១ កាន់នៅព្រៃជាវត្ត ១ ទើបព្រះបរមសាស្តា ទ្រង់លើកដំកើងលោកខាងផ្លូវនេះ ។

ព្រះមហាកស្សបត្ថេរជាព្រះសាវ័កសំខាន់បំផុត គឺលោកធ្វើជាប្រធានក្នុងគ្រាធ្វើបឋមសង្គាយនា កាលព្រះពុទ្ធបរិនិព្វានទៅបាន ៧ ថ្ងៃ ដោយព្រោះឮដល់ពាក្យមើលងាយប្រមាថធម្មវិន័យ នៃសុភទ្ទវុឌ្ឍបព្វជិតជាដើមហេតុ ទើបលោកបបួលភិក្ខុសង្ឃធ្វើសង្គាយនា ព្រះសង្ឃក៏យល់ព្រម ទើបប្រគល់ឱ្យលោកជ្រើសរើសភិក្ខុដែលអាចធ្វើសង្គាយនា បានប្រមាណ ៥០០ អង្គ បានព្រះឧបាលិត្ថេរនឹងព្រះអានន្ទត្ថេរជាកំឡាំង ក្នុងការវិសជ្ជនាធម្ម-វិន័យ បានព្រះបាទអជាតសត្តុជាសាសនូបត្ថម្ភក៏ធ្វើនៅក្រុងរាជគ្រឹះ ៧ ខែទើបស្រេច ។ លុះធ្វើបឋមសង្គាយនាហើយព្រះមហាកស្សបត្ថេរក៏សម្រេចឥរិយាបថនៅក្នុងវត្តវេឡុវន លោកឧស្សាហ៍ប្រតិបត្តិមិនប្រមាទតាមឱវាទព្រះដ៏មានបុណ្យ ដល់កំណត់អាយុ ១២០ ឆ្នាំ ទើបរំលត់ខ័ន្ធចូលកាន់បរិនិព្វាន នាចន្លោះកណ្តាលភ្នំទាំង ៣ ដែលហៅថា កុក្កុដសម្បាតបព៌ត ។

## ១៧-ប្រវត្តិព្រះមហាកច្ចាយនត្ថេរ

ព្រះមហាកច្ចាយនត្ថេរនេះ ជាបុត្រព្រាហ្មណ៍បុរោហិតកច្ចាយនគោត្រនៅក្រុងឧជ្ជេនី ឈ្មោះកញ្ចនៈ ។ គាត់ចំរើនឡើង បានសិក្សារៀនសូត្រចេះចប់

ពេទ្យត្រៃវេទ កាលបិតាលោកអនិច្ចកម្មទៅ លោកក៏បានទទួលតំណែងបុរោហិតស្នងវង្សប័យ ព្រះបាទចន្ទប្បជ្ជោត ។

កាលព្រះបាទចន្ទប្បជ្ជោតបានទ្រង់ជ្រាបពត៌មានថា ព្រះពុទ្ធបានត្រាស់ក្នុងលោកហើយ ទ្រង់ទូន្មានមហាជន ធម៌ដែលទ្រង់សំដែងនោះជាធម៌ពិតពេញមិនអាចញ៉ាំងប្រយោជន៍ឱ្យសម្រេចដល់អ្នកប្រតិបត្តិតាមមិនមានព្រះរាជបំណងនិមន្តព្រះបរមសាស្ដាឱ្យស្ដេចទៅប្រកាសសាសនានៅក្រុងឧជ្ជេនី ទើបទ្រង់មានព្រះរាជឱង្ការនឹងកច្ចានបុរោហិតឱ្យទៅក្រាបទូលនិមន្តព្រះអង្គ ។ កច្ចានបុរោហិត ក្រាបទូលសុំបួសផងលុះទ្រង់ព្រះរាជានុញ្ញាតហើយ ទើបចេញដំណើរពីក្រុងឧជ្ជេនី ព្រមដោយបរិវារ ៧ នាក់ នាំគ្នាមកដល់ហើយក៏ចូលទៅគាល់ព្រះបរមសាស្ដា បានស្ដាប់ព្រះធម្មទេសនា បានសម្រេចព្រះអរហត្តទាំង ៨ នាក់ ទើបក្រាបទូលសុំឧបសម្បទ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ឱ្យបានជាភិក្ខុ ដោយវិធីឯហិភិក្ខុឧបសម្បទា ។ លុះលោកបានបួសហើយ ក្រាបទូលនិមន្តព្រះបរមសាស្ដា តាមព្រះរាជបំណងនៃព្រះបាទចន្ទប្បជ្ជោត ។ ព្រះដ៏មានបុណ្យមានព្រះបន្ទូលថា លោកទៅតែឯងចុះ កាលបើលោកត្រឡប់ទៅដល់ហើយ ព្រះបរមរាជានឹងទ្រង់ជ្រះថ្លា ។ ទើបលោកក្រាបថ្វាយបង្គំលានាំភិក្ខុជាបរិវារទាំង ៧ អង្គ ត្រឡប់ទៅក្រុងឧជ្ជេនីប្រកាសផ្សាយព្រះពុទ្ធសាសនាញ៉ាំងព្រះមហាក្សត្រនឹងអ្នកនគរទាំងឡាយឱ្យមានសេចក្ដីជ្រះថ្លា ហើយទើបត្រឡប់មកកាន់សំណាក់ព្រះបរមសាស្ដាវិញ ។

ព្រះមហាកច្ចាយនត្ថេរនេះ ឆ្លាតអធិប្បាយសេចក្ដីសង្ខេបឱ្យពិស្ដារទូល

ទូលាយ កាលព្រះបរមសាស្តាប្រថាប់នៅជេតវនមហាវិហារ ទ្រង់ត្រាស់ភទ្ទេកត្តេសូត្រ. កច្ចាយនសយ្យាលសូត្រ. ធាកាយនសូត្រ. នឹងបធុរសូត្រ ឱ្យជាឧប្បត្តិហេតុហើយ ទ្រង់តាំងលោកក្នុងដំណែងឯតទគ្គ គឺជាកំពូលនៃភិក្ខុទាំងឡាយ បែកខាងចែកអត្ថដែលទ្រង់សំដែងដោយសង្ខេបឱ្យដោយពិស្តារ ។ ក្រៅអំពីនេះនៅមានធម្មភាសិតដទៃទៀតរបស់ព្រះថេរៈ គឺមធុបិណ្ឌិកសូត្រ នឹងឧទ្ទេសវិភង្គសូត្រ ក្នុងគម្ពីរមជ្ឈិមនិកាយ ។

ព្រះមហាកច្ចាយនត្ថេរ មានរូបឆោមល្អ មានសម្បុរលឿងដូចជាមាសធម្មជាតិ ដូចមានសេចក្តីពោលក្នុងអដ្ឋកថាធម្មបទ សេចក្តីសង្ខេបថា សេដ្ឋីបុត្រស្រុកសោរេយ្យបានឃើញរូបលោកហើយ ក៏នឹកគិតថា បើបានភរិយាមានរូបឆោមល្អឆើត ដូចរូបលោកនេះ ការគាប់ប្រសើរណាស់ ដោយអំណាចបាបដែលប្រមាថនោះ សេដ្ឋីបុត្រនោះក៏ក្លាយភេទទៅជាស្ត្រី បានសេចក្តីអៀនខ្មាសក៏គេចចោលស្រុកទៅនៅស្រុកដទៃ សម័យក្រោយមកនាងបានសូមខមាទោសនឹងលោកទើបក្លាយជាភេទបុរសដូចមុនវិញ ។

បើបញ្ជាក់តាមដំណើររឿងក្នុងបធុរៈ បានសេចក្តីពោលទុកជាក់ច្បាស់ថា ព្រះមហាកច្ចាយនត្ថេរនេះជាព្រះថេរៈសំខាន់អង្គ ១ ក្នុងព្រះពុទ្ធសាសនាមានជន្មាយុមកដល់សម័យក្រោយនៃព្រះពុទ្ធបរិនិព្វាន ។

❋☆☆☆❋

# ១៨_ប្រវត្តិព្រះអជិតត្ថេរ

ព្រះអជិតត្ថេរជាបុត្រព្រាហ្មណ៍ក្នុងនគរសាវត្ថី កាលបើចំរើនវ័យផុតដល់ការសិក្សាហើយ ទើបមាតាបិតានាំយកទៅផ្ញើទុកនឹងព្រាហ្មណ៍ពាវរី · នេ គណាចារ្យធំ ។ លុះព្រះពុទ្ធជាម្ចាស់ទ្រង់ឧប្បត្តិឡើងក្នុងលោក មានព្រះគុណល្បីខ្ចរខ្ចាយផ្សាយទៅនានាជនបទ ។ ព្រាហ្មណ៍ពាវរី បានជ្រាបពតិមានចង់ដឹងសេចក្តីពិត ទើបប្រើមាណព ១៦ នាក់ ដែលជាសិស្សមានអជិតមាណពជាដើម ឱ្យទៅក្រាបបង្គំទូលសួរប្រស្នា ដើម្បីស៊ើបឱ្យដឹងការពិត ។ ទើបមាណព ១៦ នាក់នាំបរិវាររៀងៗខ្លួន ចូលទៅរកព្រះព្រះបរមសាស្តានៅតំបន់ពាសាណកចេតិយ ក្រាបទូលសុំព្រះឱកាសចូលសួរប្រស្នា កាលព្រះអង្គអនុញ្ញាតហើយ ទើបអជិតមាណពក្រាបទូលសួរប្រស្នាដំបូង ៤ ខដូច្នេះ :

លោកគឺពពួកសត្វ មានអ្វីបិទបាំងបានជាវង្វេងវិលវល់ ដូចនៅក្នុងទីងងឹត. ព្រោះអ្វីជាហេតុ ទើបមិនមានប្រាជ្ញាឃើញប្រាកដ. ព្រះអង្គត្រាស់ថាអ្វី ជាគ្រឿងលាបសត្វលោកឱ្យជាប់ជំពាក់នៅ. ហើយត្រាស់ថាអ្វី ជាភ័យធំនៃសត្វលោកនោះ ?

ព្រះបរមសាស្តាទ្រង់ព្យាករថា លោកគឺពពួកសត្វមានអវិជ្ជា (សេចក្តីល្ងង់ខ្លៅ) បិទបាំងទុក ទើបវង្វេងវិលវល់ដូចនៅក្នុងទីងងឹត. ព្រោះសេចក្តីព្រាថ្នា មានប្រការផ្សេងៗ នឹងសេចក្តីប្រមាទធ្វេសប្រហែស ទើបមិនបានប្រាជ្ញាឃើញប្រាកដ. តថាគតពោលថា សេចក្តីប្រាថ្នាជាគ្រឿងលាបរុំសត្វ

លោកឱ្យជាប់ជំពាក់នៅ. ហើយឥថាគតពោលថា សេចក្ដីទុក្ខជាភ័យធំនៃសត្វលោកនោះ ។

-ចុះអ្វីជាគ្រឿងហាមជាគ្រឿងរាំងសេចក្ដីប្រាថ្នាប៊ីដូចខ្សែទឹក ដែលរៀហូរចូលទៅក្នុងអារម្មណ៍ទាំងពួង ចុះសេចក្ដីប្រាថ្នានោះ បុគ្គលនឹងលះចេញបានព្រោះធម៌អ្វី ?

-សតិជាគ្រឿងហាម ជាគ្រឿងរាំង សេចក្ដីប្រាថ្នា ហើយសេចក្ដីប្រាថ្នានេះបុគ្គលនឹងលះចេញបាន ព្រោះបញ្ញា ។

-បញ្ញា សតិនិងនាមរូបនោះតើរលត់ផាត់ទៅក្នុងទីណា ?

ព្រោះវិញ្ញាណរលត់ទៅមុន ទើបនាមរូបរលត់នៅក្នុងទីនោះឯង ។

-ជនអ្នកមានធម៌បានពិចារណាឃើញហើយ នឹងជនដែលនៅសិក្សានៅឡើយ ជនពីរចំពូកនេះមាននៅក្នុងលោក. ទូលព្រះបង្គំជាខ្ញុំសូមក្រាបទូលសួរអំពីសេចក្ដីប្រព្រឹត្តិនៃជនពីរពួកនេះ ?

-ភិក្ខុមានធម៌បានពិចារណាឃើញហើយ នឹងជនដែលនៅសិក្សានៅឡើយ ត្រូវជាអ្នកមិនត្រេកត្រអាលក្នុងកាមទាំងឡាយ មានចិត្តមិនកករល្អក់ឈ្លាសវៃក្នុងធម៌ទាំងពួង មានស្មារតីគ្រប់ឥរិយាបថ ។

ក្នុងវេលាចប់បញ្ហាព្យាករណ៍ អជិតមាណពបានសម្រេចអរហត្ត ព្រមដោយចតុប្បដិសម្ភិទាញាណ ។

លុះព្រះបរមសាស្ដា ទ្រង់ដោះស្រាយប្រស្នារបស់មាណព ១៥ នាក់ទៀតចប់ស្រេចហើយ ទើបក្រាបទូលសុំឧបសម្បទ ។ ព្រះដ៏មានបុណ្យទ្រង់

# ពាក្យប្រារព្ធ

ប្រវត្តិសាស្ត្រជារឿងមានសារៈរបស់ប្រទេសជាតិ សម្រាប់បំភ្លឺពន្យល់ឱ្យយើងបានឃើញបានដឹង ហេតុភេទនិងរឿងរ៉ាវផ្សេងៗ ក្នុងអតីតកាល ។ ឯការសិក្សាអនុពុទ្ធប្បវត្តិ គឺរឿងរ៉ាវរបស់ព្រះសាវ័កនេះក៏ជាការជួយណែនាំឱ្យយើងបានដឹងចរិយា និងអាចារៈប្រការខ្លះ របស់ព្រះសាវ័កអង្គនោះៗ សម្រាប់ជាទិដ្ឋានុគតិ របស់ពុទ្ធសាសនិកជនទូទៅទាំងគ្រហស្ថទាំងបព្វជិត ។ ព្រះមហាសាវ័កទាំងឡាយ របស់ព្រះពុទ្ធជាអម្ចាស់ លោកបានបំពេញកិច្ចយ៉ាងសំខាន់របស់លោក គឺការប្រកាសផ្សាយធម្មវិន័យ ដើម្បីជាប្រយោជន៍និងសេចក្ដីសុខដល់មហាជន ចាត់ជាបុព្វការីរបស់ពុទ្ធសាសនិកជនទាំងឡាយបន្ទាប់អំពីព្រះបរមសាស្ដាចុះមក ។

រឿងអនុពុទ្ធប្បវត្តិនេះ ខ្ញុំបានបោះពុម្ពផ្សាយម្ដងរួចមកហើយ កាលពីខែមករា ឆ្នាំ ១៩៥០ ប៉ុន្តែធ្វើជាភាគតូចៗ ក្នុងភាគដំបូងមានប្រវត្តិព្រះសាវ័កចំនួន ១៨ អង្គប៉ុណ្ណោះ ។ មានអស់លោកអ្នកសិក្សាខាងផ្លូវសាសនាត្រូវការចង់បានច្រើន ហើយចង់ឱ្យធ្វើជាសៀវភៅធំតែមួយ មិនចង់ឱ្យបែងវែលកជាភាគតូចៗដូចមុនទៀត ដើម្បីសម្រួលដល់ការសិក្សាផង ដល់ការទុកដាក់ផង ។ ហេតុដូច្នេះ ក្នុងឱកាសបោះពុម្ពលើកទីពីរនេះ ខ្ញុំប្រមូលរឿងរ៉ាវព្រះមហាសាវ័កទាំងឡាយបានចំនួន ៦៥ អង្គ រួបរួមទុកក្នុងសៀវភៅតែមួយនេះ ។

ប្រវត្តិព្រះមហាសាវ័កទាំងឡាយ ក្នុងគម្ពីរនានាទាំងបាលីទាំងអដ្ឋកថា មិនបានពោលរឿងរ៉ាវរបស់លោក ដោយពិស្តារគ្រប់ៗ អង្គទេ ពោលត្រួសៗតាម រឿងហួរហែតាំងពីមុនចូលបួស អង្គខ្លះបានប្រវត្តិត្រឹមតែពេលមកបួស ហើយ ថែមទាំងមិនបានចូលរួបរួមទុកក្នុងទីជាមួយគ្នាផង ។ ក្រៅពីនេះទៀត គម្ពីរនោះៗ ច្រើនពោលអាងដល់ប្រវត្តិបុព្វកម្មរបស់លោកច្រើនជាងប្រវត្តិក្នុង បច្ចុប្បន្ន ។ ឯអនុពុទ្ធប្បវត្តិដែលខ្ញុំបានរួបរួមឡើងនេះ ផ្ដើមរៀបរាប់ចំពោះ ប្រវត្តិក្នុងបច្ចុប្បន្ន ហើយដោយសង្ខេបផង ។

ក្នុងទីបំផុតនេះ ខ្ញុំមានសង្ឃឹមថា ការរៀបរៀងអនុពុទ្ធប្បវត្តិសង្ខេប នេះ គង់និងសម្រេចប្រយោជន៍ ដល់កុលបុត្រអ្នកសិក្សាពេទ្ធវិន័យបានខ្លះ ជា កិច្ចជួយពង្រីកការសិក្សាព្រះសាសនា ជាតិភាសាជាតិឱ្យកាន់តែកើនចំរើនឡើង បានខ្លះផង ។ ខ្ញុំសូមអភ័យទោស អស់លោកវិញ្ញូជន ប្រសិនបើការរៀបរៀង អនុពុទ្ធប្បវត្តិនេះ នៅមានភ្លាំងភ្លាត់ខ្លះត្រង់សេចក្ដីឬអក្ខរាវិរុទ្ធ សូម មេត្តាជួយកែតម្រង់ឱ្យទានផង ។

ហួងនិពន្ធមន្ត្រី

ញ៉ុក-ថែម

ខែកក្កដា ឆ្នាំ ១៩៥០

ប្រទានឯហិភិក្ខុឧបសម្បទាឱ្យជាភិក្ខុក្នុងពុទ្ធសាសនា ។ ព្រះអជិតត្ថេរនេះរាប់បញ្ចូលក្នុងពួករបស់ពីមហាសាវកព្រះអង្គមួយ មានជន្មាយុសមគួរនឹងកាលវេលាដែលកើតកំណើតមិញ្ញារ ។

# ១៩~ប្រវត្តិព្រះតិស្សមេត្តេយ្យត្ថេរ

ព្រះតិស្សមេត្តេយ្យត្ថេរនេះ ជាបុត្រព្រាហ្មណ៍ម្នាក់ នៅក្រុងសាវត្ថី កាលបានវ័យចំរើនឡើង ដល់ការសិក្សាហើយ បានចេញទៅរៀនវេទក្នុងសំណាក់ព្រាហ្មណ៍ពាវរី ដែលធ្លាប់ធ្វើជាមហាបុរោហិតនៃព្រះបាទកោសលរាជ ហើយតបកសម័យក្រោយ មានសេចក្ដីនឿយណាយក្នុងឃរាវាស ទើបក្រាបបង្គំទូលសូមព្រះរាជានុញ្ញាតលាទៅបួសប្រព្រឹត្តវត្តតាមលទ្ធិព្រាហ្មណ៍ តាំងអាស្រមនាឆ្នេរស្ទឹងគោធាវរី ជាទីព្រំប្រទល់នៃស្រុកអស្សកៈ និងអាឡ្យកៈ ជាគណាចារ្យធំក្នុងសម័យនោះ ។

លុះព្រះពុទ្ធជាម្ចាស់ទ្រង់ឧប្បត្តិឡើងក្នុងលោកហើយ មានព្រះកិត្តិស័ព្ទល្បីខ្ចរខ្ចាយសាយចេញទៅក្នុងទិសានុទិស ។ ព្រាហ្មណ៍ពាវរីបានជ្រាបពត៌មាន មានសេចក្ដីជឿងឆ្ងល់សង្ស័យចង់ដឹងការពិត ទើបតែងជាបញ្ហា ១៦ វត្ថុឱ្យមាណព ១៦ នាក់ជាសិស្សរបស់ខ្លួនក្នុងម្នាក់មួយវត្ថុ១ នាំយកទៅក្រាបទូលសួរព្រះបរមគ្រូល្បងមើល ។ ឯតិស្សមេត្តេយ្យមាណពក៏នៅក្នុងចំនួននេះដែរ នាំគ្នាលាអាចារ្យនាំបរិវាររៀង១ ខ្លួនចូលទៅក្រាបបង្គំគាល់ព្រះបរមគ្រូ ឯបាសាណចេតិយដែនមគធរដ្ឋ ក្រាបបង្គំទូលសូមព្រះឱកាសសួរ

អរហត្ត ព្រមដោយបដិសម្ភិទាញាណ ។ លុះពេលពាវរីទៅទៀតក្រាបទូលសួរបញ្ហារៀង១ ខ្លួនរួចហើយ ទើបតិស្សមេត្តេយ្យមាណពព្រមទាំងមាណពជាសិស្សអាចារ្យ នាំគ្នាក្រាបបង្គំទូលសូមបព្វជ្ជាឧបសម្បទា ព្រះដ៏មានបុណ្យក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា។ ព្រះតិស្សមេត្តេយ្យត្ថេរ មានជន្មាយុសមគួរដល់កាលកំណត់ហើយ ក៏រំលត់ខ័ន្ធចូលកាន់បរិនិព្វាន។

## ២០-ប្រវត្តិព្រះបុណ្ណកត្ថេរ

ព្រះបុណ្ណកត្ថេរ ជាបុត្រព្រាហ្មណ៍ម្នាក់ក្នុងនគរសាវត្ថី កាលបានវ័យចំរើនហើយក៏បានទៅនៅសិក្សាលទ្ធិ ក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលតិស្សមេត្តេយ្យមាណពបានក្រាបទូលសួរប្រស្នា បានស្តាប់ព្រះធម្មទេសនា សម្រេចអរហត្តហើយ ទើបបុណ្ណកមាណពក្រាបទូលសួរប្រស្នាជាគំរប់ ៣ សេចក្តីថា :

ពពួកមនុស្សក្នុងលោកនេះ អាស្រ័យអ្វី ទើបនាំគ្នាបូជាយ័ញ្ញបន់ស្រន់ទេព្តា?

ព្រះពិជិតមារទ្រង់ព្យាករណ៍ថា ពពួកមនុស្សទាំងនោះចង់បានរបស់ដែលខ្លួនប្រាថ្នា អាស្រ័យរបស់មានជរាទ្រុឌទ្រោមទៅ (ជាធម្មតា) ទើបនាំគ្នាបូជាយ័ញ្ញបន់ស្រន់ទេព្តា ។

-ពពួកមនុស្សទាំងនោះ ប្រសិនបើមិនប្រមាទក្នុងយ័ញ្ញរបស់ខ្លួន តើ

---

១-មានដំណើរសេចក្តីហួរហែ ដូចក្នុងប្រវត្តិព្រះតិស្សមេត្តេយ្យត្ថេរខាងលើនេះ ។

អាចនឹងឆ្លងជាតិនឹងជរាទៅបានឬទេ ?

-ពពួកមនុស្សទាំងនោះ ប៉ុនប៉ងចង់បានលាភៈដែលខ្លួនប្រាថ្នា ទើបពោលសរសើរការបូជាយ័ញ្ញ ពោលដំកើងតែរបស់ដែលខ្លួនប្រាថ្នាដូច្នេះ ក៏ព្រោះអាស្រ័យលាភ. តថាគតពោលថាអ្នកបូជាយ័ញ្ញទាំងនោះ នៅមានសេចក្ដីត្រេកត្រអាល នឹងឆ្លងឱ្យផុតចាកជាតិជរាទៅមិនបានឡើយ ។

-ចុះបើអ្នកបូជាយ័ញ្ញទាំងនោះ នឹងឆ្លងឱ្យផុតចាកជាតិជរា ព្រោះយ័ញ្ញរបស់ខ្លួនមិនបានទេ. ដូច្នេះតើ អ្នកណាមួយក្នុងទេវលោកឬក្នុងមនុស្សលោក អាចឆ្លងឱ្យផុតចាកជាតិជរានោះទៅបាន ?

-ចំណង់ឬសេចក្ដីប្រាថ្នា ដ៏ជាហេតុរអួះរអ្វេងក្រវល់ក្រវាយក្នុងលោកណាមួយ របស់បុគ្គលណាមិនមាន ព្រោះបានពិចារណាឃើញច្បាស់នូវធម៌តឹងនឹងធូរក្នុងលោក. តថាគតពោលថា អ្នកនោះឯងជាអ្នកស្ងប់រម្ងាប់ហើយ មិនមានទុច្ចរិតសេចក្ដីប្រព្រឹត្តិអាក្រក់ ដែលធ្វើឱ្យសៅហ្មង ដូចផ្សែងភ្លើងចាប់ខ្មៅ. មិនមានកិលេសប៉ះពាល់ដល់ចិត្ត ឥតសេចក្ដីប្រាថ្នាក្រវល់ក្រវាយ. ទើបអាចឆ្លងផុតចាកជាតិជរាទៅបាន។

កាលបុណ្ណកមាណពបញ្ចូនចិត្តទៅតាមក្រសែព្រះធម្មទេសនា ក៏បានសម្រេចអរហត្តព្រមទាំងចតុប្បដិសម្ភិទាញាណ ហើយបានក្រាបទូលសូមបព្វជ្ជាឧបសម្បទា .ជាមួយនឹងពួកមាណពជាសមានាចារ្យក្នុងវេលាចប់សោឡសបញ្ហាព្យាករណ៍ ។

ព្រះបរមសាស្ដាក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា។

ព្រះបុណ្ណកត្ថេរ មានព្រះជន្មាយុក្នុងព្រះសាសនា តាមសមគួរដល់កាល កំណត់ហើយ ក៏រំលត់ខ័ន្ធចូលកាន់បរិនិព្វាន ។

# ២១_ប្រវត្តិព្រះមេត្តគូត្ថេរ

ព្រះមេត្តគូត្ថេរ ជាបុត្រព្រាហ្មណ៍ត្រកូល ១ ក្នុងនគរសាវត្ថី កាលមាន វ័យចាស់ធំចំរើនឡើង បានទៅនៅសិក្សាលទ្ធិក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលបុណ្ណកមាណពក្រាបទូលសួរប្រស្នាបានស្ដាប់ព្រះធម្មទេសនាសម្រេច អរហត្តហើយ ទើបមេត្តគូមាណពក្រាបទូលសួរ ប្រស្នាជាគំរប់ ៤ តទៅថា

បពិត្រព្រះអង្គដ៏ចំរើន. ទុក្ខក្នុងលោកនេះ មានច្រើនប្រការ មិនមែន មានតែមួយទេ ចុះមកអំពីអ្វីហ្ន៎ ?

ព្រះបរមគ្រូទ្រង់ព្យាករថា ទុក្ខក្នុងលោកនេះ មានឧបធិ គឺកម្មនិង កិលេសជាហេតុ កើតមកអំពីឧបធិជាមុន. ជនណាមួយល្ងង់ខ្លៅមិនដឹងហើយ ធ្វើ ឧបធិនេះឱ្យកើតឡើង. ជននោះឯងតែងបានទទួលទុក្ខក្នុងលោកនេះ ហេតុ នេះ កាលបើដឹងឃើញច្បាស់ថា ឧបធិជាដើមធម៌នៃទុក្ខ កុំធ្វើ (ឧបធិ) ឱ្យកើតឡើងឡើយ ។

-អ្នកមានប្រាជ្ញា នឹងឆ្លងអន្លង់សមុទ្រធំ គឺជាតិ ជរា សោកបរិទេវៈឱ្យ ផុតទៅបានដូចម្ដេច ? សូមព្រះអង្គទ្រង់ សំដែងខនេះដល់ខ្ញុំព្រះអង្គ ។

-តថាគតនឹងសំដែងធម៌ ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯងក្នុង អត្តភាពនេះ មិនបាច់ជឿងេងងោងទៅតាមពាក្យអ្នកដទៃថា គឺយ៉ាងនេះ។.

ជាអ្នកកោនស្មារតី ធ្វើជំពេកិរន្តរសេចក្ដីក្រាក្នា ដែលកេរ៉ាក្បៀជាប់ជិ កេក្នុងលោក ចេញ ដល់អ្នក ។

-ខ្ញុំព្រះអង្គត្រេកអរប៉ែងធម៌ដ៏ខ្ពង់ខ្ពស់នេះយ៉ាងក្រៃលែង ។

-អ្នកដឹងហ៊ាងណាមិមួយ ក្នុងចំណែកខាងលើ (គឺអនាគត), ក្នុងចំណែកខាងក្រោម (គឺអតីត) ក្នុងចំណែកពាក់កណ្ដាល (គឺបច្ចុប្បន្ន), ចូរបន្ទោបង់សេចក្ដីរីករាយ, សេចក្ដីប្រកាន់ខាំ, ក្នុងចំណែកអស់នោះចេញ វិញ្ញាណរបស់អ្នកនឹងមិនឋិតនៅក្នុងភព, ភិក្ខុអ្នកមានវិហារធម៌យ៉ាងនេះ មានសតិ មិនធ្វេសប្រហែស, បានដឹងហើយតែងលះបង់នូវសេចក្ដីប្រកាន់ថារបស់អញចេញបានហើយ ក៏នឹងលះបង់នូវទុក្ខ គឺជាតិ ជរា សោកបរិទេវៈ ក្នុងលោកនេះចេញបាន ។

-ខ្ញុំព្រះអង្គគាប់ចិត្តនឹងព្រះវាចារបស់ព្រះអង្គយ៉ាងក្រៃលែង, ធម៌មិនមានឧបធិ ព្រះអង្គទ្រង់សំដែងប្រពៃហើយ ព្រះអង្គទ្រង់លះបង់នូវទុក្ខបានមែន ព្រោះព្រះអង្គទ្រង់បានជ្រាបនូវធម៌នេះហើយ សូម្បីលោកអ្នកចេះដឹងដែលព្រះអង្គទ្រង់បានទូន្មានជានិច្ច ក៏គង់លះទុក្ខនេះបាន

ហេតុនេះទើបខ្ញុំព្រះអង្គចូលមកក្រាបថ្វាយបង្គំគាល់ ដើម្បីព្រះអង្គទូន្មានប្រដៅខ្ញុំព្រះអង្គជានិច្ចដូច្នោះផង ?

អ្នកដឹងថា ជនណាជាព្រាហ្មណ៍ ដល់ទីបំផុតចប់ត្រៃវេទ, មិនមានកិលេសជាគ្រឿងកង្វល់ មិនជាប់នៅក្នុងកាមភព, អ្នកនោះឯង ឆ្លងអន្លង់ជុតហេតុនៃទុក្ខ ដូចអន្លង់សមុទ្រធំនេះបាន . លុះឆ្លងដល់ត្រើយហើយ ជាអ្នកមិន

ហានកិលេសជាគ្រឿងរួបរិតចិត្ត. ផុតសេចក្តីសង្ស័យ អ្នកនោះ លុះចេះចប់ត្រៃវេទក្នុងសាសនានេះហើយ តែងលះបង់នូវធម៌ ដែលជាហេតុឱ្យជាប់នៅក្នុងភពតូច-ធំចេញបានហើយ. ជាអ្នកអស់សេចក្តីប្រាថ្នាហើយ. មិនមានកិលេសខ្លាំងខ្ទប់ចិត្ត. ឥតចំណង់អន្ទះអន្ទែង តថាគតពោលថា អ្នកនោះឯងបានឆ្លងផុតជាតិទៅបានហើយ ។

ក្នុងទីបំផុតនៃបញ្ហាព្យាករណ៍ មេត្តគូមាណពបានសម្រេចអរហត្តព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបបង្គំទូលសូមបព្វជ្ជាឧបសម្បទាជាមួយនឹងពួកមាណពជាសហាយមាណព ក្នុងវេលាចប់សោឡសបញ្ហាព្យាករណ៍ ។ សម្តេចព្រះដ៏មានបុណ្យក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុដោយឯហិភិក្ខុឧបសម្បទា។ ព្រះមេត្តគុត្ថេរមានជន្មាយុក្នុងព្រះសាសនា សមគួរដល់កាលកំណត់ហើយ ក៏រំលត់ខន្ធចូលកាន់បរិនិព្វាន ។

## ២២-ប្រវត្តិព្រះធោតកត្ថេរ

ព្រះធោតកត្ថេរ កើតក្នុងត្រកូលព្រាហ្មណ៍ ១ ក្នុងក្រុងសាវត្ថី កាលមានវ័យចាស់ធំចំរើនឡើង មាតាបិតាបាននាំយកទៅផ្ញើទុក ឱ្យរៀនសូត្រក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលមេត្តគូមាណព ក្រាបទូលសួរប្រស្នា បានស្តាប់ធម្មទេសនាសម្រេចអរហត្តហើយ ទើបធោតកមាណពក្រាបទូលសួរប្រស្នាជាគំរប់ ៥ ទៅថា :

ខ្ញុំព្រះអង្គសូមក្រាបទូលសួរ សូមព្រះអង្គត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គ ។

ចង់ស្ដាប់សព្ទព្រះវាចារបស់ព្រះអង្គ. ខ្ញុំព្រះអង្គបានស្ដាប់ព្រះបន្ទូលព្រះអង្គ ហើយ នឹងសិក្សាប្រតិបត្តិជាគ្រឿងរំលត់បង់នូវកិលេសរបស់ខ្លួន ។

ព្រះបរមសាស្ដាទ្រង់ព្យាករណ៍ថា បើដូច្នេះចូរអ្នកជាមនុស្សមានប្រាជ្ញា នឹងស្មារតី បំពេញសេចក្ដីព្យាយាមក្នុងសាសនានេះចុះ ។

-ខ្ញុំព្រះអង្គបានយល់ឃើញថា ព្រះអង្គជាព្រាហ្មណ៍គ្មានកង្វល់ត្រេចទៅក្នុងទេវលោក នឹងមនុស្សលោក. ហេតុដូច្នេះ ទើបខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំព្រះអង្គ សូមទ្រង់ព្រះមេត្តាប្រោស ដោះខ្ញុំព្រះអង្គចេញចាកសេចក្ដីសង្ស័យផងចុះ ។

-តថាគតនឹងដោះជនណាមួយក្នុងលោកដែលនៅមានសេចក្ដីសង្ស័យ មិនបានទេ. កាលបើអ្នកបានដឹងធម៌ដ៏ប្រសើរដោយខ្លួនឯង. ទើបអ្នករារកនឹងឆ្លងផុតអន្លង់សមុទ្រធំ គឺកិលេសចេញបានដោយខ្លួនឯង ។

-សូមព្រះអង្គទ្រង់ព្រះករុណា ប្រោសសំដែងធម៌ ដែលស្ងប់រម្ងាប់ចាកកិលេស ដែលខ្ញុំព្រះអង្គគប្បីដឹងបាន. ទ្រង់ទូន្មានប្រដៅខ្ញុំព្រះអង្គទៅជាមនុស្សមិនជាប់ជំពាក់ ជ្រះស្រឡះដូចជាអាកាស. រម្ងាប់កិលេស មិនមានអាស្រ័យអ្វីនីមួយត្រេចទៅក្នុងលោក ។

-តថាគតនឹងប្រាប់ឧបាយជាគ្រឿងរម្ងាប់កិលេស ដ៏ខ្ពង់ខ្ពស់នេះយ៉ាងក្រៃលែង ។

-បើអ្នកដឹងថា សេចក្ដីប្រាថ្នាអន្ទះអន្ទែងទាំងភាគលើទាំងភាគខាងក្រោមទាំងភាគកណ្ដាល. ជាហេតុឱ្យជាប់នៅក្នុងលោក. អ្នកកុំធ្វើសេចក្ដី

ប្រាថ្នាអនុះអន្ទែង ដើម្បីទៅកើតក្នុងភពតូច-ធំ (តទៅទៀត) ។

វេលាចប់បញ្ហាព្យាករណ៍នេះ ធោតកមាណពបានសម្រេចអរហត្តព្រមទាំងចតុប្បដិសម្ភិទាញាណហើយក្រាបបង្គំទូលសូមឧបសម្បទ ។ ព្រះអង្គក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុដោយឯហិភិក្ខុឧបសម្បទា ជាមួយនឹងពួកមាណពទាំងនោះ ក្នុងខណៈចប់សោឡសបញ្ហាព្យាករណ៍ ។ ព្រះធោតកត្ថេរមានព្រះជនាយុក្នុងព្រះសាសនាសមគួរដល់កាលកំណត់ហើយ ក៏រំលត់ខ័ន្ធចូលកាន់បរិនិព្វាន ។

## ២៣ ប្រវត្តិព្រះឧបសីវត្ថេរ

ព្រះឧបសីវត្ថេរ កើតក្នុងត្រកូលព្រាហ្មណ៍ ១ ឯនគរសាវត្ថី ក្នុងកោសលជនបទ កាលចំរើនវ័យធំឡើង បានទៅសិក្សាលទ្ធិក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលធោតកមាណពក្រាបទូលសួរប្រស្នាបានស្តាប់ព្រះធម្មទេសនាសម្រេចអរហត្តហើយ ទើបឧបសីវមាណពក្រាបទូលសួរប្រស្នាជាគំរប់ ៦ តទៅថា :

ទំនើងខ្ញុំព្រះអង្គម្នាក់ឯង មិនបានអាស្រ័យអ្វីទេ មិនអាចឆ្លងអន្លង់សមុទ្រធំ គឺកិលេសបានឡើយ. សូមព្រះអង្គត្រាស់ប្រាប់អារម្មណ៍សម្រាប់ចាប់តោង ដែលខ្ញុំព្រះអង្គអាចអាស្រ័យឆ្លងអន្លង់នេះទៅបានដល់ខ្ញុំព្រះអង្គ ?

ព្រះសម្ពុទ្ធទ្រង់ព្យាករថា ចូរអ្នកមានសតិពិនិត្យ អាកិញ្ចញ្ញាយតនជ្ឈានអាស្រ័យអារម្មណ៍ថា មិនមានអ្វីៗ ដូច្នេះឆ្លងអន្លង់ទៅ. ចូរអ្នកលុះតាមទាំង

ឲ្យឃេញ. ជាអ្នកវៀរចាកសេចក្ដីសង្ស័យ. ហើយធ្វើព្រហ្មចរិយៈជាទីរស់នៅរបស់ខ្លួន ទាំងយប់ទាំងថ្ងៃ ។

-ជនណាប្រាសចាកតម្រេកក្នុងកាមទាំងឡាយហើយ. កន្លងឈានដទៃបានហើយ. អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន (គឺការពិនិត្យសំឡឹងខាងផ្លូវចិត្តថា "មិនមានអ្វី" ជាអារម្មណ៍) បង្អោនចិត្តទៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានដែលជាធម៌សម្រាប់ដកចេញនូវសញ្ញាយ៉ាងប្រសើរៈ តើអ្នកនោះនឹងឋិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ មិនសាបសូន្យខ្លះទេឬ ?

-អ្នកនោះនឹងឋិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានមិនសាបសូន្យទេ ។

-បើអ្នកនោះនឹងឋិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈានអស់ឆ្នាំដ៏ច្រើនបុគ្គលនោះជាអ្នកខ្ជាប់ខ្ជួនក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ ឬមួយនឹងរំលត់ខ័ន្ធបរិនិព្វានទៅ តើវិញ្ញាណរបស់អ្នកនោះ នឹងទៅជាដូចម្ដេចវិញ ?

-អណ្ដាតភ្លើងដែលត្រូវខ្យល់បក់ហើយរលត់ទៅ មិនគួររាប់ថាបានទៅហើយក្នុងទិសតំបន់ណា មានឧបមាយ៉ាងណា. វិញ្ញូជនដែលផុតទៅហើយចាកកងនាមរូប រមែងរលត់ទៅមិនមានសេសសល់ (គឺរំលត់ព្រមទាំងកិលេសទាំងខ័ន្ធ) មិនគួររាប់ថា បានទៅកើតជាអ្វី មានឧបមេយ្យដូច្នោះដែរ ។

-តើបុគ្គលនោះរលត់ទៅហើយ ឬគ្រាន់តែមិនមានរូប ឬជាអ្នកឋិតទៅខ្ជាប់ខ្ជួនមិនមានអន្តរាយ. សូមព្រះអង្គទ្រង់ព្យាករណ៍សេចក្ដីនេះដល់ខ្ញុំព្រះអង្គ ព្រោះថាធម៌នេះ ព្រះអង្គទ្រង់ជ្រាបជាក់ច្បាស់ហើយ ?

ប្រមាណនៃបញ្ចខ័ន្ធ របស់អ្នករលត់ខ័ន្ធចូលកាន់និព្វានទៅហើយ មិន

មានកិលេសដែលជាហេតុពោលអំពីអ្នកនោះថា បានទៅកើតជាអ្វី កាលបើធម៌ទាំងឡាយ ( មានខ័ន្ធជាដើម) ដែលបុគ្គលនោះ ក៏ចាកចេញរលស់ហើយ ក៏ឈ្មោះថាផ្តាច់សំដី ដែលត្រូវនិយាយដល់អ្នកនោះថាជាអ្វីទាំងអស់ ។

វេលាចប់បញ្ហាព្យាករណ៍ ឧបសីវមាណពឋិតនៅក្នុងអរហត្តផល ហើយក្រាបបង្គំទូលសូមឧបសម្ប័ទ ។ ព្រះអង្គទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទាជាមួយនឹងពួកមាណពទាំងនោះ ក្នុងកាលចប់សោឡសបញ្ហាព្យាករណ៍ ។ ព្រះឧបសីវត្ថេរ មានជន្មាយុក្នុងព្រះសាសនា សមគួរដល់កាលកំណត់ហើយ ក៏បរិនិព្វាន ។

# ២៤~ប្រវត្តិព្រះនន្ទកត្ថេរ

ព្រះនន្ទកត្ថេរ ជាបុត្រព្រាហ្មណ៍ម្នាក់ ក្នុងក្រុងសាវត្ថី កាលមានវ័យធាត់ធំចំរើនឡើង បានទៅសិក្សាលទ្ធិព្រាហ្មណ៍ ក្នុងសំណាក់ពាវរី ។ល។

កាលឧបសីវមាណពក្រាបទូលសួរប្រស្នាបានស្តាប់ព្រះធម្មទេសនាសម្រេចអរហត្តហើយ ទើបនន្ទកមាណពក្រាបទូលសួរប្រស្នាជាគំរប់ ៧ តទៅថា:

ជនទាំងឡាយពោលថា "មុនី" មាននៅក្នុងលោកដូច្នេះ. ខនេះតើដូចម្តេច. គេហៅថាមនុស្សប្រកបដោយញាណ. ឬប្រកបដោយការចិញ្ចឹមជីវិតថាជាមុនី ។

ព្រះសម្ពុទ្ធទ្រង់ព្យាករថា អ្នកឆ្លាតក្នុងលោកនេះ មិនបានពោលថា មនុស្សដែលជាមុនី ដោយយោបល់ឃើញ. ឬដោយការស្តាប់ឬណាយ

[illegible]

ចំណេះចេះដឹងនោះទេ តថាគតពោលថា ជនណាធ្វើខ្លួនឱ្យប្រាសចាកគងកិលេស ជាអ្នកឥតកិលេស. មិនមានតណ្ហា គឺសេចក្តីប្រាថ្នាអន្ទះអន្ទែង. ជននោះឯង ឈ្មោះជាមុនី ។

-សមណព្រាហ្មណ៍ឯណាមួយ ពោលសេចក្តីបរិសុទ្ធិ ដោយការយល់. ដោយការស្តាប់. ដោយសីលនឹងវត្ត នឹងដោយវិធីដទៃទៀតជាច្រើន. តើសមណព្រាហ្មណ៍ទាំងនោះប្រព្រឹត្តតាមវិធីទាំងនោះ ដែលខ្លួនយល់ថាជាគ្រឿងបរិសុទ្ធិ. អាចឆ្លងជាតិជរាបានខ្លះដែរឬទេ ? -ខ្ញុំព្រះអង្គសូមក្រាបទូលសួរ សូមព្រះអង្គត្រាស់សំដែងសេចក្តីនេះ ដល់ខ្ញុំព្រះអង្គ ។

-សមណព្រាហ្មណ៍ទាំងនោះ ទោះបីបានប្រព្រឹត្តដូច្នោះក៏ដោយតថាគតពោលថាឆ្លងឱ្យផុតជាតិជរាទៅមិនបានឡើយ ។

-ប្រសិនបើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះ ឆ្លងអន្លង់ទៅមិនបានទេ. បើដូច្នេះតើ នរណាមិញ ក្នុងមនុស្សលោកឬក្នុងទេវលោក អាចឆ្លងឱ្យផុតចាកជាតិជរាទៅបាន ។

-តថាគតមិនបានពោលថា សមណព្រាហ្មណ៍ទាំងឡាយ មានជាតិជរាគ្របសង្កត់ហើយគ្រប់ៗ គ្នាទេ. ប៉ុន្តែតថាគតពោលថា ពួកសមណព្រាហ្មណ៍ណាក្នុងលោកនេះ បានលះបង់អារម្មណ៍ដែលខ្លួនបានឃើញបានស្តាប់បានដឹង នឹងសីលវត្ត ព្រមទាំងវិធីជាច្រើនចេញអស់ហើយ. កំណត់ដឹងនូវតណ្ហាថាជាទោសគួរលះបង់បានហើយ. ជាអ្នកមិនមានអាសវៈ. សមណព្រាហ្មណ៍ទាំងនោះឯង ឆ្លងអន្លង់បានហើយ ។

-ខ្ញុំព្រះអង្គគាប់ចិត្តនឹងព្រះវាចារបស់ព្រះអង្គពេកណាស់. សូមព្រះអង្គទ្រង់សំដែងធម៌ដែលមិនមានឧបធិ (កិលេស) ប្រពៃហើយ. សូម្បីខ្ញុំព្រះអង្គ, ក៏ពោលថា សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកឆ្លងអន្លង់ផុតទៅហើយ ដូចព្រះអង្គត្រាស់ដែរ ។

វេលាចប់បញ្ហាព្យាករណ៍ ននកមាណពបានសម្រេចអរហត្តព្រមដោយចតុប្បដិសម្ភិទាញាណ ទើបក្រាបបង្គំទូល សូមបព្វជ្ជាឧបសម្បទា ។ សម្តេចព្រះបរមសាស្តាក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ជាមួយនឹងពួកមាណពជាសហការនាចារ្យ ក្នុងទីបំផុតនៃសោឡសបញ្ហាព្យាករណ៍ ។ ព្រះននកត្ថេរ មានជន្មាយុក្នុងព្រះសាសនា តាមសមគួរដល់កាលកំណត់ ហើយ ក៏បរិនិព្វានទៅ ។

# ២៥-ប្រវត្តិព្រះហេមកត្ថេរ

ព្រះហេមកត្ថេរ ជាបុត្រព្រាហ្មណ៍ត្រកូលមួយ នៅក្រុងសាវត្ថី កាលចំរើនវ័យធំឡើង បានចេញទៅសិក្សាលទ្ធិក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលននកមាណពបានក្រាបបង្គំទូលសួរប្រស្នាបានស្តាប់ព្រះធម្មទេសនាសម្រេចអរហត្តហើយ ទើបហេមកមាណពក្រាបទូលសួរប្រស្នាជាគំរប់ ៨ សេចក្តីថា:

ក្នុងសម័យមុនព្រះសាសនារបស់ព្រះអង្គ អាចារ្យទាំងឡាយបានពោលរាប់រងថា យ៉ាងនោះធ្លាប់មានមកហើយ. យ៉ាងនេះនឹងមានតទៅខាងមុខ.

ពាក្យនោះសុទ្ធតែថា យ៉ាងនេះៗ សម្រាប់តែសេចក្ដីត្រិះរិះឱ្យរាយមាយច្រើនឡើង. ខ្ញុំព្រះអង្គមិនគាប់ចិត្តនឹងពាក្យនេះឡើយ. សូមព្រះអង្គទ្រង់សំដែងធម៌ដែលជាហេតុដកតណ្ហាចេញ ដែលខ្ញុំព្រះអង្គបានដឹងហើយ គប្បីជាអ្នកមានសតិឆ្លងកន្លងតណ្ហា ដ៏ជាប់ស្អិតនៅក្នុងលោកនេះ ដូចម្ដេចព្រះអង្គ ?

ព្រះដ៏មានបុណ្យទ្រង់ព្យាករណ៍ថា ជនពួកណាបានដឹងថា និព្វានជាទីបន្ទោបង់ នូវតម្រេកក្នុងអារម្មណ៍ជាទីស្រឡាញ់. ដែលខ្លួនបានឃើញហើយ. បានស្ដាប់ហើយ បានធុំហើយ. បានភ្លក់ហើយបានពាល់ត្រូវហើយ. បានដឹងហើយដោយចិត្ត ជាអចមិមិនប្រែប្រួលដូច្នេះហើយ ជាអ្នកមានស្មារតី មានធម៌បានឃើញហើយ. រំលត់កិលេសបានហើយ. ជនអ្នះស្ងប់រម្ងាប់កិលេសបានហើយនោះឯង តែងឆ្លងកន្លងតណ្ហាដែលនាំឱ្យជាប់នៅក្នុងលោកបានហើយ ។

ក្នុងទីបំផុតនៃបញ្ហាព្យាករណ៍ ហេមកមាណព ក៏បានសម្រេចអរហត្តព្រមដោយចតុប្បដិសម្ភិទាញាណ ហើយក្រាបទូលសូមបព្វជ្ជាឧបសម្បទា ។ ព្រះបរមគ្រូក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ជាមួយនឹងពួកមាណពជាសមានាចារ្យ ក្នុងគ្រាចប់សោឡសបញ្ហាព្យាករណ៍ ។ ព្រះហេមកត្ថេរ មានជន្មាយុក្នុងព្រះសាសនាដោយសមគួរដល់កាលកំណត់ហើយទើបបរិនិព្វាន ។

## ២៦. ប្រវត្តិព្រះតោទេយ្យត្ថេរ

ព្រះតោទេយ្យត្ថេរ ជាបុត្រព្រាហ្មណ៍ត្រកូលមួយ ក្នុងក្រុងសាវត្ថី កាល

បានវ័យធំចំរើនឡើង បានទៅសិក្សាលទ្ធិក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលហេមកមាណពក្រាបសួរប្រស្នា បានស្ដាប់ធម្មទេសនាសម្រេចអរហត្តហើយ ទើបតោទេយ្យមាណពក្រាបសួរប្រស្នាជាគំរប់ ៩ តទៅថា :

កាមទាំងឡាយមិនបានឋិតនៅក្នុងបុគ្គលណា. តណ្ហារបស់បុគ្គលណាមិនមាន. ហើយបុគ្គលណាឆ្លងកន្លងផុត សេចក្ដីសង្ស័យបានហើយ. ការផុតរបូតរបស់បុគ្គលនោះតើដូចម្ដេច ?

ព្រះដ៏មានជោគជាអម្ចាស់ទ្រង់ព្យាករថា ការផុតរបូតរបស់បុគ្គលនោះមិនក្លាយទៅជាយ៉ាងដទៃទៀត មិនមានឡើយ (អធិប្បាយថា: បុគ្គលនោះផុតចាកកាម. ចាកតណ្ហា ចាកសេចក្ដីសង្ស័យហើយ. កាមក្ដី តណ្ហាក្ដី សេចក្ដីសង្ស័យក្ដី អាចនឹងត្រឡប់កើតឡើងវិញ ហើយអ្នកនោះត្រូវព្យាយាមធ្វើឱ្យផុតរបូតទៅម្ដងទៀត មិនមានឡើយ. សេចក្ដីផុតរបូតរបស់បុគ្គលនោះខ្ជាប់ខ្ជួនមិនមានប្រែប្រួលឡើយ) ។

-បុគ្គលនោះ ជាអ្នកមានចំណង់ឬគ្មានទេ. ជាអ្នកមានបញ្ញាមែនពិត ឬគ្រាន់តែជាអ្នកបង្កតណ្ហា នឹងទិដ្ឋិឱ្យកើតឡើងដោយបញ្ញា. តើខ្ញុំព្រះអង្គ នឹងស្គាល់បុគ្គលជាមុនីនោះដូចម្ដេច សូមព្រះអង្គត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គ ?

-បុគ្គលនោះឥតចំណង់អន្ទះអន្ទែង. ជាអ្នកមានបញ្ញាមែន. មិនមែនជាអ្នកបង្កទិដ្ឋិនឹងតណ្ហាឱ្យកើតឡើងដោយបញ្ញាទេ. ចូរអ្នកស្គាល់មុនីនោះថាជាអ្នកឥតកង្វល់ មិនជាប់ជំពាក់នៅក្នុងកាមភពដូច្នេះចុះ ។

ក្នុងទីបំផុតនៃបញ្ហាព្យាករណ៍ តោទេយ្យមាណពបានសម្រេចអរហត្ត

ព្រមដោយចតុប្បដិសម្ភិទាញាណ ទើបក្រាបបង្គំទូលសូមឧបសម្បទ ។ សម្តេចព្រះសុគតទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុដោយឯហិភិក្ខុឧបសម្បទា ព្រម ជាមួយនឹងពួកមាណពទាំងនោះ ក្នុងវេលាចប់សោឡសបញ្ហាព្យាករណ៍ ។ ព្រះ តោទេយ្យត្ថេរមានជន្មាយុក្នុងព្រះសាសនា ដោយសមគួរដល់កាលកំណត់ ហើយ ក៏រលត់ខន្ធបរិនិព្វាន ។

# ២៧-ប្រវត្តិព្រះកប្បត្ថេរ

ព្រះកប្បត្ថេរ ជាបុត្រព្រាហ្មណ៍ម្នាក់ នៅក្នុងក្រុងសាវត្ថី កាលចំរើនវ័យ ឡើង បានទៅនៅសិក្សាក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលតោទេយ្យមាណព ក្រាបទូលសួរប្រស្នាជ,នស្តាប់ព្រះធម្មទេសនា សម្រេចអរហត្តហើយ ទើបកប្បមាណពបានឱកាសក្រាបទូលសួរប្រស្នាជាគំរប់ ១០ តទៅថា :

សូមព្រះអង្គត្រាស់ប្រាប់ធម៌ដែលជាទីពឹងពុំនាក់នៃជន ដែលមានជរា នឹងមរណៈមកដល់ជុំវិញ ដូចជាកោះជាទីស្នាក់អាស្រ័យ នៃជនអ្នកឋិតនៅនា កណ្តាលសាគរ ដែលមានរលកគគ្រាំគម្រែងគួរស្ញែងខ្លាច ដល់ខ្ញុំព្រះអង្គ. កុំឱ្យ ទុក្ខនេះកើតឡើងទៀតបាន ?

ព្រះឈ្នះមារទ្រង់ព្យាករថា តថាគតពោលថា និព្វានគ្មានកិលេសជា គ្រឿងកង្វល់ មិនមានតណ្ហាជាគ្រឿងប្រកាន់មាំ. ជាទីអស់ទៅនៃជរានឹង មរណៈនេះឯង បីដូចជាកោះ មិនមែនធម៌ដទៃផ្សេងទៀត ជនពួកណាស្គាល់

និព្វានទោះហើយ ជាអ្នកមានសតិ. មានធម៌បានឃើញហើយ. រលត់កិលេសបានហើយ. ជនពួកនោះមិនបាច់ធ្លាក់ទៅកងអំណាចនៃមារ. មិនបាច់ដើរក្នុងផ្លូវនៃមារឡើយ ។

វេលាចប់បញ្ហាព្យាករណ៍ តោទេយ្យមាណពបានសម្រេចអរហត្ត ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបថ្វាយបង្គំសូមឧបសម្ប័ទ ។ ព្រះដ៏មានបុណ្យក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ព្រមជាមួយនឹងពួកមាណពទាំងនោះ ក្នុងខណៈចប់សោឡសបញ្ហាព្យាករណ៍ ។ ព្រះកប្បត្ថេរ មានជន្មាយុក្នុងព្រះសាសនា ដោយសមគួរដល់កាលកំណត់ហើយ ក៏រលត់ខ័ន្ធចូលកាន់បរិនិព្វាន ។

## ២៨-ប្រវត្តិព្រះជតុកណ្ណិត្ថេរ

ព្រះជតុកណ្ណិត្ថេរ ជាបុត្រព្រាហ្មណ៍ត្រកូលមួយ ក្នុងនគរសាវត្ថីមានឈ្មោះថាជតុកណ្ណិមាណព បានទៅនៅសិក្សាលទ្ធិក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលកប្បមាណពក្រាបទូលសួរប្រស្នា បានស្តាប់ព្រះធម្មទេសនាសម្រេចអរហត្តហើយ ទើបជតុកណ្ណិមាណពបានឱកាសក្រាបទូលសួរប្រស្នាជាគំរប់ ១១ តទៅថា :

ខ្ញុំព្រះអង្គបានដឹងច្បាស់ថា ព្រះអង្គមិនមែនជាអ្នកប្រាថ្នាកាម ឆ្លងអន្លង់កិលេសផុតទៅហើយ. ទើបចូលមកក្រាបថ្វាយបង្គំគាល់ទូលសួរព្រះអង្គអ្នកឥតកិលេសកាមហើយ. សូមព្រះដ៏មានជោគ មានបញ្ញាដូចដួងចក្ខុកើតឡើង

ព្រមទាំងសេចក្តីត្រាស់ដឹង. សូមព្រះអង្គប្រាប់សំដែងធម៌ជាគ្រឿងរម្ងាប់កិលេស ដល់ខ្ញុំព្រះអង្គ. ព្រោះហេតុថា ព្រះអង្គទ្រង់ផ្ចាញ់កិលេសកាមឱ្យស្ងប់ស្ងៀមទៅ ហាក់ដូចដួងអាទិត្យ កំដៅផែនដីឱ្យហែងហួតស្ងួតទៅដោយរស្មី. សូមព្រះអង្គ ដ៏មានបញ្ញាធំទូលាយដូចផែនដី ទ្រង់ព្រះមេត្តាប្រោសសំដែងធម៌ ជាគ្រឿងលះ បង់នូវជាតិជរាក្នុងអត្តភាពដែលខ្ញុំព្រះអង្គគួរចេះគួរដឹង ដល់ខ្ញុំព្រះអង្គអ្នក មានបញ្ញាតិចផង ?

ព្រះបរមសាស្តាទ្រង់ព្យាករថា ចូរអ្នកនាំយកតម្រេកក្នុងកាមចេញឱ្យ អស់ ហើយឃើញការចេញចាកកាមជាសភាវៈក្សេមក្សាន្តចុះ. កិលេសជា គ្រឿងកង្វល់ ដែលអ្នកធ្លាប់តោងស្អិតដោយតណ្ហានិងទិដ្ឋិ ដែលគាប្បលះបង់ ចេញ កុំឱ្យចាក់ដោតដល់ចិត្តរបស់អ្នក. កង្វល់ឯណាធ្លាប់មានមកហើយក្នុង កាលមុន. ចូរអ្នកញ៉ាំងកង្វល់នោះឱ្យហែងហួតស្ងួតទៅ. កង្វល់ជាខាងក្រោយ កុំបីមានដល់អ្នកដទៃ. បើអ្នកមិនប្រកាន់យកនូវកង្វល់កណ្តាលទេ. អ្នកនឹង បានជាអ្នកស្ងប់រម្ងាប់កង្វល់ត្រេចទៅ. អាសវកិលេសដែលជាហេតុឱ្យលុះ អំណាចមច្ចុរាជ របស់ជនអ្នកប្រាសចាកតម្រេកក្នុងនាមរូបដោយអាការទាំង ពួង មិនគប្បីមានឡើយ ។

ក្នុងឱកាសចប់បញ្ហាព្យាករណ៍ ជតុកណ្ណិមាណពក៏បានសម្រេចអរហត្ត-ផល ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបថ្វាយបង្គំសូមឧបសម្ប័ទ ។ ព្រះបរមគ្រូក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ព្រមទាំង ពួកមាណពទាំងនោះ ក្នុងវេលាចប់ទេសនាបញ្ហាព្យាករណ៍ ។

ព្រះជតុកណ្ណិថេរ បានជីវិតក្នុងព្រះសាសនា - ត្រាតែសមគួរដល់កំណត់អាយុសង្ខារហើយទើបនិព្វាន ។

# ២៩~ប្រវត្តិព្រះភទ្រាវុធត្ថេរ

ព្រះភទ្រាវុធត្ថេរ កើតក្នុងត្រកូលព្រាហ្មណ៍ ១ នាក្រុងសាវត្ថី កាលបានវ័យចំរើនឡើង បានទៅរៀនសិក្សាចំពោះវិជ្ជា ក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល ។

កាលព្រះបរមគ្រូទ្រង់ដោះស្រាយ ប្រស្នារបស់ជតុកណ្ណិមាណពរួចហើយ. ទើបភទ្រាវុធមាណពកាន់ឱកាសក្រាបទូល សួរប្រស្នាជាគំរប់ ១២ ដោយគាថា :

ខ្ញុំព្រះអង្គសូមក្រាបទូលអារាធនាព្រះអង្គ ជាអ្នកទ្រង់លះបង់អាល័យ កាត់ផ្តាច់នូវតណ្ហាបានហើយ. មិនទ្រង់ញាប់ញ័រ (ព្រោះលោកធម៌) លះបង់សេចក្តីរីករាយចេញហើយ ទ្រង់ឆ្លងអន្លង់កិលេសផុតអស់ហើយ. ទ្រង់លះបង់ធម៌ជាគ្រឿងត្រិះរិះ (ផ្សេងៗ) គឺតណ្ហានឹងទិដ្ឋិហើយវាមានព្រះប្រាជ្ញាញាណដ៏ថ្លៃថ្លា. ជនទៅជនបទផ្សេងៗ ចង់ស្តាប់ស័ព្ទព្រះវាចារបស់ព្រះអង្គ នាំគ្នាចេញមកអំពីជនបទនោះៗ បានស្តាប់ស័ព្ទព្រះវាចារបស់ព្រះអង្គហើយនឹងត្រឡប់ចេញទៅអំពីទីនេះ. សូមព្រះអង្គទ្រង់ដោះស្រាយប្រស្នា ដើម្បីជនទាំងនោះ ព្រោះថាធម៌នោះព្រះអង្គទ្រង់បានជ្រាបហើយ។

ព្រះបរមសាស្តាទ្រង់ព្យាករថា ពពួកជនទាំងនោះ គួរនាំចេញនូវតណ្ហាដែលជាហេតុប្រកាន់មាំ ទាំងខាងលើ ទាំងខាងក្រោម នឹងចំណែកកណ្តាលក្តី

អស់ទៅ. ព្រោះបុគ្គលប្រកាន់មាំរបស់អ្វីៗ ក្នុងលោក. មាររមែងព្រេចទៅតាមបុគ្គលនោះ ដោយសាររបស់នោះៗ ហេតុនេះ កាលបើភិក្ខុបានដឹងឃើញពពួកសត្វដែលជាប់នៅក្នុងវដ្ដៈ ជាទីអាស្រ័យនៃមារថា ជាប់ជំពាក់នៅព្រោះអាស្រ័យសេចក្ដីប្រកាន់មាំដូច្នេះ គប្បីជាអ្នកមានសតិ មិនប្រកាន់មាំ ឥតកង្វល់ក្នុងលោកទាំងពួង ។

ក្នុងទីបំផុតនៃបញ្ហាព្យាករណ៍ ភទ្រាវុធមាណពបានសម្រេចអរហត្ត ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបបង្គំទូលសូមឧបសម្ប័ទ ។ ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ព្រមជាមួយនឹងពួកមាណពទាំងនោះ ក្នុងទីបំផុតនៃសោឡសបញ្ហាព្យាករណ៍ ។

ព្រះភទ្រាវុធត្ថេរ ឋិតនៅក្នុងព្រះសាសនាត្រាតែដល់កំណត់អាយុសង្ខារហើយ ក៏រំលត់ខ័ន្ធចូលកាន់បរិនិព្វាន ។

## ៣០~ប្រវត្តិព្រះឧទយត្ថេរ

ព្រះឧទយត្ថេរ ជាបុត្រព្រាហ្មណ៍ម្នាក់នៅក្រុងសាវត្ថី កាលមានវ័យចំរើនឡើង បានចេញទៅនៅរៀនសូត្រ ក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

លុះភទ្រាវុធមាណពក្រាបទូលសួរប្រស្នា បានស្ដាប់ព្រះធម្មទេសនាសម្រេចអរហត្តហើយ ទើបឧទយមាណពបានឱកាសក្រាបបង្គំទូលសួរប្រស្នាជាគំរប់ ១៣ សេចក្ដីថា :

ខ្ញុំព្រះអង្គមានបំណងនឹងក្រាបទូលសួរប្រស្នាទើបចូលមកក្រាបថ្វាយ

បង្គំគាល់ព្រះអង្គ ទ្រង់គង់រំពេញពរោគ. កោចព្រះសង្ឃាមក្រាសកោកកិលេស ធូលី. គ្មានអាស្រវៈ. ទ្រង់ធ្វើកិច្ចដែលត្រូវធ្វើរួចហើយ. ទ្រង់លុះដល់ត្រើយនៃធម៌ទាំងពួង. សូមព្រះអង្គទ្រង់សំដែងធម៌ជាគ្រឿងផុត (ចាកកិលេស) ដែលគួរដឹងទូទៅ ជាគ្រឿងទំលាយបង់នូវអវិជ្ជាគឺសេចក្តីល្ងង់ខ្លៅ មិនដឹងច្បាស់តាមពិតនោះ ?

ព្រះបរមគ្រូទ្រង់ព្យាករថា តថាគតពោលនូវធម៌ជាគ្រឿងលះបង់ នូវសេចក្តីត្រេកអរក្នុងកាមនឹងទោមនស្សទាំងពីរយ៉ាង. ជាគ្រឿងបន្ទោបង់នូវងងុយងោក. ជាគ្រឿងរាំងរានូវសេចក្តីរំខាន. មានឧបេក្ខានឹងសតិ កោនសេចក្តីត្រិះរិះប្រកបដោយធម៌ ថាជាធម៌ផុត (ចាកកិលេស) ដែលគួរដឹងទៅ ជាគ្រឿងទំលាយបង់នូវអវិជ្ជា សេចក្តីល្ងង់ខ្លៅ មិនដឹងច្បាស់ ។

-លោកមានអ្វីចងទុក អ្វីជាគ្រឿងត្រេចទៅរបស់លោកនេះ ដែលលោកពោលថា និព្វាន១ ដូច្នេះ ព្រោះលះអ្វីចេញបាន ?

-លោកមានការរីករាយភ្លើតភ្លើនចងទុក. សេចក្តីត្រិះរិះជាគ្រឿងត្រេចទៅនៃលោកនេះ. លោកពោលថា និព្វាន១ ដូច្នេះ ព្រោះលះតណ្ហាចេញបាន ។

-កាលបុគ្គលមានសតិនឹករលឹកដូចម្តេច ទើបវិញ្ញាណរលត់ទៅ ខ្ញុំព្រះអង្គទាំងឡាយនាំគ្នាចូលមកគាល់ព្រះអង្គ ដើម្បីទូលសួរព្រះអង្គសូមឱ្យខ្ញុំព្រះអង្គបានស្តាប់ព្រះវាចារបស់ព្រះអង្គ ?

-កាលបើបុគ្គលមិនរីករាយនឹងវេទនាទាំងខាងក្នុង ទាំងខាងក្រៅ មានសតិរលឹកយ៉ាងនេះ ទើបវិញ្ញាណរបស់គេរលត់ទៅ ។

វេលាចប់សោឡសបញ្ហាព្យាករណ៍ ឧទយមាណពបានសម្រេចអរហត្ត ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបបង្គំទូលសូមឧបសម្បទក្នុងព្រះសាសនា។ ព្រះបរមសាស្តាទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ជាមួយនឹងពួកមាណពជាសមានាចារ្យ ក្នុងវេលាចប់សោឡសបញ្ហាព្យាករណ៍។ ព្រះឧទយត្ថេរមានជីវិតនៅក្នុងព្រះសាសនាគ្រាតែដល់កំណត់អាយុសង្ខារ ទើបលោករំលត់ខន្ធចូលកាន់បរិនិព្វាន ។

## ៣១ - ប្រវត្តិព្រះបោសាលត្ថេរ

ព្រះបោសាលត្ថេរ ជាបុត្រព្រាហ្មណ៍ម្នាក់នៅក្រុងសាវត្ថី មាននាមថា បោសាលមាណព កាលចំរើនវ័យឡើង បានទៅនៅសិក្សាលទ្ធិក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលឧទយមាណពក្រាបទូលសួរប្រស្នាបានស្តាប់ធម្មទេសនាសម្រេចអរហត្តហើយ ទើបបោសាលមាណពបានឱកាសក្រាបទូលសួរប្រស្នាជាគំរប់ ១៤ តទៅថា:

ខ្ញុំព្រះអង្គមានបំណងនឹងទូលសួរប្រស្នា ទើបចូលមកគាល់ព្រះអង្គ ជាអ្នកទ្រង់សំដែងនូវព្រះប្រាជ្ញាញាណ ក្នុងអតីតកាល. មិនទ្រង់រំភើប (ដោយសុខទុក្ខ) ទ្រង់បានកាត់ផ្តាច់សេចក្តីសង្ស័យហើយ. ទ្រង់ឆ្លងដល់ត្រើយនៃធម៌ទាំងពួងហើយ. ខ្ញុំព្រះអង្គសូមទូលសួរ អំពីញាណរបស់បុគ្គលអ្នកមានតម្រេកសំគាល់ក្នុងរូបជាក់ច្បាស់ (គឺបានឈានហើយ) លះរូបបារម្មណ៍ទាំងពួងបាន

ហើយ (គឺកន្លងផុតរូបជ្ឈានហើយ). មើលឃើញទាំងខាងក្នុងទាំងខាងក្រៅថា មិនមានអ្វីបន្តិចបន្តួច (គឺលុះដល់អរូបជ្ឈាន ដែលហៅថា អាកិញ្ចញ្ញាយតនជ្ឈាន). តើបុគ្គលដូច្នេះ គួរនឹងណែនាំទូន្មានឱ្យធ្វើដូចម្ដេចតទៅទៀត ?

ព្រះបរមសាស្ដាទ្រង់ព្យាករថា តថាគតទ្រង់ជ្រាបភូមិ ជាទីតាំងនៃវិញ្ញាណទាំងអស់ ទើបទ្រង់ជ្រាបបុគ្គលដូច្នោះ ទោះបីឋិតនៅក្នុងលោកនេះ ថាមានអធ្យាស្រ័យបង្អោននៅក្នុងអាកិញ្ចញ្ញាយតនភព មានអាកិញ្ចញ្ញាយតនភពជាទីប្រព្រឹត្តទៅខាងមុខ. បុគ្គលដូច្នោះដឹងថាកម្មជាហេតុឱ្យកើតក្នុងអាកិញ្ចញ្ញាយតនភព មានសេចក្ដីត្រេកអរពីកាយជាគ្រឿងប្រកបដូច្នេះហើយ លំដាប់នោះឯង តែងពិចារណាឃើញសហជាតធម៌ ក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ (គឺធម៌ដែលកើតព្រមគ្នានឹងឈាននេះ). ដឹងជាក់ច្បាស់ដោយលក្ខណៈទាំង ៣ (គឺមិនទៀង. ជាទុក្ខ. មិនមែនខ្លួន) ខនេះជាញាណដ៏ពិតប្រាកដរបស់ព្រាហ្មណ៍នោះ អ្នកមានព្រហ្មចរិយធម៌បានប្រព្រឹត្តចប់ហើយ ។

ក្នុងទីបំផុត នៃបញ្ហាព្យាករណ៍ បោសាលមាណពបានសម្រេចអរហត្តព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបទូលសូមឧបសម្បទ ។ ព្រះដ៏មានបុណ្យទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដូចន័យមុន ។ ព្រះបោសាលត្ថេររស់នៅក្នុងព្រះសាសនា ព្រាតែសបគួរដល់កំណត់អាយុសង្ខារ ទើបលោករំលត់ខ័ន្ធចូលកាន់បរិនិព្វាន ។

☆☆☆

# ៣២-ប្រវត្តិព្រះមោឃរាជត្ថេរ

ព្រះមោឃរាជត្ថេរ ជាបុត្រត្រកូលមួយ ក្នុងក្រុងសាវត្ថី មាននាមថា មោឃរាជមាណព កាលមានវ័យចំរើនឡើង បានផ្ញើខ្លួនជាសិស្សក្នុងសំណាក់ព្រាហ្មណ៍ពាវរី ដ៏ជាមហាបុរោហិតនៃព្រះបាទកោសលរាជ ។ អំណើះកាលតមក ព្រាហ្មណ៍ពាវរីមានសេចក្ដីនឿយណាយខាងផ្លូវឃរាវាស ទើបក្រាបទូលលាព្រះមហាក្សត្រចេញពីតំណែងបុរោហិត ហើយទៅបួសជាជដិល តាំងអាស្រមនៅនាឆ្នេរស្ទឹងគោធាវារី ព្រំប្រទល់ដែននៃស្រុកអស្សកៈនឹងស្រុកអាលកៈ ។ មោឃរាជមាណពព្រមទាំងពួកសិស្សជាសាមានាចារ្យ ក៏នាំគ្នាទៅបួសតាមអាចារ្យ ។

លុះព្រះពុទ្ធជាម្ចាស់ទ្រង់ឧប្បត្តិឡើងក្នុងលោក មានព្រះកិត្តិគុណល្បីខ្ចរខ្ចាយសាយចេញទៅក្នុងទិសតំបន់ផ្សេងៗ ។ ព្រាហ្មណ៍បានជ្រាបកិត្តិស័ព្ទក៏នឹកជឿងឆ្ងល់មានបំណងចង់ស៊ើបឱ្យដឹងការពិត ទើបចងជាប្រស្នាឱ្យមាណពជាសិស្ស ១៦ នាក់មានអជិតមាណពជាប្រធាន ក្នុងម្នាក់១វគ្គ១ ឱ្យនាំយកទៅក្រាបទូលសួរល្បងមើល មោឃរាជមាណព គឺនៅក្នុងចំនួននេះដែរ បាននាំគ្នាព្រមទាំងបរិវារ ចូលទៅគាល់ព្រះបរមសាស្ដាឯបាសាណចេតិយ៍ ដែនមគធរដ្ឋក្រាបទូលសូមព្រះឱកាសសួរប្រស្នាម្នាក់ម្ដងៗ ។ កាលព្រះដ៏មានបុណ្យទ្រង់អនុញ្ញាតហើយ ទ្រង់បានដោះស្រាយប្រស្នារបស់អជិតមាណពជាលើកដំបូងចប់ហើយ មោឃរាជមាណពប្រារព្ធនឹងទូលសួរប្រស្នាជាលំដាប់តទៅ ។ មាន

សេចក្ដីដឹងពាក្យថា មោឃរាជមាណពនេះ ប្រកាន់ខ្លួនថាជាអ្នកមានប្រាជ្ញាឆ្នើត ជាងគេ គិតចង់ទូលសួរមុន ប៉ុន្តែនឹកក្រែងចិត្តអជិតមាណពដែលជាធំជាង ទើបបណ្ដោយឱ្យអជិតមាណពទូលសួរមុន។ ព្រះបរមគ្រូទ្រង់ទតឃើញអាការ ដូច្នោះ ទើបត្រាស់ឃាត់មោឃរាជមាណពឱ្យបង្អង់សិន ។ លុះមាណពដទៃ ទៀតនាំគ្នាក្រាបទូលសួរប្រស្នាទៅដោយលំដាប់ដល់ ៨ នាក់ហើយ មោឃរាជ មាណពប្រារព្ធនឹងទូលសួរទៀត ព្រះអង្គក៏ត្រាស់ហាមឃាត់ឱ្យបង្អង់សិនទៀត។ កាលមាណពទាំងឡាយក្រាបសួរប្រស្នាហួសទៅ៦នាក់ទៀតហើយ ទើប មោឃរាជមាណពបានឱកាសក្រាបទូលសួរប្រស្នាជាគំរប់ ១៥ មានសេចក្ដីថា:

ខ្ញុំព្រះអង្គនឹងពិចារណាឃើញលោកដូចម្ដេច ទើបស្ដេចមច្ចុរាជមើលមិន ឃើញ គឺថាតាមមិនទាន់ ?

ព្រះពិជិតមារទ្រង់ព្យាករថា ម្នាលមោឃរាជ. ចូរអ្នកមានសតិពិចារណា ឃើញលោកថាជាសភាវៈសាបសូន្យទទេ ដកអត្តានុទិដ្ឋិចេញគ្រប់ខណៈចុះ. អ្នកនឹងឆ្លងកន្លងមច្ចុរាជចេញទៅបានដោយឧបាយយ៉ាងនេះ. បើអ្នកពិចារណា ឃើញលោកយ៉ាងនេះ ទើបមច្ចុរាជមើលមិនឃើញ ។

ក្នុងវេលាចប់បញ្ហាព្យាករណ៍ មោឃរាជមាណពបានសម្រេចអរហត្ត ព្រមទាំងបរិវារ ទើបក្រាបបង្គំទូលសូមឧបសម្បទ ក្នុងព្រះសាសនា ។ ព្រះ បរមសាស្តាទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុដូចន័យមុន ។.

ព្រះមោឃរាជត្ថេរនេះ ចាប់តាំងពីបានឧបសម្បទមក លោកតែង ទ្រទ្រង់ចីវរប្រកបដោយសៅហ្មង ៣ យ៉ាង គឺសំពត់សៅហ្មង. ដេរក៏សៅហ្មង

ជ្រលក់ក៏សៅហ្មង. ហេតុនេះទើបព្រះបរមគ្រូ កាលទ្រង់ប្រថាប់ក្នុងព្រះជេវន មហាវិហារ បានទ្រង់តាំងព្រះមោឃរាជត្ថេរក្នុងតំណែងឯតទគ្គៈ គឺជាកំពូល នៃភិក្ខុទាំងឡាយ ដែលទ្រទ្រង់ចីវរសៅហ្មង ។ លោកគង់នៅក្នុងព្រះសាសនា សមគួរដល់កំណត់អាយុហើយ ក៏រលត់ខ័ន្ធបរិនិព្វាន ។

# ៣៣-ប្រវត្តិព្រះបិង្គិយត្ថេរ

ព្រះបិង្គិយត្ថេរ កើតក្នុងត្រកូលព្រាហ្មណ៍មួយ ក្នុងក្រុងសាវត្ថីត្រូវជា ក្មួយរបស់ព្រាហ្មណ៍ពាវរី-កាលចំរើនវ័យឡើង បានសិក្សាសិល្បសាស្ត្រក្នុង សំណាក់ឪពុកធំ ។ មានសេចក្ដីដំណាលថា ព្រាហ្មណ៍ពាវរីនេះ ធ្វើជាបរោហិត នៃព្រះបាទកោសលរាជ ។ តមកសម័យក្រោយ ព្រាហ្មណ៍ពាវរីបាន ក្រាបទូលលាព្រះមហាក្សត្រចេញទៅបួសតាមលទ្ធិព្រាហ្មណ៍ តាំងអាស្រមនៅ ក្នុងឆ្នេរស្ទឹងគោធាវារី នាទីព្រំប្រទល់ស្រុកអស្សកៈនឹងស្រុកអាលកៈ ។ល ។

មោឃរាជមាណពក្រាបទូលសួរប្រស្នា បានស្ដាប់ព្រះធម្មទេសនាសម្រេច អរហត្តហើយ ទើបបិង្គិយមាណពក្រាបទូលសួរប្រស្នាជាគំរប់ ១៦ តទៅថា :

ខ្ញុំព្រះអង្គជាមនុស្សចាស់ហើយ មិនមានកំឡាំង អស់សំបុរផូរផង់ហើយ ភ្នែករបស់ខ្ញុំព្រះអង្គក៏មើលមិនឃើញច្បាស់ត្រចៀកក៏ស្ដាប់មិនបានស្រួល. សូមកុំឱ្យខ្ញុំព្រះអង្គសាបសូន្យក្នុងចន្លោះឡើយ សូមព្រះអង្គត្រាស់សំដែងធម៌ ដែលខ្ញុំព្រះអង្គគួរចេះដឹង ជាគ្រឿងលះបង់នូវជាតិជរា ក្នុងអត្តភាពនេះ ។

ព្រះបរមសាស្ដាទ្រង់ព្យាករថា អ្នកឃើញថាជនទាំងឡាយប្រមាទ

ប៉ុន្តែ រមែងក្តៅក្រហាយព្រោះរូបជាហេតុ ហេតុនេះ ចូរអ្នកកុំបីប្រមាទ លះបង់សេចក្តីតាមចិត្តក្នុងរូបចេញ ទើបមិនបាច់កើតទៀត ។

ទិសធំបួន ទិសតូចបួន ជាដប់ទាំងទិសខាងលើ-ខាងក្រោម ដែលព្រះអង្គមិនបានឃើញហើយ មិនបានឮហើយ មិនបានជ្រាបហើយ. សូម្បីតែបន្តិចបន្តួចក៏មិនមានក្នុងលោក. សូមព្រះអង្គត្រាស់ប្រាប់ធម៌ដែលខ្ញុំព្រះអង្គគួរត្រាស់ដឹង ជាគ្រឿងលះជាតិជរាក្នុងអត្តភាពនេះ ?

-កាលបើអ្នកឃើញពួកមនុស្ស មានតណ្ហាគ្របសង្កត់ហើយ. មានសេចក្តីក្តៅក្រហាយកើតឡើងហើយ. មានជរាចោមរោមហើយ ហេតុនេះ ចូរអ្នកកុំប្រមាទលះតណ្ហាចេញ អ្នកនឹងមិនបាច់កើតឡើង ។

វេលាចប់បញ្ហាព្យាករណ៍ បិង្គិយមាណពសម្រេចធម្មចក្ខុថ្នាក់សោតាបត្តិផល ហេតុដែលបិង្គិយមាណពមិនបានសម្រេចអរហត្តក្នុងខណៈនោះ ព្រោះមានគំនិតគិតដល់ព្រាហ្មណ៍ពាវរីជាអាចារ្យ ក្នុងខណៈស្តាប់ព្រះធម្មទេសនា ដោយនឹកស្តាយថា ឪពុកធំពុំបានស្តាប់ព្រះធម្មទេសនាដ៏ពីរោះយ៉ាងនេះសោះ ។ អាស្រ័យទោសដែលកើតចិត្តរាយមាយដូច្នេះ ទើបមិនអាចធ្វើចិត្តឱ្យផុតចាកអាសវៈទៅបាន ។ លំដាប់នោះ បិង្គិយមាណពក៏បានក្រាបទូលសូមឧបសម្ប័ទ ។ ព្រះបរមគ្រូ ក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុដោយឯហិភិក្ខុឧបសម្បទា ជាមួយនឹងមាណព ១៥ នាក់ទៀត ។

លោកបិង្គិយភិក្ខុបានក្រាបថ្វាយបង្គំលាព្រះបរមគ្រូត្រឡប់ទៅថ្លែងពតិមាន ដល់ព្រាហ្មណ៍ពាវរីជាអាចារ្យ ។ សម័យក្រោយមកលោកបានស្តាប់

ព្រះបរមពុទ្ធោវាទ ទើបធ្វើចិត្តឱ្យផុតចាកអាសវក្កិលេសទាំងពួង ។ ចំណែក
ឯព្រាហ្មណ៍ពាវរីបានលុះធម្មាភិសម័យត្រឹមថ្នាក់សេខភូមិ ។ ព្រះបិង្គិយត្ថេរ
មានជន្មាយុក្នុងព្រះសាសនាសមគួរដល់កាលកំណត់ហើយក៏បរិនិព្វាន ។

# ៣៤-ប្រវត្តិព្រះរាធត្ថេរ

ព្រះរាធត្ថេរ ជាបុត្រព្រាហ្មណ៍ម្នាក់ ក្នុងក្រុងរាជគ្រឹះ មគធរដ្ឋ លុះចាស់
ជរាទុព្វលភាពហើយ ប្រពន្ធកូនគេមិនទទួលចិញ្ចឹម ទើបចូលទៅអាស្រ័យនៅ
នឹងព្រះភិក្ខុសង្ឃ ក្នុងវេឡុវនមហាវិហារ ។ រាធព្រាហ្មណ៍នោះ បានបំណង
ចង់បួសក្នុងព្រះសាសនា តែភិក្ខុទាំងឡាយមិនព្រមបំបួសឱ្យ ដោយយល់ថា
គាត់មិនអាចប្រព្រឹត្តកិច្ចវត្តក្នុងព្រះសាសនាឱ្យបរិបូណ៌បាន ។ ឯរាធព្រាហ្មណ៍
ក៏កើតទុក្ខមានរាងកាយស្គម ។

សម័យក្រោយមក គាត់បានចូលទៅក្រាបថ្វាយបង្គំគាល់ព្រះដ៏មាន
បុណ្យ ក្រាបទូលថ្លែងបំណងរបស់គាត់ឱ្យទ្រង់ជ្រាប ។ ព្រះអង្គទ្រង់ទត
ឃើញឧបនិស្ស័យធម៌របស់គាត់ ទើបទ្រង់អនុញ្ញាតឱ្យបួសក្នុងសំណាក់ព្រះ
សារីបុត្តត្ថេរ ។ លុះទ្រង់អនុញ្ញាតឱ្យព្រះសារីបុត្របំបួសរាធព្រាហ្មណ៍ ដូច្នោះ
ហើយ ព្រះអង្គក៏ទ្រង់បញ្ញត្តិមិនឱ្យភិក្ខុទាំងឡាយឱ្យឧបសម្បទកុលបុត្រ
ដោយត្រៃសរណគមនូបសម្បទា ដែលទ្រង់អនុញ្ញាតទុកអំពីមុន តាំងអំពី
កាលណោះជាដើមទៅ ។ វិធីឧបសម្បទបែបក្រោយនេះ គឺទ្រង់អនុញ្ញាតឱ្យ
សង្ឃឧបសម្បទកុលបុត្រទាំងឡាយដោយវិធីញត្តិចតុត្ថកម្មវាចា តាំងអំពីគ្រា

នោះមក ។ ព្រះភគ្គេរបានទទួលវិធីឧបសម្ប័ទបែបនេះជាអង្គដំបូងបំផុត ។

ពេលក្រោយថ្ងៃមួយ លោកចូលទៅគាល់ព្រះដ៏មានបុណ្យក្រាបបង្គំទូលថា សូមព្រះអង្គទ្រង់សំដែងធម៌ដល់ខ្ញុំព្រះអង្គដោយសង្ខេប. ខ្ញុំព្រះអង្គបានស្តាប់ហើយនឹងចៀសចេញចាកពួកគណៈទៅនៅតែម្នាក់ឯង មានសេចក្តីមិនប្រមាទបញ្ជូនចិត្តទៅក្នុងភាវនា ។ ព្រះបរមសាស្តាទ្រង់ទូន្មានថា ម្នាលរាធៈ របស់ឯណាជាមារ. ចូរអ្នកលះបង់សេចក្តីត្រេកត្រអាលពេញចិត្ត ក្នុងរបស់នោះចេញ. ចុះអ្វីជាមារ? -រូប. វេទនា. សញ្ញា. សង្ខារ. វិញ្ញាណ. ដែលមិនទៀង. ជាទុក្ខ. មិនមែនខ្លួន. មានការអស់ទៅ សាបសូន្យទៅ កើតឡើងតែងរលត់បាត់ទៅជាធម្មតា ឈ្មោះថា មារ. ចូរអ្នកលះសេចក្តីគាប់ចិត្ត ក្នុងរូប.. វេទនា. សញ្ញា. សង្ខារ. វិញ្ញាណ. នោះចេញ ។

កាលព្រះភគ្គេរទទួលយកព្រះឱវាទហើយក៏បានត្រេចចារិកទៅជាមួយនឹងព្រះសារីបុត្រជាព្រះឧបជ្ឈាយ៍ ។ លោកខំប្រឹងសមណធម៌ព្រាតែបានសម្រេចអរហត្តផលហើយ ទើបព្រះសារីបុត្រនាំលោកចូលមកគាល់ព្រះដ៏មានបុណ្យ។ ត្រាស់សួរព្រះសារីបុត្តថា សទ្ធិវិហារិករបស់អ្នកដូចម្តេចខ្លះ ? ព្រះសារីបុត្តក្រាបទូលសរសើរថាជាមនុស្សប្រដៅងាយណាស់ ។ បើណែនាំទូន្មានថា ការនេះគួរធ្វើ ការនោះមិនគួរធ្វើ ចូរអ្នកធ្វើការនេះ. កុំធ្វើការនោះដូច្នេះជាដើមមិនដែលខឹងឡើយ.។ ព្រះបរមគ្រូទ្រង់ទូន្មានភិក្ខុទាំងឡាយឱ្យប្រកាន់យកជាគំរូតួយ៉ាងថា អ្នកទាំងឡាយ ចូរធ្វើខ្លួនឱ្យជាអ្នកប្រដៅងាយ ដូចយ៉ាងរាធៈ នេះចុះ. កាលឧបជ្ឈាយាចារ្យចង្អុលទោសទូន្មានកុំខឹង. គួរគេបំរាណភ្ញិត

ដែលខ្លួនសំគាល់ឃើញថា ជាអ្នកបង្ហាញទោសពោលសង្កត់សង្កិនហាក់ដូចជាអ្នកចង្អុលបង្ហាញកំណប់ទ្រព្យឲ្យ ព្រោះតបរិបេក្ខិតដូច្នោះ ពាក្យតែគុណគោរពប្រសើរ មិនមានទោសលាមកសោះឡើយ ។

ដោយហេតុព្រះភគត្ថេរ ជាអ្នកប្រដៅងាយយ៉ាងក្រៃលែងយ៉ាងនេះ តមកសម័យក្រោយទើបលោកបានទទួលសេចក្ដីសរសើរអំពីព្រះដ៏មានបុណ្យ ថាប្រសើរលើសលែងភិក្ខុទាំងឡាយ រីឯខាងបដិភាណ គឺញាណភ្លឺឡាស់ក្នុងព្រះធម្មទេសនា អាចសំដែងធម៌ ដែលទ្រង់សំដែងហើយនោះបានដោយពិស្ដារ ។ ព្រះភគត្ថេរមានជន្មាយុក្នុងព្រះសាសនា ត្រាតែសមគួរដល់កាលកំណត់ហើយ ទើបលោករំលត់ខន្ធចូលកាន់បរិនិព្វាន ។

# ៣៥~ប្រវត្តិព្រះបុណ្ណមន្តានីបុត្តត្ថេរ

ព្រះបុណ្ណៈ កើតក្នុងត្រកូលព្រាហ្មណ៍មហាសាលក្នុងស្រុកព្រាហ្មណ៍ ១ ឈ្មោះទោណវត្ថុ ជិតក្រុងកបិលពស្តុ ជាបុត្រនាងមន្តានី ដែលជាប្អូនស្រីនៃព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ។ កាលព្រះអញ្ញាកោណ្ឌញ្ញត្ថេរជានីពុកធំ និមន្តទៅក្រុងកបិលពស្តុ ដើម្បីសួរត្រកូលរបស់លោកនោះ លោកបានដឹកនាំបុណ្ណមាណពជាក្មួយ ឱ្យចូលមកបព្វជ្ជាឧបសម្បទា ក្នុងព្រះពុទ្ធសាសនា។ លុះឧបសម្បទហើយទើបលោកនិមន្តទៅនៅក្នុងប្រទេស១ឈ្មោះជាតិភូមិ ចំរើនវិបស្សនាកម្មដ្ឋានមិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ព្រមទាំងចតុប្បដិសម្ភិទាញាណ លោកតែងតាំងនៅក្នុងគុណធម៌ ១០ ប្រការ គឺ ប្រាថ្នាតិច. សន្តោស. គាប់ចិត្ត

ស្ងាត់. មិនទៅច្របូកច្របល់ដោយពួកគណៈ. ប្រារព្ធសេចក្ដីព្យាយាម. បរិបូណ៌ដោយសីល. សមាធិ. បញ្ញា. វិមុត្តិ. វិមុត្តិញ្ញាណ ។ ទោះបីលោកមានបរិស័ទក៏ទូន្មានឱ្យឋិតនៅក្នុងគុណធម៌ទាំង ១០ ប្រការនេះដែរ. តមក លោកបានធ្វើជាឧបជ្ឈាយ៍បំបួសកុលបុត្រអ្នកស្រុកជាតិភូមិ ៥០០ នាក់ លោកក៏ទូន្មានភិក្ខុទាំងនោះ ដោយរកថាវត្ថុ ១០ ប្រការ គឺ សំដីដែលដឹកនាំឱ្យមានសេចក្ដីប្រាថ្នាតិច ១ សំដីដែលដឹកនាំឱ្យកើតសន្ដោស គឺត្រេកអរដោយបច្ច័យតាមមានតាមបាន ១ សំដីដែលដឹកនាំឱ្យស្ងាត់កាយស្ងាត់ចិត្ត ១ សំដីដែលដឹកនាំមិនឱ្យនៅច្របូកច្របល់ដោយពួកគណៈ ១ សំដីដែលដឹកនាំឱ្យប្រារព្ធសេចក្ដីព្យាយាម ១ សំដីដែលដឹកនាំឱ្យឋិតនៅក្នុងសីល ១ សំដីដែលដឹកនាំឱ្យធ្វើចិត្តឱ្យស្ងប់ ១ សំដីដែលដឹកនាំឱ្យកើតបញ្ញា ១ សំដីដែលដឹកនាំដើម្បីធ្វើចិត្តឱ្យផុតចាកកិលេស ១ សំដីដែលដឹកនាំឱ្យកើតញ្ញាណដឹងឃើញ ក្នុងដំណើរដែលចិត្តផុតចាកកិលេស ១ តាមដែលលោកបានជ្រាបមកហើយនោះ ។

សម័យ ១ ព្រះបរមសាស្ដាស្ដេចចេញអំពីក្រុងរាជគ្រឹះទៅកាន់ក្រុងសាវត្ថី ព្រះបុណ្ណមន្ដានីបុត្តត្ថេរបានជ្រាបដំណឹង ក៏ចូលទៅក្រាបថ្វាយបង្គំបានស្ដាប់ព្រះធម្មទេសនាហើយ ទើបលោកក្រាបថ្វាយបង្គំលាទៅគង់ឯអន្ធវនៈដើម្បីសម្រាកក្នុងពេលថ្ងៃ ។ ព្រះសារីបុត្តត្ថេរបានជ្រាបដំណឹង ក៏ចូលទៅរកព្រះបុណ្ណត្ថេរ ធ្វើសម្មោទនីយកថាទៅវិញទៅមក ហើយទើបលោកសួរអំពីវិសុទ្ធិ ៧ ប្រការ ចំពោះព្រះបុណ្ណត្ថេរៗ ក៏វិសជ្ជនាវិសុទ្ធិ ៧ ប្រការ ឧបមាដោយរាជរថឥតដាច់ដំពាក់ឡើយ ។ ព្រះមហាថេរទាំងពីររអង្គ ក៏សំដែងសេចក្ដី

ត្រេកអរអនុមោទនាភាសិតនៃគ្នានឹងគ្នា ។

ព្រះបុណ្ណត្ថេរនេះ ដកល់ខ្លួនលោកក្នុងគុណធម៌ដូចម្តេច ក៏លោកទូន្មានប្រដៅអ្នកដទៃឱ្យឋិតនៅក្នុងគុណធម៌ដូច្នោះដែរ ។ កាលស្តេចព្រះបរមសាស្តាស្តេចប្រថាប់នាកណ្តាលជំនុំសង្ឃ ទើបទ្រង់តាំងដំកើងព្រះបុណ្ណត្ថេរ ក្នុងដំណែងព្រះឯតទគ្គៈ គឺជាកំពូលនៃភិក្ខុទាំងឡាយប៉ែកខាងធម្មិកថិក ។ លុះលោកឋិតនៅក្នុងព្រះសាសនា ត្រាតែសមគួរដល់កំណត់អាយុសង្ខារហើយ ទើបលោករំលត់ខន្ធចូលកាន់បរិនិព្វាន ។

# ៣៦ - ប្រវត្តិព្រះកាឡុទាយិត្ថេរ

ព្រះកាឡុទាយិត្ថេរ ជាបុត្រមហាអាមាត្យនៅក្រុងកបិលពស្តុ. លោកកើតក្នុងថ្ងៃជាមួយនឹងព្រះមហាបុរសទ្រង់ប្រសូត រាប់ជាសហជាតិរបស់ព្រះអង្គ ។ ដើមឡើយ លោកឈ្មោះឧទាយី ព្រោះជាទីរីករាយនៃអ្នកស្រុក តមកក្រោយទៀត គេហៅឈ្មោះថា កាឡុទាយី ព្រោះលោកមានសម្បុរខ្មៅ ។ លុះលោកចំរើនវ័យធំឡើង លោកបានថ្វាយខ្លួនជាមហាតឡិក នៃមហាបុរសជាមួយនឹងនាយឆន្នៈ ។ កាលព្រះដ៏មានបុណ្យបានត្រាស់ហើយ ស្តេចប្រថាប់នៅនាក្រុងរាជគ្រឹះ ។ ព្រះបាទសុទ្ធោទនៈ ជាព្រះវររាជបិតា ទ្រង់ជ្រាបដំណឹងទើបទ្រង់ចាត់អាមាត្យឱ្យទៅនិមន្តព្រះអង្គមកកាន់ក្រុងកបិលពស្តុ ដល់៩លើកមិនបានសម្រេច តមក ទ្រង់យល់ថា កាឡុទាយីអាមាត្យ ជាទីប្រោសប្រាណនៃព្រះបរមគ្រូ ទាំងជាទីទុកព្រះទ័យរបស់ព្រះអង្គផង ទើបទ្រង់ចាត់លោកឱ្យ

ទៅនិមន្ត លោកក្រាបទូលសូមលាបួសផង ។ លុះព្រះមហាក្សត្រទ្រង់ព្រះរាជានុញ្ញាតហើយ ទើបលោកចូលទៅក្រាបថ្វាយបង្គំព្រះបរមគ្រូនៅវត្តវេឡុវន ក្រុងរាជគ្រឹះ បានស្តាប់ព្រះធម្មទេសនា សម្រេចអរហត្តហើយ លោកបានទទួលឧបសម្បទ ជាឯហិភិក្ខុក្នុងព្រះពុទ្ធសាសនា ។ ដល់រដូវប្រាំង ព្រះកាឡុទាយិត្ថេរ ក្រាបទូលនិមន្តព្រះពុទ្ធជាម្ចាស់ឱ្យស្តេចនិមន្តទៅកាន់ក្រុងកបិលពស្តុ ។ លោកនិមន្តហួសទៅមុន ដើម្បីថ្វាយពត៌មានដល់ព្រះមហាក្សត្រព្រះពុទ្ធបិតា ព្រមទាំងព្រះញាតិវង្សនឹងប្រជាជនទាំងឡាយ ឱ្យបានទ្រង់ជ្រាបបានដឹងអំពីព្រះពុទ្ធដំណើរ ។

លុះជនទាំងនោះបានដឹងដំណឹងថា លោកនិមន្តមកក៏មានសេចក្តីត្រេកអរជ្រះថ្លានាំគ្នាទទួលលោកជាឧឡារិក លោកបានដឹកនាំប្រជាជននឹងសាក្យវង្សទាំងឡាយ ឱ្យមានសទ្ធាជ្រះថ្លាក្នុងព្រះសាសនា ។ ព្រះបរមសាស្តាទ្រង់ប្រារព្ធដល់គុណសម្បត្តិ សបត្តភាពនេះរបស់លោក ទើបទ្រង់តាំងលោកក្នុងតំណែងប្រសើរលើសលែងភិក្ខុទាំងឡាយ ប៉ែកខាងញ៉ាំងត្រកូលមិនទាន់ជ្រះថ្លាឱ្យកើតសេចក្តីជ្រះថ្លាក្នុងព្រះសាសនា ។

លោកមានព្រះជន្មាយុក្នុងព្រះសាសនា គ្រាតែសមគួរដល់កាលកំណត់ហើយ ទើបរំលត់ខន្ធបរិនិព្វាន ។

## ៣៧~ប្រវត្តិព្រះនន្ទត្ថេរ

ព្រះនន្ទត្ថេរ ជាព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនៈពុទ្ធបិតា នឹងព្រះនាង

មហាបជាបតីគោតមី ក្រុងកបិលពស្តុ ។ តាំងពីលោកបានចាប់បដិសន្ធិក្នុងព្រះគភ៌នៃព្រះវរមាតា ព្រះញាតិទាំងឡាយ មានសេចក្តីត្រេកអររីករាយផង់ហើញចង់យល់ ហេតុនេះ ព្រះញាតិទាំងឡាយ ទើបថ្វាយព្រះនាមថា នន្ទកុមារ ។

កាលព្រះអង្គបានត្រាស់ដឹងហើយ ស្តេចត្រេចចារិកមកកាន់ក្រុងកបិលពស្តុ ប្រថាប់នៅនិគ្រោធារាម ទ្រង់សំដែងព្រះធម្មទេសនា ប្រកាសសុចរិតធម៌ ញ៉ាំងព្រះញាតិវង្សានុវង្ស មានព្រះបាទសុទ្ធោទនៈជាប្រមុខ ឲ្យកើតសទ្ធាជ្រះថ្លា ។

ថ្ងៃបួន មានព្រះរាជពិធីអាវាហវិវាហមង្គលអភិសេក នៃព្រះនន្ទកុមារនឹងនាងជនបទកល្យាណី ព្រះពុទ្ធជាម្ចាស់ស្តេចប្រថាប់សោយភត្តាហារ ក្នុងតំណាក់ព្រះនន្ទកុមារ ទ្រង់ធ្វើអនុមោទនារួចហើយ ដល់ទ្រង់យាងត្រឡប់ទៅវិញ ទ្រង់ហុចបាត្រឱ្យព្រះនន្ទកុមារទទួល ។ ព្រះកុមារដើរកាន់បាត្រតាមព្រះអង្គទៅដោយគិតថា បើទ្រង់ទទួលយកបាត្រក្នុងទីណាហើយ នឹងរាលប្រញាប់ត្រឡប់មកតំណាក់វិញ ប៉ុន្តែមិនហ៊ានទូលថាអ្វី ព្រោះមានសេចក្តីគោរពកោតខ្លាចព្រះអង្គពេក ។ ចំណែកឯព្រះនាងជាទេវីរបស់ព្រះនន្ទកុមារ បានឃើញអាការដូច្នោះ ទើបចូលផ្តាំថា សូមព្រះអយ្យបុត្រស្តេចប្រញាប់វិលមកវិញកុំខាន ។ លុះព្រះដ៏មានបុណ្យស្តេចយាងដល់ព្រះវិហារហើយ ទ្រង់ត្រាស់សួរព្រះនន្ទកុមារថា នន្ទៈ អ្នកនឹងបួសឬ ? -ព្រះនន្ទកុមារទោះបីមិនមានចិត្តស្ម័គ្រសោះ ប៉ុន្តែមិនអាចទូលទាស់ ព្រោះមានសេចក្តីគោរពច្រើន ទើបក្រាបបង្គំទូលថា បួស ទ្រង់ក៏ឱ្យបំបួសព្រះនន្ទកុមារ ។ កាលទ្រង់បានបួសហើយ ក៏នឹក

រលឹកដល់សំដីនាងទេវីដែលស្រែកផ្ដាំមកនោះ កើតចិត្តនឿយណាយធុញទ្រាន់ក្នុងការបំពេញសមណកិច្ចគិតចង់សឹកទៅវិញ ។ តមក សម័យក្រោយ ព្រះដ៏កាលព្រះពុទ្ធទ្រង់នាំព្រះនន្ទភិក្ខុត្រាច់ចារិកទៅ ក៏បានឃើញស្ត្រីរូបល្អជាងនាងទេវីនោះ ញុំាងព្រះនន្ទភិក្ខុឱ្យលះបង់សេចក្ដីស្រឡាញ់ស្នេហាចំពោះនាងទេវី ហើយប៉ុនប៉ងចង់បានស្ត្រីមានរូបឆើតជាងនោះទៅទៀត ត្រាតែព្រះនន្ទកើតបញ្ញាយល់ឃើញតាមពិតថា សេចក្ដីស្រឡាញ់មិនមានទីបំផុត ក៏បន្ទោបង់សេចក្ដីស្នេហាចេញបានជាអ្នកមិនប្រមាទ ខំបំពេញសេចក្ដីព្យាយាមក៏បានសម្រេចព្រះអរហត្តផល ។ លោកបានទទួលលើកដំកើងសរសើរ អំពីព្រះបរមសាស្ដាថា ប្រសើរលើសលែងភិក្ខុទាំងឡាយ ប៉ែកខាងសង្រួមរក្សាទ្វារឥន្ទ្រិយទាំង ៦ គឺ ភ្នែក. ត្រចៀក. ច្រមុះ. អណ្ដាត. កាយ. ចិត្ត. មិនឱ្យកើតសេចក្ដីត្រេកអរឬទោមនស្ស ដោយរំពាចលោភធម៌.ជាអ្នកប្រកបដោយបរិភាព ។ ព្រះនន្ទត្ថេរមានជន្មាយុក្នុងព្រះសាសនា ត្រាតែសមគួរដល់កាលកំណត់ហើយក៏រំលត់ខ័ន្ធបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ។

## ៣៨~ប្រវត្តិព្រះរាហុលត្ថេរ

ព្រះរាហុលត្ថេរ ជាព្រះពុទ្ធជិនោរសនឹងព្រះនាងយសោធរា ( ពិម្ពា) ជាព្រះរាជនត្តាព្រះបាទសុទ្ធោទនៈ ក្រុងកបិលពស្តុ ។ កាលព្រះអង្គបានត្រាស់ហើយ ស្ដេចយាងទៅទេសនាប្រោសព្រះញាតិវង្ស មានព្រះពុទ្ធបិតាជាដើមស្ដេចប្រថាប់នៅនិគ្រោធារាម ក្នុងក្រុងកបិលពស្តុ ។ ព្រះរាហុលកុមារទូល

ទៅគាល់ក្រាបទូលសូមរាជសម្បត្តិ ។ ព្រះអង្គទ្រង់ព្រះតម្រិះថា បណ្ដាធនសម្បត្តិដែលមានខ្លឹមសារជាថាវរៈហើយប្រសើរជាងគុណសម្បត្តិនោះមិនដែលមាន ហេតុនេះ ទើបទ្រង់សំដែងអរិយទ្រព្យ ៧ ប្រការ ហើយមានព្រះពុទ្ធដីកាឱ្យព្រះសារីបុត្របំបួសព្រះរាហុលកុមារជាសាមណេរ ព្រោះមានព្រះជន្មនៅក្មេងមិនសមគួរនឹងឧបសម្ប័ទជាភិក្ខុ លុះលោកបានបព្វជ្ជាជាសាមណេរដោយទទួលត្រៃសរណគមន៍ ចាត់ជាបឋមនៃការបព្វជ្ជាជាសាមណេរក្នុងព្រះពុទ្ធសាសនាហើយ ជាអ្នកគាប់ចិត្តនឹងការសិក្សារៀនសូត្រ អត់ធន់ចំពោះពាក្យទូន្មានប្រៀនប្រដៅលុះមានជន្មាយុ ១៨ វស្សាមានឥន្ទ្រិយធំមិចាស់ បានស្ដាប់ព្រះធម្មទេសនារាហុលោវាទសូត្រ នឹងចុល្លរាហុលោវាទសូត្រ អំពីសំណាក់ព្រះបរមសាស្ដា ។ លោកតែងត្រេចចារិកតាមព្រះដ៏មានបុណ្យ នឹងព្រះឧបជ្ឈាយ៍របស់លោក ដល់លោកមានជន្មាយុ ២០ វស្សាបរិបូណ៌ហើយ ទើបបានទទួលឧបសម្ប័ទជាភិក្ខុ ។ ថ្ងៃមួយ ព្រះរាហុលភិក្ខុនៅក្នុងព្រៃស្វាយមួយ ជិតក្រុងរាជគ្រឹះ ព្រះដ៏មានបុណ្យស្ដេចយាងទៅទីនោះលោកបានឃើញព្រះអង្គរពីចម្ងាយ ក៏ក្រាលអាសនៈទុក ដកល់ទឹកលាងព្រះបាទបំរុងទុក ។ ព្រះបរមគ្រូស្ដេចទៅដល់ហើយទ្រង់ប្រថាប់លើអាសនៈនោះហើយ ទ្រង់លាងព្រះបាទហើយ ទ្រង់លើកភាជនៈទឹកនោះឡើង ទ្រង់ត្រាស់សួរលោកថា ម្នាលរាហុលបាបានឃើញភាជនៈទឹកនេះគ្មានទឹកឬទេ ? ព្រះរាហុលក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស គ្មានទឹកទេ ។

ព្រះ- ខនេះយ៉ាងណោ. សមណគុណរបស់ជនដែលគ្មានខ្មាសក្នុងការ

ក្លែងពោលពាក្យភូតភរ ក៏សោះទទេមិនមានយ៉ាងនោះដែរ ។ អ្នកណាមិនមានសេចក្តីអៀនខ្មាស ក្នុងការក្លែងពោលពាក្យកុហក. អ្នកនោះ នឹងមិនធ្វើអំពើអាក្រក់យ៉ាងណានិមួយ មិនដែលមាន. ហេតុនេះ ចូលបាសិក្សាថា អញនឹងមិននិយាយកុហកឡើ‌ង ។ ម្នាលរាហុល. កញ្ចក់មានប្រយោជន៍ដូចម្តេច ?

រា.- "សូមទ្រង់ព្រះមេត្តាប្រោស. មានប្រយោជន៍សម្រាប់ឆ្លុះ ។

ព្រះ.- "កញ្ចក់នេះយ៉ាងណា បញ្ញាក៏មានប្រយោជន៍សម្រាប់ឆ្លុះយ៉ាងនោះដែរ បាគប្បីពិចារណាតិះរិះជាមុនសិន សឹមធ្វើកិច្ចការដោយកាយវាចាចិត្ត បាចង់ធ្វើការអ្វី គប្បីពិចារណាមើលឱ្យល្អសិន បើដឹងថាអំពើនេះប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនក្តី ដើម្បីបៀតបៀនអ្នកដទៃក្តី ដើម្បីបៀតបៀនទាំងខ្លួនឯងទាំងអ្នកដទៃក្តី ជាអកុសលមានផលជាទុក្ខ ការងារដូច្នេះ កាយមិនគួរធ្វើទេ ។ បើដឹងថាអំពើនេះមិនប្រព្រឹត្តទៅដើម្បីបៀតបៀនដូច្នោះទេ ជាបុណ្យកុសលមានផលជាសុខ ការងារដូច្នោះ បានគួរធ្វើ ។ សូម្បីក្នុងខណៈដែលធ្វើក៏គប្បីពិចារណាយ៉ាងនេះដែរ បើដឹងថាប្រកបដោយទោសដូចពោលហើយ បាគប្បីវៀរចេញ បើដឹងថាមិនមានទោសទេ គប្បីសង្វាតធ្វើទៅចុះ. សូម្បីបានធ្វើហើយ ក៏គប្បីពិចារណាយ៉ាងនេះដែរ បើដឹងថាមានទោស បើជាកាយកម្មវចីកម្ម បាគប្បីសំដែងបើកឱ្យប្រាកដច្បាស់ក្នុងសំណាក់គ្រូឬសព្រហ្ម-ចារីដទៃទៀត សង្រួមប្រយ័ត្នតទៅ ។ បើជាមនោកម្ម បាគប្បីនឿយណាយខ្មាសខ្ពើមហើយប្រុងប្រយ័ត្នតទៅ. បើដឹងថាគ្មានទោសទេ, បាគប្បីនៅដោយបីតិរីករាយ ឧស្សាហ៍សិក្សាក្នុងធម៌ដែលជាបុណ្យ ជាកុសលរាល់យប់ថ្ងៃ.

ម្នាលរាហុល សមណព្រាហ្មណ៍ឯណាមួយក្នុងកាលកន្លងទៅហើយ បានជម្រះការងារដោយកាយវាចាចិត្តឱ្យបរិសុទ្ធហើយ. សមណព្រាហ្មណ៍ទាំងអស់នោះសុទ្ធតែបានពិចារណាឃើញហើយយ៉ាងនេះឯង. ទោះបីសមណព្រាហ្មណ៍ក្នុងកាលខាងមុខក្តី ក្នុងកាលឥឡូវនេះក្តី ក៏ដូច្នេះដែរ ហេតុនេះ គប្បីសិក្សាថា អញនឹងពិចារណាហើយជម្រះកាយកម្ម វចីកម្ម. មនោកម្មឱ្យបរិសុទ្ធ គប្បីសិក្សាកំណត់ទុកក្នុងចិត្តយ៉ាងនេះចុះ ។ ព្រះបរមសាស្តាត្រាស់ទូន្មានព្រះរាហុលដូច្នេះហើយ ទើបស្តេចយាងត្រឡប់ទៅវិញ ។

ថ្ងៃមួយព្រះរាហុលចូលទៅគាល់ ព្រះបរមសាស្តាត្រាស់ទូន្មានក្នុងរូបកម្មដ្ឋាន គឺដី. ទឹក. ភ្លើង. ខ្យល់. អាកាសធាតុ. ថារបស់ទាំងនេះ មានទាំងខាងក្នុងទាំងខាងក្រៅ ។ របស់ឯណាប្រព្រឹត្តទៅចំពោះខ្លួន គឺដែលបុគ្គលកំណត់ថាជារបស់ខ្លួន របស់នោះហៅថាធាតុខាងក្នុង ធាតុ ៥ ខាងក្នុងក្តី ខាងក្រៅក្តី ក៏គ្រាន់តែជាធាតុមួយយ៉ាងណា១ ប៉ុណ្ណោះ គប្បីឃើញដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតថា របស់នោះមិនមែនជារបស់អញ. របស់នោះមិនមែនជាអញ. របស់នោះមិនមែនជាខ្លួនរបស់អញ. កាលបើឃើញយ៉ាងនេះហើយរមែងនឿយណាយ. ធ្វើចិត្តកុំឱ្យកើតតម្រេកក្នុងធាតុទាំង ៥ នេះ ។ ម្នាលរាហុលចាចូរចំរើនភាវនាធ្វើចិត្តឱ្យស្មើដោយ ដី. ទឹក. ភ្លើង. ខ្យល់. អាកាស. ព្រោះថាបើបាធ្វើបានយ៉ាងនេះ អារម្មណ៍ដែលមកប៉ះពាល់ជាទីគាប់ចិត្ត មិនជាទីគាប់ចិត្តក្តី ដែលកើតឡើងហើយ មិនអាចគ្របសង្កត់ចិត្តឋិតនៅបានទេប្រៀបដូចជាជនទាំងឡាយបោះរបស់ស្អាតខ្លះស្មោកគ្រោកខ្លះចុះក្នុងផែនដី.

ក្នុងទឹក. ក្នុងភ្លើង. ខ្យល់បក់របស់ស្អាតខ្លះ មិនស្អាតខ្លះដី ទឹក ភ្លើង ខ្យល់ ក៏មិនស្រឡាញ់ មិនស្អប់ឡើយ អាកាសក៏មិនជាប់ជំពាក់ក្នុងទីណាមួយឡើយ ការឧបមាយ៉ាងណា ។ ចូរចំរើនភាវនាធ្វើចិត្តឱ្យស្មើដោយដី. ទឹក. ភ្លើង. ខ្យល់. អាកាស. មានឧបមេយ្យដូច្នេះដែរ ។ កាលបើបាធ្វើបានយ៉ាងនេះ អារម្មណ៍ដែលមកប៉ះពាល់ជាទីគាប់ចិត្តក្ដី ។ មិនជាទីគាប់ចិត្តក្ដី ដែលកើតឡើងហើយនឹងមិនគ្របសង្កត់ចិត្តឋិតនៅបានឡើយ ។

លុះព្រះបរមគ្រូត្រាស់ទូន្មានក្នុងរូបកម្មដ្ឋានដទៃទៀតតទៅថា ម្នាលរាហុល ចាបចូរចំរើនភាវនា គឺមេត្តា គិតឱ្យពពួកសត្វបានសុខទូទៅ. ករុណាគិតឱ្យពពួកសត្វផុតចោលទុក្ខរាល់គ្នា. មុទិតា រីករាយត្រេកអរព្រោះសម្បត្តិដែលអ្នកដទៃបាន. ឧបេក្ខា ព្រងើយកន្តើយ តាំងចិត្តជាកណ្ដាលមិនចូលទៅខាងណា. អសុភ ពិចារណារាងកាយឱ្យឃើញជាមិនល្អ មិនស្អាត. អនិច្ចសញ្ញា ពិចារណាឃើញសង្ខារថាមិនទៀង ។ កាលបើបានចំរើនមេត្តា នឹងលះសេចក្ដីព្យាបាទអ្នកដទៃចេញបាន. ចំរើនករុណានឹងលះវិហឹសា ការគិតបៀតបៀនអ្នកដទៃចេញបាន. ចំរើនមុទិតា នឹងលះឥស្សានឹងអរតិ សេចក្ដីមិនត្រេកអរចេញបាន. ចំរើនឧបេក្ខា នឹងលះសេចក្ដីគាប់ចិត្ត នឹងមិនគាប់ចិត្តចេញបាន. ចំរើនអសុភ នឹងលះតម្រេកត្រេកត្រអាលក្នុងរូបខ្លួននឹងរូបអ្នកដទៃចេញបាន. ចំរើនអនិច្ចសញ្ញា នឹងលះមានះ សេចក្ដីប្រកាន់ខ្លួនចេញបាន ។ មួយវិញទៀត ចូរចាចំរើនភាវនា គឺតាំងសតិកំណត់ខ្យល់ដង្ហើមចេញចូល ព្រោះភាវនានេះ បុគ្គលបានចំរើនអប់រំឱ្យច្រើនហើយ រមែងមានផលានិសង្សច្រើន. ធ្វើមិនឱ្យ

វង្វេងភ្លេចភ្លាំងស្មារតី ។

លុះទ្រង់ទូន្មានចប់ហើយ ព្រះរាហុលក៏មានចិត្តត្រេកអរទទួលយកព្រះឱវាទដោយគោរព តមកសម័យក្រោយទៀត លោកបានស្តាប់ព្រះឱវាទដែលទ្រង់ទូន្មានខាងផ្លូវវិបស្សនា ទ្រង់លើកយកអាយតនៈខាងក្នុងខាងក្រៅជាដើម ទ្រង់សំដែងថាជា អនត្តា មិនមែនជាខ្លួនប្រាណ ។ល។ ព្រះរាហុលត្ថេរបញ្ជូនចិត្តទៅតាមក្រសែព្រះធម្មទេសនានេះ ក៏បានសម្រេចអរហត្តផល ។ ព្រះរាហុលត្ថេរនេះ ប្រាកដថាជាអ្នកយកចិត្តទុកដាក់ម៉ឺងការសិក្សាធម្មវិន័យ ចាប់អំពីកាលលោកនៅជាសាមណេរ ហេតុនេះ កាលព្រះអង្គទ្រង់ប្រកាសកណ្តាលជំនុំសង្ឃ ទើបទ្រង់តាំងព្រះរាហុលត្ថេរ ក្នុងទីឯតទគ្គៈ គឺជាកំពូលនៃភិក្ខុទាំងឡាយ អ្នកប្រាថ្នាតិចការសិក្សាធម្មវិន័យ ។ លុះលោកមានជន្មាយុគ្រប់កំណត់ហើយ ទើបរំលត់ខន្ធចូលកាន់បរិនិព្វាន ក្នុងឋានសួគ៌ជាន់តាវត្តឹង្ស ។

## ៣៩~ប្រវត្តិព្រះឧបាលិត្ថេរ

ព្រះឧបាលិត្ថេរ កើតក្នុងត្រកូលជាងកោរកាត់ក្នុងក្រុងកបិលពស្តុ មាននាមថាឧបាលី កាលមានវ័យចំរើនឡើងហើយ ជាទីសព្វព្រះទ័យនៃពួកក្សត្រសាក្យវង្ស ហើយបានទទួលនាទីជានាយភូសាមាលានៃរាជវង្សសាក្យៈ ។ លុះព្រះដ៏មានបុណ្យស្តេចមកប្រថាប់នៅអនុបិយកម្ពវនារាម ឧបាលីបានចេញទៅបួសក្នុងព្រះសាសនា ជាមួយនឹងក្សត្រ ៦ អង្គ គឺព្រះអនុរុទ្ធ. កិម្ពិល. ភគ្គុ. អានន្ទនឹងទេវទត្ត ហើយបានទទួលឧបសម្បទមុនគេតាមព្រះបំណងនៃក្សត្រ

ទាំងនោះ ។ កាលបានឧបសម្បទហើយ លោកបានធ្វើសេចក្តីព្យាយាមចំរើនវិបស្សនាកម្មដ្ឋានមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្ត បែកធ្លុះធ្លាយស្ទាត់ជំនាញក្នុងវិន័យបិដក ។ តមក លោកបានទទួលនាំវិនិច្ឆ័យវត្ថុ ៣ ប្រការ គឺ ភារុកច្ឆវត្ថុ. អជ្ជុកវត្ថុ. កុមារកស្សបវត្ថុ. នឹងព្រះបរមសាស្តាៗ ទ្រង់ធ្វើវិនិច្ឆ័យទាំង ៣ ប្រការនេះឱ្យជាហេតុទើបទ្រង់តាំងព្រះឧបាលិត្ថេរ ក្នុងតំណែងឯតទគ្គដ្ឋាន គឺជាកំពូលនៃភិក្ខុទាំងឡាយ បែកចាងទ្រទ្រង់វិនយបិដក ដូច្នេះ ។

អាស្រ័យគុណសម្បត្តិនេះឯង កាលព្រះមហាកស្សបប្រជុំសង្ឃធ្វើបឋមសង្គាយនា ជំនុំសង្ឃបានអារាធនាលោកឱ្យជាអ្នកវិសជ្ជនាវិនយបិដក ចាត់ជាព្រះមហាសាវ័កសំខាន់អង្គ១ជាក់កំឡាំងធំក្នុងការតអាយុព្រះសាសនា ។ លុះលោកមានព្រះជន្មគ្រប់កំណត់ហើយ ទើបចូលបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។

## ៤០~ប្រវត្តិព្រះភទ្ទិយត្ថេរ សាក្យរាជ

ព្រះភទ្ទិយត្ថេរ ជាព្រះឱរសរបស់ព្រះនាង កាឡិគោធាសាក្យកញ្ញាក្នុងខត្តិយត្រកូល ក្រុងកបិលពស្តុ កាលមានវ័យវឌ្ឍនាការសមរម្យ បានទទួលអភិសេកឱ្យគ្រងរាជសម្បត្តិ ។ តមកសម័យក្រោយព្រះភទ្ទិយសាក្យរាជបានទទួលពន្យល់ដឹកនាំ អំពីព្រះអនុរុទ្ធសាក្យជាសំឡាញ់ចាស់ ក្នុងការចេញទៅបួសតាមព្រះដ៏មានបុណ្យ ទើបទ្រង់លះបង់រាជសម្បត្តិចេញទៅទ្រង់ព្រះផ្នួសក្នុងព្រះពុទ្ធសាសនា ព្រមទាំងព្រះអនុរុទ្ធ កិម្ពិលៈ ភគុ. អានន្ទ. ឧបាលិ

រូប ៧ អង្គ ក្នុងគ្រាដែលព្រះដ៏មានបុណ្យប្រថាប់នៅអនុបិយអម្ពវ័ន ក្បែរដែនមលរដ្ឋ ។ លុះទ្រង់បានបព្វជ្ជាឧបសម្បទាហើយ ទ្រង់បានធ្វើសេចក្ដីព្យាយាមចំរើនសមណធម៌ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត ក្នុងវស្សាដែលទ្រង់ព្រះផ្នួសនោះឯង ។ លុះបានសម្រេចអរហត្តហើយ ទោះលោកទំមន្តទៅក្នុងព្រៃក្ដី គង់ក្រោមម្លប់ឈើក្ដី នៅក្នុងផ្ទះស្ងាត់ក្ដី លោកហែបន្លឺឧទានវាចាថា សុខហ្ន៎ៗ ដូច្នេះជារឿយៗ ។ ភិក្ខុទាំងឡាយនាំសេចក្ដីនេះក្រាបបង្គំទូលព្រះដ៏មានបុណ្យថាព្រះភទ្ទិយត្ថេរបន្លឺឧទានយ៉ាងនេះគង់មិនត្រេកអរទឹងប្រព្រឹត្តព្រហ្មចរិយធម៌ គិតនឹកទៅដល់សេចក្ដីសុខក្នុងរាជសម្បត្តិជាប្រាកដ ។ ព្រះបរមគ្រូបានព្រះពុទ្ធដីកាឱ្យហៅព្រះភទ្ទិយត្ថេរមកគាល់ត្រាស់សួរថា ភទ្ទិយៈ ឮថា អ្នកបន្លឺឧទានយ៉ាងនេះមែនឬ ? -ព្រះភទ្ទិយត្ថេរក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោសមែន ។ -ចុះអ្នកបានឃើញអំណាចប្រយោជន៍ដូចម្ដេច ទើបបន្លឺឧទានយ៉ាងនេះ ? -កាលពីមុននេះ ខ្ញុំព្រះអង្គជាក្សត្រទ្រទ្រង់ដែនដី តោងចាត់ការរក្សាការពារ ទាំងខាងក្នុងវាំង ទាំងខាងក្រៅវាំង ទាំងខាងក្នុងស្រុក ទាំងខាងក្រៅស្រុក រហូតព្រះរាជអាណាខេត្តទាំងមូល ខ្លួនខ្ញុំព្រះអង្គសូម្បីមានមនុស្សចាំថែទាំរក្សា យ៉ាងនេះហើយ នៅតែភ័យខ្លាចភ្ញាក់ផ្អើលជានិច្ច ត្រូវប្រុងប្រយ័ត្នខ្លួនជានិច្ច ។ ដល់មកឥឡូវនេះទោះខ្ញុំព្រះអង្គនៅក្នុងព្រៃស្ងាត់ក្ដី ទោះនៅក្រោមម្លប់ឈើក្ដី ទោះនៅក្នុងទីស្ងាត់ដទៃៗ ក្ដី មិនខ្លាច. មិនតក់ស្លុត. មិនរង្កៀស. មិនភ្ញាក់ផ្អើល. មិនបាច់ខ្វល់ខ្វាយ. មានរោមសម្រេបជាប្រក្រតី. មិនព្រឺរោមព្រោះខ្លាច. អាស្រ័យអាហារដែលអ្នកដទៃបានសម្រាប់

រំលោភជីវិត. កោឯពិត្តដូចប្រេត. ខ្ញុំព្រះអង្គបានឃើញអំណាចប្រយោជន៍យ៉ាងនេះ ទើបបានបន្លឺឧទាននេះ ។ ព្រះបរមសាស្ដាទ្រង់ត្រាស់ប្រទានសំពួលសាធុការថា សាធុៗ ភទ្ទិយៈអ្នកបន្លឺឧទានប្រពៃហើយ ។ សម័យ ១ ព្រះដ៏មានបុណ្យស្ដេចប្រថាប់នៅ ព្រះជេតវនមហាវិហារ ទ្រង់តាំងព្រះភទ្ទិយត្ថេរ ក្នុងតំណែងឯកទគ្គៈ គឺជាកំពូលនៃភិក្ខុទាំងឡាយ ដ៏មានត្រកូលខ្ពស់ ។

មានពាក្យចោទសួរថា ភិក្ខុទាំងឡាយដទៃទៀតមានត្រកូលខ្ពស់នោះមានច្រើនអង្គណាស់ ចុះហេតុដូចម្ដេច ព្រះបរមសាស្ដាទ្រង់តាំងក្នុងឯតទគ្គដ្ឋានតែមួយអង្គ មិនទៅជាមុខោលោកនេះឬ ? -វិសជ្ជនាថាភិក្ខុឯទៀតៗ ដែលមានត្រកូលខ្ពស់ៗ មានច្រើនក៏ពិតមែន ប៉ុន្តែព្រះភទ្ទិយត្ថេរនេះ កាលមិនទាន់ចេញមកបួសនោះ លោកជាស្ដេចគ្រងរាជសម្បត្តិក្នុងសាក្យត្រកូល រួចហើយលោលះបង់រាជសម្បត្តិស្ដេចចេញទ្រង់ព្រះផ្នួសបាន។ ប្រការមួយទៀត ព្រះភទ្ទិយ-ត្ថេរនេះកាលអំពីអតីតជាតិ លោកបានថ្វាយបិណ្ឌបាតដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានរហូត ៧ ថ្ងៃហើយ បានតាំងសេចក្ដីប្រាថ្នាចំពោះឯតទគ្គដ្ឋាននេះហេតុនេះទើបព្រះបរមសាស្ដាទ្រង់ប្រទានឯតទគ្គដ្ឋាន តាមសេចក្ដីប្រាថ្នារបស់លោកក្នុងអតីតជាតិមិនមែនព្រះអង្គទ្រង់មុខោលោកនៈឡើយ ។ ព្រះភទ្ទិយ-ត្ថេរមានព្រះជន្មាយុក្នុងព្រះសាសនា តាមសមគួរដល់កាលកំណត់ហើយក៏រំលត់ខ័ន្ធបរិនិព្វាន ។

****

# ៤១-ប្រវត្តិព្រះអនុរុទ្ធត្ថេរ

ព្រះអនុរុទ្ធត្ថេរ ជាព្រះឱរសរបស់ព្រះអមិតោទនសាក្យៈ ដ៏ជាព្រះអនុជរបស់ព្រះបាទសុទ្ធោទនសាក្យរាជ ក្នុងក្រុងកបិលពស្តុ ។ លោកមានបងប្អូនរួម ៣ អង្គ ជាប្រុសពីរគឺមហានាម ១ អនុរុទ្ធ ១ ស្រីមួយ គឺរោហិណី រាប់តាមព្រះវង្ស ខ្លួនលោកត្រូវជាព្រះអនុជនៃព្រះបរមសាស្តា ។ អនុរុទ្ធកុមារនេះ ជាក្សត្រសុខុមាលជាតិ. ប្រកបដោយសេចក្តីសុខមានបុណ្យច្រើន. បរិបូណ៌សោយភោគសម្បត្តិគ្រប់ប្រការ សូម្បីពាក្យថា មិនមានឬគ្មាន ក៏លោកមិនដែលឮឡើយ ។

ក្នុងសម័យមួយនោះ ព្រះបរមសាស្តាស្តេចប្រថាប់នៅអនុបិយនិគមរបស់មល្លក្សត្រ ។ គ្រានោះ សាក្យកុមារទាំងឡាយ នាំគ្នាចេញបួសតាមព្រះបរមសាស្តាជាច្រើនអង្គ ។ ទើបថ្ងៃ ១ មហានាមសាក្យៈជាព្រះជេដ្ឋាអនុរុទ្ធ-សាក្យៈ ពោលប្រារព្ធនឹងអនុរុទ្ធជាប្អូនថា ពាអនុរុទ្ធ. ខាងពួកយើងនេះ មិនទាន់មានអ្នកណាមួយចេញទៅបួសតាមព្រះអង្គសោះ គួរតាឬបងណាមួយចេញបួសទើបសមគួរ ។ អនុរុទ្ធសាក្យៈឆ្លើយថា ប្អូនជាអ្នកធ្លាប់តាំងនៅក្នុងសេចក្តីសុខ មិនទៅបួសទេ សូមឱ្យបងបួសតែឯងចុះ ។ ទើបមហានាមសាក្យៈពោលថា បើបានៅគ្រប់គ្រងផ្ទះ ត្រូវសិក្សាឱ្យចេះដឹងកិច្ចការរបស់អ្នកគ្រប់គ្រងផ្ទះសព្វគ្រប់ ហើយអធិប្បាយពន្យល់អំពីរបៀបធ្វើស្រែ តាំងពីចាប់ធ្វើដំបូងរហូតដល់ចប់វិធីធ្វើស្រែ ក្នុងវេលានោះ អនុរុទ្ធសាក្យៈនៅក្មេងកម្លោះ

ប៉ុន្តែបងនៅព្រួតព្រាបើបេការងារអ្វីសោះ រវល់តែលេងសប្បាយ កាលបាន ស្ដាប់មហានាមដំណាលទូន្មានអំពីការងារនៃអ្នកនៅគ្រប់គ្រងផ្ទះដូច្នោះ សួរ សោកទៅបានជ្រាបថា ការងារមិនចេះអស់មិនចេះហើយ ដល់កាលណាយើងបាន ឈប់សំរាកមិនបាច់ខ្វល់ខ្វាយបំរើខ្លួនដោយកាមគុណ ក៏កើតគំនិតនឿយណាយ ទើបឆ្លើយថ្កានមហានាមជាបងថា បងរៀនឱ្យចេះដឹងប្រយោជន៍នៃអ្នកគ្រប់គ្រងផ្ទះតែឯងចុះប្អូននឹងទៅបួសវិញ ។ លុះអនុរុទ្ធសាក្យៈពោលយ៉ាងនេះ ហើយទើបចូលទៅរកព្រះមាតាពោលសូមអនុញ្ញាតចេញទៅបួស ។ ព្រះមាតា តបថា អនុរុទ្ធខ្លួនជាកូនរបស់បាទាំងពីរនាក់ជាកូនសំឡាញ់ពេញចិត្តរបស់ ម្ដាយណាស់ ទោះបីបាទាំងពីរត្រូវស្លាប់ម្ដាយក៏មិនចង់ព្រាត់ប្រាសចាកបាឡើយ ទៀត បានៅរស់ត្រឡប់ ធ្វើម្ដេចម្ដាយនឹងព្រមឱ្យបាចេញទៅបួស ។ អនុរុទ្ធ-សាក្យៈ ក៏នៅតែទូលអង្វរទទូចអនុញ្ញាតចេញទៅបួសជាច្រើនដង ។ ទើបព្រះ មាតាគិតថា ព្រះបាទភទ្ទិយៈជាសម្លាញ់របស់អនុរុទ្ធ លោកគង់មិនអាចចេញ ទៅបួសទេ ទើបពោលថា បាអនុរុទ្ធ បើព្រះបាទភទ្ទិយៈបួសចូរបាបួសជាមួយ ផងចុះ ។ អនុរុទ្ធបានស្ដាប់ដូច្នោះហើយ ក៏ចូលទៅគាល់ព្រះបាទភទ្ទិយៈ ទូល តាមវោហារដែលធ្លាប់ស្និទ្ធស្នាលគ្នាថា សម្លាញ់អើយ បព្វជ្ជារបស់ខ្ញុំជាប់ទាក់ ទងនឹងបព្វជ្ជារបស់លោក ។ ព្រះភទ្ទិយៈសាក្យរាជត្រាស់តបថា កុំឱ្យជាប់ទាក់ ទងឡើយ សម្លាញ់. ចូរអ្នកទៅបួសតាមស្រួលចុះ ។ អនុរុទ្ធទូលថាទៅជាមួយ គ្នាហោសម្លាញ់ យើងនឹងបួសជាមួយគ្នាទាំងពីរនាក់ ។ ព្រះបាទភទ្ទិយៈត្រាស់ ថា យើងមិនអាចទៅបួសទេ បើការឯទៀតដែលយើងអាចធ្វើ យើងនឹងធ្វើឱ្យ

អ្នកបាន. ចូរអ្នកទៅបួសតែម្នាក់ឯងចុះ ។ អនុរុទ្ធទូលថា ព្រះមាតាត្រាស់នឹងខ្ញុំថា បើព្រះបាទភទ្ទិយៈបួសផង ចូរបាបួសចុះ បើលោកមិនបួស បញ្ហារបស់យើងក៏នៅតែជាប់ទាក់ទងនឹងលោក. សម្លាញ់អើយ យើងចេញទៅបួសជាមួយគ្នាទាំងពីរនាក់ ។ នៅទីបំផុត ព្រះបាទភទ្ទិយៈ ក៏យល់ព្រម ទើបត្រាស់សុំឲ្យបង្អង់ ៧ ឆ្នាំសិន ដល់កន្លង ៧ ឆ្នាំទៅ សូមចេញបួសជាមួយគ្នា ។ អនុរុទ្ធទូលថា យឺតយូរណាស់ សម្លាញ់ ខ្ញុំមិនអាចរង់ចាំដល់ ៧ ឆ្នាំទេ ។ ព្រះភទ្ទិយ-សាក្យរាជ ក៏ទ្រង់សុំបន្ថយចុះមកជាលំដាប់រហូតដល់៧ថ្ងៃ ។ ទើបអនុរុទ្ធយល់ព្រមហើយទៅបបួលសាក្យៈ ៤ អង្គទៀត គឺអានន្ទ. ភគ្គុ. កិម្ពិលៈ និងកោលិយៈ គឺទេវទត្តរួមជា ៧ នាក់ទាំងឧបាលី ដែលជាភ្នាក់ងារកូសាមាលា បានព្រមស្រុះស្រួលគ្នាចេញអំពីក្រុងកបិលពស្តុ ចូលទៅគាល់ព្រះបរមសាស្ដា ឯអនុបិយនិគម ដែនមល្លរដ្ឋ ។ មុននឹងបួស សាក្យៈទាំងនោះ ក្រាបទូលថា ខ្ញុំព្រះអង្គទាំងឡាយជាសាក្យៈមានទិដ្ឋិមានះប្រកាន់ខ្លួនណាស់ ឧបាលីនេះជាមនុស្សបម្រើរបស់ខ្ញុំព្រះអង្គទាំងឡាយមកយូរហើយ សូមព្រះអង្គបង្គាប់បំបួសឧបាលីមុនចុះ ពួកខ្ញុំព្រះអង្គនឹងបានធ្វើកិច្ចក្រាបសំពះ ក្រោកទទួលនឹងកិច្ចដទៃទៀតដល់ឧបាលី. ខ្ញុំព្រះអង្គទាំងឡាយនឹងបានលះបង់នូវមានៈសេចក្ដីប្រកាន់ខ្លួនជាសាក្យៈចេញបាន ។ ព្រះបរមគ្រូក៏ទ្រង់អនុម័តិតាមចំណង់ ។

លុះព្រះអនុរុទ្ធសាក្យៈបានបួសហើយ បានរៀនព្រះកម្មដ្ឋានក្នុងសំណាក់ព្រះសារីបុត្រ ។ ថ្ងៃមួយ លោកនិមន្តទៅកាន់ព្រៃបាចីនវង្សមិគទាយវន ដ៏ជាទីស្ងាត់ ខំចំរើនសមណធម៌ ត្រិះរិះដល់ធម្មវិន័យថា ធម៌នេះរបស់អ្នកមាន

ប្រាថ្នាតិច. មិនមែនរបស់អ្នកប្រាថ្នាច្រើន. ធម៌នេះរបស់អ្នកសន្តោស ត្រេកអរនឹងរបស់ដែលមាន. មិនមែនរបស់អ្នកឥតសន្តោសទេ. . . . របស់អ្នកស្ងាត់ មិនមែនរបស់អ្នកត្រេកអរនឹងពួកគណៈ. . . . របស់អ្នកប្រារព្ធព្យាយាមមិនមែនរបស់អ្នកខ្ជិលច្រអូស . . . របស់អ្នកមានសតិខ្ជាប់ខ្ជួន មិនមែនរបស់អ្នកវង្វេងស្មារតី . . . របស់អ្នកមានចិត្តតាំងមាំ មិនមែនរបស់អ្នកមានចិត្តតាំងមាំ . . . របស់អ្នកមានបញ្ញា មិនមែនរបស់អ្នកឥតបញ្ញា ។ លុះព្រះបរមសាស្ដាស្ដេចនិមន្តទៅដល់បានទ្រង់ជ្រាបថា ព្រះអនុរុទ្ធបានត្រិះរិះដូច្នោះ ក៏ទ្រង់ត្រាស់អនុមោទនាថា សាធុៗ អនុរុទ្ធ. អ្នកបានត្រិះរិះនូវធម៌ដែលមហាបុរសធ្លាប់ត្រិះរិះប្រពៃហើយ បើដូច្នេះចូរអ្នកត្រិះរិះដល់ធម៌ដែលមហាបុរសធ្លាប់ត្រិះរិះជាគំរប់ ៨ តទៅទៀតថា ធម៌នេះរបស់អ្នកត្រេកអរក្នុងធម៌ដែលមិនធ្វើឱ្យយឺតយូរ មិនមែនរបស់អ្នកត្រេកអរក្នុងធម៌ដែលធ្វើឱ្យយឺតយូរទេ ។ ព្រោះអ្នកបានត្រិះរិះដល់ធម៌ដែលមហាបុរសបានត្រិះរិះទាំង ៨ ខនេះ អ្នកនឹងលុះឈាន ទី១ ទី២ ទី៣ ទី៤ តអំពីនោះបង្សុកូលចីវរនឹងប្រាកដដល់អ្នកដូចជាហិបសំពត់ពេញទៅដោយសំពត់ជ្រលក់ផ្សេងៗ របស់គហបតីឬរបស់បុត្រគហបតី. ភោជនៈគឺដុំបាយដែលបានដោយកំឡាំងស្នងជើងនឹងប្រាកដដល់អ្នកដូចបាយស្រូវសាលីបរិសុទ្ធឥតមន្ទិល មានម្ហូបច្រើនមុខរបស់គហបតីឬរបស់បុត្រគហបតី. សេនាសនៈ គឺគល់ឈើនឹងប្រាកដដល់អ្នក ដូចផ្ទះកំពូលប្រកលាបដោយកំបោរប្រពៃហើយទាំងខាងក្នុងទាំងខាងក្រៅ មានសន្ទឹកបង្អួចជិតស្និទ្ធល្អ របស់គហបតីឬបុត្រគហបតី. ទីដេកទីអង្គុយដែលក្រាលដោយស្មៅនឹង

ចំបើង នឹងប្រាកដដល់អ្នក ដូចបល្ល័ង្កប្រដាប់ដោយកម្រាលដ៏វិចិត្រមានមាស នឹងប្រាក់ជាដើម របស់គហបតីឬបុត្ររបស់គហបតី. ថ្នាំព្រាំដោយទឹកម្ទេស នឹងប្រាកដដល់អ្នក ដូចថ្នាំផ្សេងៗ មានសប្បិ. នវនីត. ប្រេង. ទឹកឃ្មុំ. ទឹកអំពៅជាដើម របស់គហបតីឬបុត្រគហបតី ដូច្នោះ ។

ឯព្រះអនុរុទ្ធត្ថេរ កាលបានស្តាប់ព្រះពុទ្ធដីកាដូច្នោះហើយ ក៏ខំបំពេញសេចក្តីព្យាយាម ក៏បានសម្រេចអរហត្តផល ។ ថ្ងៃមួយភិក្ខុទាំងឡាយចូលទៅរកហើយសួរលោកថា លោកដ៏មានអាយុ កាលដែលភារៈជារបស់អ្នកនេះជីវផ្សេងៗ ព្រោះបានចំរើនធម៌អ្វី ? -ព្រោះខ្ញុំករុណាបានចំរើនសតិបដ្ឋានទាំង ៤ គឺពិចារណាឃើញក្នុងកាយថាគ្រាន់តែជាកាយ. ពិចារណាឃើញក្នុងវេទនាគ្រាន់តែជាវេទនា. ពិចារណាឃើញក្នុងចិត្តគ្រាន់តែជាចិត្ត. ពិចារណាឃើញក្នុងធម៌គ្រាន់តែជាធម៌ មានសេចក្តីព្យាយាមមានសតិសម្បជញ្ញៈ នាំចេញនូវអភិជ្ឈា នឹងទោមនស្ស ដូច្នេះ ។ លោកពោលសរសើរអ្នកដែលចំរើនសតិបដ្ឋាន ទាំង ៤ ឱ្យភិក្ខុទាំងឡាយស្តាប់ ដោយឧបមាដូចទន្លេគង្គាដែលហូរទៅទិសខាងកើត មហាជននាំគ្នាមកដោយសង្ឃឹមថានឹងទប់ឱ្យត្រឡប់ហូរទៅក្រោយវិញ តើអ្នកទាំងឡាយសំគាល់សេចក្តីនេះដូចម្តេច តើនឹងធ្វើដូច្នោះបានឬទេ ? -ធ្វើមិនបានឡើយ លោកដ៏មានអាយុ. ព្រោះហេតុអ្វី ? -ព្រោះថាទន្លេគង្គាដែលហូរទៅទិសខាងកើតនោះ នឹងធ្វើឱ្យហូរត្រឡប់ទៅក្រោយវិញមិនងាយឡើយ មិនអាចធ្វើទៅកើតឡើយ មហាជននោះ ត្រូវតែនឿយហត់ទេបុំណ្ណោះឯង. លោកដ៏មានអាយុទាំងឡាយ.ខនេះមានឧបមាយ៉ាងណា. ភិក្ខុចំរើនសតិបដ្ឋាន

ទាំង ៤ ក៏មានឧបមេយ្យដូច្នោះដែរ. ប្រសិនបើមានព្រះរាជាឬរាជមហាមាត្យ ញាតិមិត្រសំឡាញ់ឬគេក្រៅលោមលួងលោម ដោយភោគសម្បត្តិថា អ្នកអើយ អ្នកស្លៀកពាក់សំពត់អ៊ីកធ្វើអ្វី. ចូរអ្នកសឹកមកបរិភោគសម្បត្តិធ្វើបុណ្យទៅ ភិក្ខុនោះនឹងលាសិក្ខាបទសឹកមកតាមពាក្យទូន្មាននេះមិនមានឡើយ. ព្រោះហេតុអ្វី ព្រោះចិត្តរបស់លោកបង្អោនទៅកាន់វិវេកយូរហើយ ។ ព្រះអនុរុទ្ធត្ថេរចំរើនសតិបដ្ឋាន ៤ ដោយខ្លួនលោក ហើយសរសើរអ្នកចំរើនសតិ-បដ្ឋាន ៤ ដោយប្រការដូច្នេះ ។

មានសេចក្ដីដំណាលថា ព្រះអនុរុទ្ធត្ថេរនេះក្រៅពីពេលឆាន់ចង្ហាន់ហើយ លោកតែងពិចារណាប្រមើលមើលពពួកសត្វទាំងពួង ដោយទិព្វចក្ខុញាណ ជាអ្នកស្ទាត់ជំនាញក្នុងទិព្វចក្ខុ គឺមានភ្នែកទិព្វដោយអានិសង្សនៃទីបបូជា ក្នុងអតីតជាតិ អាស្រ័យហេតុនេះ ទើបព្រះបរម គ្រូទ្រង់សរសើរលោកថា ជាកំពូលនៃភិក្ខុទាំងឡាយអ្នកមានទិព្វចក្ខុ ។ ព្រះអនុរុទ្ធត្ថេរមានជីវិតឋិតនៅក្នុងព្រះសាសនា សមគួរដល់កាលកំណត់សង្ខារហើយ ទើបរំលត់ខ័ន្ធ ចូលកាន់បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្រោយព្រះពុទ្ធបរិនិព្វាន ។

## ៤២. ប្រវត្តិព្រះអានន្ទត្ថេរ ពុទ្ធុបដ្ឋាក

ព្រះអានន្ទត្ថេរអង្គនេះ កើតក្នុងត្រកូលសាក្យៈជាឱរសរបស់ព្រះសក្កោ-ទនសាក្យៈ ដ៏ជាព្រះអនុជព្រះបាទសុទ្ធោទន គ្រងក្រុងកបិលពស្តុ ញោមស្រីរបស់លោកឈ្មោះគិសាគោតមី លុះចំរើនវ័យធំឡើង បានសិក្សាសិល្បវិជ្ជា

ផ្សេង១ តាមប្រពៃណីអ្នកកើតក្នុងរាជត្រកូល ។

កាលសម្តេចព្រះបរមសាស្តាស្តេចយាងមកបំពេញពុទ្ធកិច្ច ប្រថាប់នៅអនុបិយនិគមរបស់ពួកមល្លក្សត្រ អានន្ទរាជកុមារក៏បានចេញទៅទ្រង់ព្រះផ្នួសជាមួយនឹងសាក្យៈព្រះញាតិវង្ស ៥ អង្គ គឺព្រះបាទភទ្ទិយៈព្រះភគ្គ ព្រះកិម្ពិលៈព្រះអនុរុទ្ធ ព្រះទេវទត្ត រួមជា ៧ នឹងឧបាលិជានាយភូសាមាលា។ កាលលោកបានឧបសម្បទហើយមិនយូរប៉ុន្មាន បានស្តាប់ឱវាទព្រះបុណ្ណត្ថេរ មន្តានីបុត្រក៏បានសម្រេចសោតាបត្តិផល ។ ចំណេរកាលតពីមក ព្រះបរមសាស្តាគ្មានភិក្ខុឧបដ្ឋាកប្រចាំព្រះអង្គ សង្ឃបានជ្រើសរើសព្រះអានន្ទថ្វាយ តែលោកជាអ្នកធ្ងន់ក្នុងហេតុ មានស្មារតីមិត់ចត់ទើបលោកមិនព្រមទទួលនាទីនេះភ្លាមទេ ក្រាបបង្គំទូលសូមពរជាមុន លុះព្រះអង្គទ្រង់អនុញ្ញាតហើយ ទើបលោកទទួលនាទីជាពុទ្ធុបដ្ឋាក ។ ឯពរដែលលោកក្រាបទូលសូបនោះមាន ៨ ខ ដូចតទៅនេះ :

១- សូមកុំឱ្យទ្រង់ប្រទានចីវរដ៏ប្រណិតដល់ខ្ញុំព្រះអង្គ ។

២- សូមកុំទ្រង់ប្រទានបិណ្ឌបាតប្រណិតដល់ខ្ញុំព្រះអង្គ ។

៣- សូមកុំឱ្យខ្ញុំព្រះអង្គនៅក្នុងទីប្រថាប់ជាមួយនឹងព្រះអង្គ ។

៤- សូមកុំទ្រង់នាំខ្ញុំព្រះអង្គទៅកាន់ទីនិមន្ត ។

៥- សូមព្រះអង្គស្តេចទៅកាន់ទីនិមន្ត ដែលខ្ញុំព្រះអង្គបានទទួលគេទុករួចហើយ ។

៦- សូមឱ្យខ្ញុំព្រះអង្គនាំបរិស័ទមកពីចម្ងាយចូលគាល់បានខណៈដែលគេ

បានមកដល់ហើយ ។

៧- បើសេចក្តីសង្ស័យកើតឡើងវេលាណា សូមឱ្យខ្ញុំព្រះអង្គចូលគាល់ទូលសួរបានក្នុងវេលានោះ ។

៨- បើព្រះអង្គទៅទេសនារឿងអ្វី ក្នុងទីណាដែលខ្ញុំព្រះអង្គមិនបានស្តាប់ សូមព្រះអង្គត្រាស់សំដែងរឿងនោះដល់ខ្ញុំព្រះអង្គ ។

ការដែលលោកក្រាបទូលសូមពរ ៤ ខ ខាងដើមនោះ ដើម្បីការពារនិន្ទាថា លោកឧបដ្ឋាកព្រះបរមសាស្តា ព្រោះប្រាថ្នាលាភ ។ ពរ៣ ខាងចុង ដើម្បីការពារគរហានិន្ទាថា ខ្ញុំឧបដ្ឋាកព្រះបរមសាស្តាទៅធ្វើអ្វី គ្រាន់តែប្រយោជន៍បន្តិចបន្តួចព្រះអង្គក៏មិនទ្រង់អនុគ្រោះ ។ ពរខាងចុងបង្អស់ដោយលោកមានបំណងថា បើមានគេមកសួរលោកថា ព្រះអង្គទ្រង់ទេសនារឿងអ្វី ? ទ្រង់សំដែងនៅទីណា ? ក៏អាចប្រាប់គេបាន កុំឱ្យគេរិះគន់ថា នៅជាប់នឹងព្រះអង្គជានិច្ច មិនដឹងអ្វី ។

តាំងអំពីកាលព្រះអានន្ទត្ថេរបានទទួលនាទីជាពុទ្ធុបដ្ឋានហើយ បានតាំងចិត្តដោយគោរព មានចិត្តសុចរិតស្មោះត្រង់ចំពោះព្រះដ៏មានបុណ្យយ៉ាងក្រៃលែង ដល់ទៅហ៊ានលះបង់ជីវិតថ្វាយព្រះអង្គ ដូចកាលលោកទៅឈរពាំងមុខដំរីនាឡាគិរី ការពារមិនឱ្យព្រះអង្គអន្តរាយ លោកជាអ្នកមានស្មារតីខ្ជាប់ខ្ជួនល្អណាស់អាចចងចាំទុកបានច្រើន មានសេចក្តីព្យាយាមអត់ធន់ ទាំងឈ្លាសវៃក្នុងផ្លូវទេសនា គុណសម្បត្តិទាំងនេះ ជាហេតុឱ្យព្រះបរមសាស្តា ទ្រង់លើកដំកើង សរសើរលោក ថាជាកំពូល នៃភិក្ខុទាំងឡាយជាពហុស្សូត ១ មាន

សតិ ១ មានគតិ ១ មានសេចក្តីព្យាយាម ១ ជាឧបដ្ឋាក ១ លោកថិតនៅក្នុង ឯតទគ្គដ្ឋាន ៥ ប្រការយ៉ាងនេះ ។

លុះព្រះបរមសាស្តាបរិនិព្វានហើយ គ្រាដែលសង្ឃជំនុំធ្វើសង្គាយនាធម្មវិន័យនោះ លោកបានទទួលភារៈជាអ្នកវិសជ្ជនា ព្រះសូត្រនឹងព្រះអភិធម្ម ក្នុងគ្រាបឋមសង្គាយនា ហើយក្នុងថ្ងៃព្រឹកឡើងនឹងធ្វើសង្គាយនានេះ លោកក៏បានសម្រេចអរហត្តផល ក្នុងរវាងដែលលើកព្រះបាទផុតពីដីទម្រេតកាយមិនសឹង គឺថាលោកបានសម្រេចអរហត្តក្នុងចន្លោះឥរិយាបថទាំង ៤ ។ លោកមានព្រះជន្មជរាបដល់អាយុក្ស័យហើយក៏រំលត់ខ័ន្ធបរិនិព្វាន នៅចន្លោះពុំងសឹងរោហិណី ជាទីប្រទល់ដែននៃក្រុងកបិលព័ស្តុនឹងក្រុងកោលិយៈនោះឯង ។ ន័យ ១ ទៀតមានសេចក្តីដំណាលថា កាលនឹងនិព្វាន លោកបានទេសនាទូន្មានពួកព្រះញាតិនឹងមហាជនដោយធម្មិកថាដ៏ច្រើន នៅទីបំផុតបានសំដែងអរិយសច្ចទាំង ៤ កាលចប់ធម្មទេសនា មហាជនបានលុះបត្តផលក៏ច្រើន ហើយលោកបានសំដែងបាដិហារ្យផ្សេងៗ ហើយអធិដ្ឋានទុកថា កាលលោកនិព្វានហើយ សូមឱ្យចំណែកអដ្ឋិធាតុបែកចេញជាពីរបំណែកៗ មួយបានទៅខាងពួកសាក្យៈមួយចំណែកទៀតឱ្យបានទៅខាងពួកកោលិយៈ ជាឧបាយការពារមិនឱ្យព្រះញាតិទាំងពីរចំណែកប្រណែនឈ្នានិះឬវិវាទគ្នា ដោយរឿងអដ្ឋិធាតុរបស់លោក ទាំងជាការសំដែងទឹកព្រះទ័យរបស់លោកប្រាសចាកអគតិទាំង ៤ ប្រការផង ។

✳✳✳✳✳

# ៤៣~ប្រវត្តិព្រះសោណកោឡិវិសត្ថេរ

ព្រះថេរៈអង្គនេះ ជាបុត្រអសុភសេដ្ឋី ក្នុងកាលសម្បាកឯរ ។ លោកជាអ្នកមានបុណ្យវាសនាតាំងពីកាលនៅក្នុងគភ៌មាតា រហូតដល់ប្រសូតចេញមកតែងបានមហាជននាំគ្រឿងបណ្ណាការមកជូនមហាសេដ្ឋីបិតាលោកជានិច្ច ។ លុះលោកប្រសូត្រមក កាយសំបុរស្បែកភ្លឺថ្លាពេញរស្មី ហេតុបិតាតាំងងារលោកថា សោណកៈ ។ ឯពាក្យថា កោឡិវិសៈជាឈ្មោះគោត្ររបស់លោក ។ លុះចំរើនវ័យឡើង សេដ្ឋីជាបិតាឱ្យគេសង់ប្រាសាទ ៣ ខ្នងសម្រាប់ឱ្យកូននៅក្នុងរដូវទាំង ៣ ។

កាលព្រះដ៏មានបុណ្យស្ដេចគង់នាក្រុងរាជគ្រឹះនោះ ព្រះបាទពិម្ពិសារទ្រង់បញ្ជូនសេដ្ឋីបុត្រនេះទៅកាន់ព្រះពុទ្ធសំណាក់ ។ លុះលោកបានស្ដាប់ព្រះធម្មទេសនា មានសទ្ធាជ្រះថ្លា ក្រាបទូលសូមឧសម្បទ ព្រះអង្គទ្រង់មានព្រះពុទ្ធដីកាឱ្យទៅលាមាតាបិតជាមុនសិន លុះបានអនុញ្ញាត ហើយទើបលោកត្រឡប់មកបួស ក្នុងសំណាក់ព្រះដ៏មានបុណ្យ ។ តាំងពីលោកបានបួសហើយតែងមានញាតិមិត្តចូលទៅរកលោកជាញឹកញយ មិនសូវមានឱកាសទំនេរទើបលោកគេចទៅនៅព្រៃសីតវនចំរើនសមណធម៌តាំងអធិដ្ឋានធ្វើសេចក្ដីព្យាយាមដើរចង្ក្រមមិនឈប់ឈរ ត្រាតែបាទាលោកពុះពងបែកចេញឈាម នឹងដើរចង្ក្រមតទៅទៀតពុំរួច ទើបលោកមានសេចក្ដីត្រិះរិះថា "បណ្ដាព្រះសាវករបស់ដ៏មានបុណ្យ ដែលខំប្រារព្ធសេចក្ដីព្យាយាមម៉ឺងម៉ាត់ អាត្មាអញក៏នៅក្នុង

ចំនួននេះ ១ រូបដែរប៉ុន្តែអាត្មាអញនៅតែមិនអាចសម្រេចបព្វជ្ជាបើធ្វើយ៉ាង ប្រហែលអាត្មាអញនេះជាអភ័ព្វបុគ្គលទេដឹង. ទ្រព្យសម្បត្តិក្នុងត្រកូល របស់អញមានច្រើន ដូច្នេះគួរអាត្មាអញសឹកចេញទៅបរិភោគសម្បត្តិ ធ្វើទានរក្សាសីលវិញ ។

ព្រះបរមសាស្តាទ្រង់ជ្រាបបរិវិតក្ករបស់លោក ទើបស្តេចទៅប្រោសប្រទានព្រះពុទ្ធោវាទ ទ្រង់លើកយកខ្សែពិណជាគ្រឿងឧបមា ។ លោកទទួលយកព្រះឱវាទដោយគោរព ប្រារព្ធសេចក្តីព្យាយាមតែល្មមប្រមាណគឺមិនតឹងពេកមិនធូរពេក ក៏បានសម្រេចអរហត្តផល ជាព្រះអរហន្តដ៏វិសេសក្នុងព្រះពុទ្ធសាសនា រាប់បញ្ចូលក្នុងពួកព្រះមហាសាវ័កអង្គមួយ ទើបលោកចូលទៅក្រាបថ្វាយបង្គំគាល់ព្រះបរមសាស្តា បញ្ចេញព្រះវាចា ព្យាករណ៍របស់លោក បើកព្រះភក្ត្រព្រះអង្គ ទ្រង់សរសើរហើយ ទ្រង់តាំងក្នុងឯតទគ្គដ្ឋាន គឺតំណែងជាកំពូលភិក្ខុទាំងឡាយខាងប្រារព្ធសេចក្តីព្យាយាម ។ លោកមានព្រះជន្មក្នុងព្រះសាសនា ត្រាតែដល់អាយុក្ស័យ ទើបរំលត់ខ័ន្ធបរិនិព្វាន ។

# ៤៤~ប្រវត្តិព្រះរដ្ឋបាលត្ថេរ

ព្រះថេរៈអង្គនេះ ជាបុត្ររបស់រដ្ឋបាលសេដ្ឋី ក្នុងថុល្លកោដ្ឋិតនិគមខេត្តដែនកុរុរាស្ត្រ ។ លុះលោកចំរើនវ័យ បានសិក្សាសិល្បសាស្ត្រតាមវង្សត្រកូល ។

គ្រាមួយ ព្រះដ៏មានបុណ្យស្តេចត្រេចចារិកនៅក្នុងកុរុ ព្រមដោយព្រះភិក្ខុសង្ឃជាចំនួនច្រើន ដរាបដល់ទៅថុល្លកោដ្ឋិតនិគម ស្តេចប្រថាប់នៅទី

នោះ ។ រដ្ឋបាលមាណពនឹងព្រាហ្មណ៍គហបតីអ្នកនិគមនោះបានដឹងពីរថា ព្រះបរមគ្រូស្ដេចយាងទៅដល់ហើយ ក៏នាំគ្នាចូលគាល់ស្ដាប់ព្រះធម្មទេសនា ។

រដ្ឋបាលនោះក៏ក្រាបទូលសូមព្រះផ្នួសទៅក្រោមបវរពុទ្ធបួស ។ ព្រះអង្គត្រាស់ថា មិនទ្រង់បំបួសកុលបុត្រណាដែលមិនទាន់បានទទួលអនុញ្ញាតពីមាតាបិតាជាមុនទេ ។ ទើបលោកត្រឡប់ទៅជម្រាបលាមាតាបិតា១ មិនព្រម អនុញ្ញាតិឱ្យលោកទៅបួស ព្រោះមានកូនតែមួយ ជាទីស្រឡាញ់ពេញចិត្តពេកាស់ ។ លោកតូចចិត្តណាស់ក៏ប្រាសប្រាណដេកអត់អាហារ ដោយគិតថានឹងស្លាប់លើដំណេកនោះ ឬនឹងបានបួសប៉ុណ្ណោះ ។ តើទុកជាមាតាបិតាញាតិមិត្តនិយាយលួងលោមដូចម្ដេច ។ ក៏លោកមិនព្រមក្រោកបរិភោគអាហារសោះ ។

គ្រាក្រោយមក ពួកសំឡាញ់របស់លោកនិយាយលួងលោមយ៉ាងណា ក៏លោកមិនព្រមឆ្លើយសោះ ទើបពិគ្រោះគ្នាថា បើរដ្ឋបាលមិនបានបួសទេ មុខជាស្លាប់អស្សារឥតការ. បើរដ្ឋបាលបានបួស មាតាបិតាក្ដី យើងរាល់គ្នាក្ដីនឹងបានឃើញមុខរដ្ឋបាល មួយដងមួយកាលមិនខាន ។ ប៉ុន្តែឯការបួសនេះតឹងណាស់ ប៉ុនមែនធូរស្រួលទេ ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ ដេកមួយពេល ស៊ីមួយពេល. ឯរដ្ឋបាលនេះធ្លាប់ឋិតនៅតែក្នុងសេចក្ដីសុខ. ជាបោរីជនគង់មិនអាចប្រព្រឹត្តដូច្នោះបានទេ គង់វិលមកផ្ទះវិញមិនខាន គួរយើងនាំគ្នាទៅនិយាយនឹងមាតាបិតារបស់រដ្ឋបាលឱ្យព្រមអនុញ្ញាតិផ្នួសឱ្យរដ្ឋបាលទៅសិនចុះ។ មាតាបិតាក៏យល់ព្រមតាមយោបល់នោះ ទើបពួកសំឡាញ់នាំគ្នាទៅប្រាប់ពត៌មាននេះដល់លោក១ មានរំពេរពេកាស់ក្រោកឡើងបោសខ្លួនប្រាណ បរិភោគ

អាហារល្មមមានកំឡាំងហើយ លោកបានចូលក្រាបថ្វាយបង្គំសូមផ្នួស ព្រះដ៏មានបុណ្យ ក៏ទ្រង់ប្រទានបព្វជ្ជាឧបសម្បទាឲ្យលោកតាមប្រាថ្នា ។

កាលលោកបានបួសហើយ មិនយូរប៉ុន្មានប្រមាណកន្លះខែព្រះបរមសាស្តាស្តេចចេញពីថុល្លកោដ្ឋិតនិគម ស្តេចទៅប្រថាប់នៅក្រុងសាវត្ថីលោកបានទៅតាមព្រះអង្គដែរ លោកបានតាំងនៅក្នុងសេចក្តីមិនប្រមាទ ពិរើនវិបស្សនាក៏បានសម្រេចអរហត្តផល ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបលោកចូលគាល់ក្រាបទូលលាទៅសួរមាតាបិតា លុះបានទទួលព្រះពុទ្ធានុញ្ញាតិហើយ លោកក៏ចេញពីក្រុងសាវត្ថី ត្រេចចារិកទៅដល់ថុល្លកោដ្ឋិតនិគមដ៏ជាមាតុភូមិរបស់លោក ។

ថ្ងៃមួយ ព្រះបាទកោរព្យរាជស្តេចប្រពាតព្រះរាជឧទ្យាន បានទតព្រះនេត្រទៅឃើញព្រះរដ្ឋបាលត្ថេរ ទ្រង់ចាំបាន ទើបស្តេចចូលទៅជិតទ្រង់ត្រាស់ប្រស្រ័យតាមសមគួរហើយ ទើបទ្រង់ត្រាស់សួរថា "សេចក្តីសាបសូន្យ ៤ យ៉ាងដែលមនុស្សពួកខ្លះបានជួបប្រទះហើយ ទើបចេញទៅបួស គឺជរា ១ ព្យាធិ ១ ឥតទ្រព្យសម្បត្តិ ១ ឥតញាតិមិត្ត ១ ដែលនឹងគិតតាំងខ្លួនប្រាណក្នុងផ្លូវឃរាវាសមិនកើត ។ ចុះចំណែកលោក១ កំពុងពេញកំឡោះត្រឡាំងទាំងមិនមានសេចក្តីសាបសូន្យអ្វីមួយមកប៉ះពាល់ឡើយ ចុះលោកបានឃើញឬបានដឹងឮដូចម្តេច បានជាលោកចេញបួស ?

ព្រះថេរៈបានសំដែងធម្មទេស ៤ ដែលព្រះបរមគ្រូ ទ្រង់បានរកឃើញព្រះអង្គជាព្រះអរហត្តត្រាស់ដឹងដោយព្រះអង្គឯង សំដែងថ្វាយដល់ព្រះរាជា-

ក្សត្រថា ៖ ខ ទី ១ ថា លោកធ្វើពពួកសត្វ ត្រូវជរានាំចូលទៅជិតផតខ្ជាប់ខ្លួន. ខ ទី ២ ថាលោកធ្វើពពួកសត្វ មិនមានអ្នកណាប្រយោជន៍ការពារផ្ទាល់មានសេរីភាព អំពោះខ្លួន. ខ ទី ៣ ថាលោកធ្វើពពួកសត្វ មិនមានរឿងរបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួងទៅ. ខ ទី ៤ ថា លោកធ្វើពពួកសត្វខ្វះកង្វះជានិច្ច មិនចេះឆ្អែត ជាខ្ញុំនៃតណ្ហា ៕

បេុះលោកទូលហេតុដែលនាំឱ្យលោកចេញបួសថ្វាយព្រះមហាក្សត្រចប់ស្រេចហើយ ព្រះរាជាទ្រង់ត្រាស់អនុមោទនាធម្មិកថារបស់លោក ។

ព្រះរដ្ឋបាលត្ថេរសម្រាកនៅក្នុងដែននោះតាមសមគួរហើយ ទើបលោកត្រឡប់មកកាន់សំណាក់ព្រះបរមសាស្តា ។ អាស្រ័យហេតុដែលលោកចេញបួសដោយសទ្ធាជ្រះថ្លាតាំងពីដំបូង ហើយទម្រាំនឹងបានបួសក៏លំបាកណាស់ ទើបព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរលោកថា ជាកំពូលនៃភិក្ខុទាំងឡាយ អ្នកចេញបួសដោយសទ្ធា ។ លុះលោកបានព្រះជន្មដល់កំណត់អាយុក្ស័យហើយ ទើបរំលត់ខ័ន្ធបរិនិព្វាន ។

# ៤៥. ប្រវត្តិព្រះបិណ្ឌោលភារទ្វាជត្ថេរ

ព្រះថេរៈអង្គនេះ ជាបុត្រព្រាហ្មណ៍មហាសាល ភារទ្វាជគោត្រ ក្នុងក្រុងរាជគ្រឹះ មាននាមតាមគោត្រថា ភារទ្វាជមាណព ។ លុះចំរើនវ័យធំឡើងបានសិក្សាចប់គម្ពីរត្រៃវេទ ចេះចាំស្ទាត់ជំនាញ បានទទួលនាទីជាគ្រូបង្រៀនមន្តដល់ពួកមាណព ៥០០ នាក់ ។ តបក មានសេចក្តីល្មោភក្នុងអាហារបិណ្ឌបាត

ត្រាច់ស្វែងរកក្នុងទីតំបន់ផ្សេងៗ ដោយអាការត្រូវចំណងខ្លះខុសចំណងខ្លះ ព្រោះ តែមានគេត្មះតិះដៀល ទើបបានជាប់ឈ្មោះហៅផ្សេងទៀតថា "បិណ្ឌោលភារទ្វាជៈ" តាំងអំពីកាលណោះមក ។

គ្រាមួយ សម្តេចព្រះបរមសាស្តា ស្តេចត្រាច់ទៅប្រកាសព្រះសាសនា ក្នុងក្រុងរាជគ្រឹះ លោកបានដឹងដំណឹងក៏ចូលទៅគាល់ស្តាប់ព្រះធម្មទេសនា មានសេចក្តីជ្រះថ្លា ក្រាបទូលសូមបព្វជ្ជាឧបសម្បទ ។ លោកបានឧបសម្បទ ហើយបានតាំងនៅក្នុងសេចក្តីមិនប្រមាទធ្វើសមណធម៌មិនយូរប៉ុន្មាន ក៏បាន សម្រេចអរហត្តផល ។ លោកជាអ្នកបរិបូណ៌ដោយឥន្ទ្រិយ៍ ៣ គឺ សតិ សមាធិ បញ្ញា ។ កាលលោកបានសម្រេចអរហត្តហើយ ត្រាច់និមន្តទៅកាន់ទីណាក៏ ដោយតែងបន្លឺឧទានវាចាថា "**មគ្គេ វា ផលេ វា**" ដូច្នេះរំលើក សេចក្តី អ្នកណាមួយមានសេចក្តីងឿងឆ្ងល់ឬសង្ស័យ ក្នុងមគ្គក្តី ផលក្តី សូម អ្នកនោះចូលមកសួរខ្ញុំចុះ" ។ ទោះបីនៅក្នុងទីចំពោះព្រះភក្ត្រព្រះបរមគ្រូ ក៏ នៅតែបន្លឺឧទានវាចាដូច្នោះដែរ ព្រោះអាស្រ័យហេតុនេះឯងជានិមិត្ត ទើបព្រះ ដ៏មានបុណ្យសរសើរលោកថា ជាឆ្នើមជាងភិក្ខុទាំងឡាយខាងបន្លឺសីហនាទ ។ លុះលោកមានព្រះជន្មគ្រប់បរិបូណ៌ដល់កំណត់អាយុក្ស័យហើយ ក៏រំលត់ខន្ធ បរិនិព្វាន ។

☆☆☆☆☆

## ៤៦-ប្រវត្តិព្រះមហាបន្ថកត្ថេរ
## ៤៧-ប្រវត្តិព្រះចុល្លបន្ថកត្ថេរ

ព្រះថេរៈទាំងពីរអង្គនេះ តាមប្រវត្តិដំណាលថា លោកជាបុត្រនៃធីតាសេដ្ឋីម្នាក់ នៅក្រុងរាជគ្រឹះ ។ មាតារបស់លោកប្រព្រឹត្តតាមសន្ថវៈនឹងបុរសបម្រើរបស់នាង ហើយបានសេចក្តីភិតភ័យខ្លាចគេបុសរៀងខ្លួន ទើបនាំគ្នារត់ទៅនៅក្នុងតំបន់ដែលគ្មានគេស្គាល់ខ្លួនសោះ ។ តមក នាងភរិយាកាលផ្ទៃពោះធំឡើងនាំសេចក្តីលំបាកវេទនាបំពាន និយាយអង្វរស្វាមីដើម្បីឱ្យនាំទៅកាន់ត្រកូលរបស់នាងវិញ ដើម្បីប្រសូតបុត្រនៅទីនោះ អស់កាលច្រើនលើកច្រើនគ្រា មិនដាច់ ដោយស្វាមីនាងចេះតែបណ្តែតបណ្តោយមួយថ្ងៃហើយមួយថ្ងៃទៀត ។

ថ្ងៃមួយ ស្វាមីចេញទៅធ្វើការខាងក្រៅផ្ទះ នាងធីតាសេដ្ឋីនិយាយផ្តាំផ្ញើផ្ទះនឹងអ្នកជិតខាងហើយឱ្យប្រាប់ស្វាមីនាងតាមដំណើររឿង១ ។ ឯស្វាមីនាងដល់ត្រឡប់មកពីធ្វើការងារ បានដំណឹងថា ភរិយារត់ទៅតាមផ្លូវត្រកូលរបស់នាង ក៏ខំស្រូតទៅតាម ទាន់នាងកំពុងប្រសូតបុត្រនៅពាក់កណ្តាលផ្លូវ ហើយនាំគ្នាត្រឡប់មកលំនៅវិញ ព្រោះកិច្ចដែលត្រូវទៅកាន់ត្រកូលនោះសម្រេចអស់ហើយ ។ បុត្រនោះ ឱ្យឈ្មោះថា បន្ថកៈ ព្រោះបានបកកើតក្នុងរវាងផ្លូវ ។

អំណើសកាលតមក នាងធីតាសេដ្ឋីមានគភ៌ឡើងទៀត ហើយនាងបានប្រព្រឹត្តដូចលើកមុន ហើយតាំងឈ្មោះកូនថា បន្ថក ទៀត ប៉ុន្តែកូនបងឱ្យ

ឈ្មោះថាមហាបន្ថកៈ កូនប្អូនឱ្យឈ្មោះថាចុល្លបន្ថកៈ ។ លុះបុត្រទាំងពីរធាត់ធំចំរើនឡើង ក៏សាកសួរដល់ជីដូនជីតាវង្សត្រកូល ។ នាងមាតាក៏ប្រាប់តាមដំណើរ កូនទាំងពីរក៏តាំងរកកូនឱ្យនាំខ្លួនទៅរក ជីដូនជីតា ស្វាមីភរិយាទីកអាភេិតកូនណាស់ក៏នាំខ្លួនទៅរកត្រកូលលោកសេដ្ឋីឯក្រុងរាជគ្រឹះ ប៉ុន្តែលោកសេដ្ឋីព្រមទទួលតែចៅតូចៗ ទាំងពីរប៉ុណ្ណោះ បពណ្តោយឱ្យឪពុកម្តាយក្មេងទៅតាមយថាកម្ម ដោយលោកអាងថា ជនទាំងពីរបានធ្វើឱ្យលោកអាមាសមុខដល់ប្រជាជន មិនគួរឱ្យនៅក្នុងត្រកូលរបស់លោកតទៅទៀត តែព្រោះនាងធីតាជាសាច់សារលោហិតរបស់លោកពិតៗ ទើបលោកធ្វើមាសប្រាក់ទៅឱ្យខ្លះល្មមជាស្បៀងចិញ្ចឹមជីវិតតទៅ ។

កាលមហាបន្ថកកុមារធំឡើង តែងតាមជីតាទៅស្តាប់ ព្រះធម្មទេសនាឯវេឡុវនមហាវិហារ មានចិត្តជ្រះថ្លាចង់បួស ជីតាក៏អនុញ្ញាតហើយនាំខ្លួនទៅថ្វាយដល់ព្រះដ៏មានបុណ្យៗ ទ្រង់អនុញ្ញាតិឱ្យភិក្ខុ ១ រូបបំបួសជាសាមណេរដល់អាយុ ២០ ឆ្នាំ ក៏បានទទួលឧបសម្ប៉ទដាភិក្ខុ លោកយកចិត្តទុកដាក់ ចំរើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល ហើយបានទទួលសេចក្តីសរសើរ អំពីព្រះបរមសាស្តាថា ជាឆ្នើមជាងភិក្ខុទាំងឡាយ ក្នុងកិច្ចចំរើនបញ្ញាភាវនា ។ តបកលោលចូលទៅគាល់ព្រះដ៏មានបុណ្យ ក្រាបទូលយកអាសាធ្វើនាទីភត្តុទ្ទេសក៏។ ព្រះអង្គក៏ទ្រង់អនុមោទនា ប្រទានតំណែងនេះដល់លោកៗក៏ទទួលធ្វើមុខការនោះបានរៀបរយរហូតមក ។

ព្រះមហាបន្ថកត្ថេរតែងសម្រេចសម្រាន្តនៅដោយឈានសុខ មគ្គសុខ

ផលសុខនឹងមិនបានសុខជានិច្ច ទើបលោកគិតដល់ប្អូនលោក ថាគួរឱ្យបានសេ
សោយសេចក្តីសុខបែបនេះផង ទើបលោកចូលទៅរកសេដ្ឋីជីតា សុំអនុញ្ញា
បំបួសចុល្លបន្ថក ។ ជីតាក៏អនុញ្ញាតតាមបំណងកាលចុល្លបន្ថកៈបានបួសហើ
គ្រឡប់ទៅជាល្ងង់ខ្លៅយ៉ាងក្រៃលែងរៀនទន្ទេញគាថាមួយសរសើរព្រះពុទ្ធគុណ
ក្នុងសំណាក់ព្រះថេរៈជាបងអស់ ៤ ខែនៅតែចាំមិនបាន ។ ព្រះមហាបន្ថកត្ថេ
បាលថា ប្អូនលោកល្ងង់ខ្លៅពេក ក៏បណ្តេញចេញពីសំណាក់លោក ។ ព្រះចុល្ល
បន្ថកៈមានចិត្តទោមនស្សណាស់ អស់អាល័យក្នុងភេទបព្វជិត គិតបំរើងសឹក
ទៅជាគ្រហស្ថ ។ មានសេចក្តីដំណាលថា ដែលលោកល្ងង់ខ្លៅដូច្នោះ ព្រោះ
កាលអំពីអតីតជាតិ លោកបានសើចចំអកឱ្យពួកសិស្សល្ងង់ខ្លៅដែលនៅរៀន
សូត្រជាមួយគ្នា ។

គ្រានោះ ពេទ្យកោមារភិច្ច ប្រើបម្រើឱ្យទៅក្រាបទូលនិមន្តព្រះបរម-
សាស្តា ព្រមដោយព្រះភិក្ខុសង្ឃ ៥០០ រូបទទួលភត្ត ។ មនុស្សបម្រើបានទៅ
រកព្រះមហាបន្ថកត្ថេរ ជាភត្តុទ្ទេសក៏តាមដំណើរ។ លោកដកឈ្មោះចុល្លបន្ថកៈ
ប្អូនលោកចេញពីចំនួនដែលត្រូវនិមន្ត ។ លោកជាប្អូនបានដឹងដំណឹងនេះកាន់
តែតូចចិត្តខ្លាំងឡើង គិតនឹងទៅសឹកចេញ ចួនជាបានជួបព្រះដ៏មានបុណ្យ ។
ទ្រង់មានព្រះពុទ្ធដីកាលួងលោមប្រទានសំពត់សបរិសុទ្ធិឱ្យចាប់អង្អែលបរិកម្ម
ថា "**រជោហរណំ**" ៗ ២ លោកបរិកម្មស្ទាបអង្អែលទៅ សំពត់ក៏កោរ
ពណ៌សៅហ្មង ប្រឡាក់ដោយមន្ទិល អាស្រ័យហេតុនេះជានិមិត្ត ទើបលោក
ផ្តងចិត្តពិចារណាថា សេចក្តីបរិសុទ្ធិអស់ទៅ ព្រោះអាស្រ័យមន្ទិលក្នុងកាយ

ដូចជាចិត្តដែលបរិសុទ្ធិដូវជង់ របែងសៅប្បរដោយបាបកុសលេ ហាមលេវេ ទោសជាដើម ដែលកើតឡើងក្នុងចិត្ត ។ លោកបានពិចារណាតាមព្រះត្រៃ-លក្ខណ៍មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តបដិសម្ភិទាញាណនឹងអភិញ្ញាទាំង ៦ ប្រកបដោយមនោមយិទ្ធិ គឺរិទ្ធិអាចនិងនិមិត្តមនុស្សម្នាក់ឱ្យទៅជាច្រើន ក៏បាន ធ្វើមនុស្សច្រើនឱ្យទៅជាម្នាក់វិញ ក៏បានតាមបំណង ។

ដល់ពេលព្រឹកឡើង ព្រះបរមសាស្តាព្រមដោយភិក្ខុសង្ឃ ៩០០ ខ្វះ ១ រូប ស្តេចនិមន្តទៅកាន់ផ្ទះពេទ្យកោមារភិច្ចៗ ដួសបបរយាគូបង្ហោនចូលទៅថ្វាយ ព្រះអង្គទ្រង់បិទបាត្រ ។ ទើបគេក្រាបទូលសួរហេតុទ្រង់ត្រាស់ថាក្នុងវត្តនៅមានភិក្ខុ ១ រូបទៀត ។ ពេទ្យកោមារភិច្ចចាត់បម្រើឱ្យទៅពិបច្ចត្រោវ តែគេឃើញភិក្ខុទាំងពាន់រូបប្លែកៗ កំពុងធ្វើកិច្ចធុរៈផ្សេងៗ គ្នា ក៏នឹកឆ្ងល់ណាស់ ទើបត្រឡប់មកប្រាប់ពេទ្យជីវកកោមារភិច្ចៗ ក៏ចាត់ឱ្យទៅនិមន្តភិក្ខុចុល្លបន្ថកៈ ។ បម្រើក៏សួរថា អង្គណាព្រះនាមចុល្លបន្ថកៈ ។ លោកទាំងពីរនោះឆ្លើយឡើងព្រមគ្នាថា អាត្មាឈ្មោះចុល្លបន្ថកៈព្រមគ្នាទាំងអស់ ។ បុរសបម្រើក៏វិលមកវិញទទេម្តងទៀត ។ ទើបពេទ្យជីវកបង្គាប់ថា លោកអង្គណាឆ្លើយមុនគេ ឯងទូលលោកថា ព្រះដ៏មានបុណ្យមានព្រះពុទ្ធដីកា ឱ្យហៅ ។ គ្រានេះទើបបានព្រះចុល្លបន្ថកៈមកឯលោកសង្ឃដែលនិមិត្រក៏បាត់អស់ទៅ ។

ព្រោះហេតុនេះហើយ បានជាព្រះបរមសាស្តាទ្រង់តាំងលោកក្នុងឯតទគ្គដ្ឋានកថា ជាឆ្នើមជាងភិក្ខុទាំងឡាយ បែកខាងស្ទាត់ជំនាញដោយមនោមយិទ្ធិវិជ្ជា ។ ព្រះមហាថេរទាំងពីរអង្គ មានព្រះជន្មាយុក្នុងព្រះសាសនា

គ្រាដែលដល់កំណត់អាយុក្ស័យ ទើបរំលត់ខន្ធបរិនិព្វាន ។

# ៤៨~ប្រវត្តិព្រះសោណកុដិកណ្ណត្ថេរ

ព្រះថេរៈអង្គនេះ ជាបុត្ររបស់ឧបាសិកាឈ្មោះកាឡី សោតាបន្នា កើតក្នុងក្រុងរាជគ្រឹះ ។ កាលលោកនៅជាគ្រហស្ថបានពាក់គ្រឿងប្រដាប់ត្រចៀកមានដម្លៃប្រមាណ ១ កោដិ ទើបមហាជនកាន់យកនិមិត្រនេះជាហេតុ នាំគ្នាហៅឈ្មោះថា សោណកុដិកណ្ណៈ តាំងអំពីកាលណោះមក ។

គ្រាមួយ ព្រះមហាកច្ចាយនត្ថេរ លោកអាស្រ័យនៅភ្នំឧបវត្តនៈស្រុកកុររឃរៈ ក្នុងអវន្តីជនបទ ។ ឯនាងកាឡីឧបាសិកា ជាឧបដ្ឋាយិការបស់លោក ដល់សោណៈធាត់ធំចំរើនឡើង ក៏មានសេចក្តីស្និទ្ធស្នាលនឹងព្រះមហាកច្ចាយនត្ថេរៗ ការបំបួសជាសាមណេរ សិក្សាវិន័យ ៣ ឆ្នាំ ទើបបានឧបសម្បទជាភិក្ខុដោយញត្តិចតុត្ថកម្មវាចា ក្នុងសំណាក់ព្រះមហាកច្ចាយនត្ថេរៗ បានណែនាំពន្យល់ឱ្យចំរើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ។ លោកបានសិក្សាសុត្តនិទានក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ដល់ចេញវស្សាបានលាព្រះឧបជ្ឈាយ៍មកគាល់ព្រះបរមសាស្តា ហើយនាំយកសំពត់កម្ពលរបស់ម្តាយដែលផ្ញើមកថ្វាយព្រះអង្គ ។ ព្រះដ៏មានបុណ្យទ្រង់ប្រោសឱ្យលោកស្នាក់ជិតទីប្រថាប់ ។

ថ្ងៃមួយ ព្រះបរមសាស្តាទ្រង់ត្រាស់ឱ្យព្រះសោណត្ថេរសំដែងធម៌ ។ លោកក៏បានសំដែងព្រះសូត្រដែលពោលអំពីវគ្គ ៨ ប្រការ ដោយសំឡេងដ៏

ពិរោះពេញចិត្ត ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រទានសាធុការថា សាធុៗ ពិរោះណាស់ មានទំនង់ដូចជាធម្មទេសនា ដែលតថាគតបានសំដែងហើយ ។ លុះតមក លោកបានឱកាសក៏ក្រាបបង្គំទូលសូមពរ ៨ ប្រការ តាមពាក្យដែលព្រះឧបជ្ឈាយ៍លោកបានផ្ដាំមក អំពីហេតុដែលធ្វើឧបសម្បទកម្ម ដោយគណៈបក-ត័ត្ត មានព្រះវិន័យធរជាគំរប់ ៥ ជាដើម ។ ព្រះអង្គក៏ទ្រង់ប្រទានពុទ្ធានុញ្ញាតឱ្យ ទើបលោកក្រាបបង្គំទូលលាវិលមកកាន់សំណាក់ព្រះមហាកច្ចាយនត្ថេរវិញ ហើយបាននាំយកធម៌ដែលលោកសំដែងថ្វាយដល់ព្រះដ៏មានបុណ្យ នោះមកសំដែងដល់មាតាលោកម្ដងទៀត ។

ព្រះសោណកុដិកណ្ណត្ថេរនេះ ព្រះបរមសាស្ដាទ្រង់លើកសរសើរថាជាឆ្នើមជាងភិក្ខុទាំងឡាយ ខាងសំដែងធម្មទេសនាដោយវាចាដ៏ពិរោះ ។ លុះលោកមានព្រះជនក្នុងព្រះសាសនា ត្រាតែដល់កំណត់អាយុក្ខ័យហើយ ក៏រំលត់ខ័ន្ធបរិនិព្វាន ។

## ៤៩~ប្រវត្តិព្រះវក្កលិត្ថេរ

លោកកើតក្នុងត្រកូលព្រាហ្មណ៍នាក្រុងសាវត្ថី មាននាមថា វក្កលមាណពលុះចំរើនវ័យឡើង បានរៀនសូត្រចេះចប់គម្ពីរត្រៃវេទ សម័យមួយ វក្កលិ-មាណពបានឃើញព្រះដ៏មានបុណ្យស្ដេចនិមន្តចូលទៅក្រុងសាវត្ថីមានព្រះភិក្ខុសង្ឃចោមរោមជាបរិវារ ក៏កើតសេចក្ដីជ្រះថ្លាជាប់ចិត្តនឹងព្រះរូបកាយសម្បត្តិរបស់ព្រះអង្គ ចង់ឃើញព្រះអង្គជានិច្ចទើបដាច់ចិត្តលះបង់គេហស្ថានចូលទៅ

ប្រសាសន៍ក្នុងព្រះសាសនា ។ លុះលោកបានបួសហើយ មិនបានតាំងចិត្តបំពេញសមណធម៌ គិតតែដើរតាមគន់មើលព្រះរូបព្រះឆោមរបស់ព្រះអង្គប៉ុណ្ណោះ ។ តមកសម័យក្រោយព្រះអង្គទ្រង់យល់ថា ការធ្វើដូច្នោះ មិនអាចនឹងត្រាស់ដឹងធម៌វិសេសអ្វីបានទេ ទើបទ្រង់បណ្តេញចេញអំពីព្រះពុទ្ធសំណាក់ ។

លោកមានសេចក្តីទោមនស្សណាស់ ក៏ឡើងទៅលើភ្នំគិជ្ឈកូដ ដើម្បីនឹងលោតទម្លាក់សម្លាប់ខ្លួន ។ ព្រះអង្គទ្រង់ជ្រាបទើបស្តេចយាងទៅឱ្យបានឃើញ ហើយទ្រង់ត្រាស់ទូន្មានលួងលោមដោយធម៌កថា លោកកើតបីតិសោមនស្សខ្លាំង តាំងនៅក្នុងព្រះឱវាទ តមក លោកបានត្រិះរិះដោយឧបាយដ៏ប្រពៃ បន្ទាបបង់សេចក្តីពុលស្រវឹងក្នុងរូបចេញបានកើតសង្វេគស្លុតចិត្តខំចំរើនវិបស្សនាធុរៈ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផលព្រមដោយបដិសម្ភិទាញាណ បានទទួលសេចក្តីសរសើរអំពីព្រះបរមសាស្តា ថាជាកំពូលនៃភិក្ខុទាំងឡាយ ខាងសទ្ធាវិមុត្តិ គឺផុតចាកកិលេសដោយសទ្ធា ។ លុះលោកមានអាយុសង្ខារសមគួរនឹងកាលវេលាហើយ ក៏រំលត់ខ័ន្ធបរិនិព្វាន ។

## ៥០~ប្រវត្តិព្រះវង្គីសត្ថេរ

ព្រះវង្គីសត្ថេរ ជាបុត្រព្រាហ្មណ៍ម្នាក់នៅក្រុងសាវត្ថី ដើមឈ្មោះវង្គីសមាណព លុះចំរើនវ័យឡើង បានសិក្សាចេះចប់គម្ពីរវេទទាំង ៣ យ៉ាងស្ទាត់ ថែមទាំងចេះមន្ត ១ ប្រភេទទៀតឈ្មោះឆវសីសៈជាមន្តសម្រាប់ពិសោធន៍ក្បាលខ្មោច ឱ្យដឹងថាទៅកើតក្នុងកំណើតអ្វី ។ លុះបានសម្រេចមន្តនេះហើយ

ក៏ត្រេចរកចិញ្ចឹមជីវិតដោយវិជ្ជាការនោះ ត្រាតែមានមនុស្សរាប់អានដ៏ច្រើន និងត្រេចទៅកាន់ទិសដំបន់ណា ក៏មានមនុស្សចោមរោមជាបរិវារ ។ តមក វង្គីសមាណពបានទទួលសរសើរព្រះបរមគ្រូថាជាកំពូលអ្នក ប្រាជ្ញរកពោះមួយប្រៀបផ្ទឹមគ្មាន លោកចូលគាល់ព្រះអង្គឯព្រះវិហារជេតវន តែម្នាក់ឯង។ ព្រះអង្គទ្រង់ឱ្យនាំយកសីសៈព្រះខីណាស្រពមកឱ្យវង្គីសៈពិនិត្យ ។ វង្គីសព្រាហ្មណ៍ក៏យកចុងក្រចកគោះរលាសីសៈព្រមទាំងរាយមន្តវិជ្ជាការដ៏សក្តិសិទ្ធិនោះក៏នៅតែមិនអាចដឹងដល់គតិភពនៃព្រះខីណាស្រពនោះ ទាល់គំនិតទើបក្រាបទូលសូមរៀន ។ ព្រះសម្ពុទ្ធត្រាស់ថា ឱ្យវង្គីសៈបួសសិន ។ លោក ក៏ព្រមបួស កាលបានបួសហើយ ព្រះសម្ពុទ្ធទ្រង់ពន្យល់ទូត្តិសាការឱ្យលោក ស្វាធ្យាយ លោកជាអ្នកមិនប្រមាទ ទាំងជាអ្នកមានសតិបញ្ញាស្រាប់លុះលោក ស្វាធ្យាយទៅ ប្រើប្រាជ្ញាពិចារណាចាក់ធ្លុះហេតុផល · ក៏បានសម្រេចអរហត្តផល ព្រមដោយបដិសម្ភិទាញាណ ។ កាលលោកចូលទៅគាល់ព្រះបរមសាស្ដាក្នុងកាលណាក្តី នៅទីណាក្តី តែងពោលគាថាសរសើរព្រះពុទ្ធគុណ ១ បទមុនជានិច្ចមិនដែលខាន ។ ព្រះដ៏មានបុណ្យទ្រង់សំដែងអាងដល់ហេតុនេះឯង ទើបទ្រង់សរសើរលោក ថាជាកំពូលនៃភិក្ខុទាំងឡាយ ខាងមានបញ្ញាបដិភាណឆ្លាតចងបទបាទគាថា ។ លុះលោកមានជ្រះជន្មដល់អាយុក្ស័យហើយ ក៏រំលត់ខន្ធបរិនិព្វាន ។

◇◇◇◇

# ៥១-ប្រវត្តិព្រះកុមារកស្សបត្ថេរ

ព្រះកុមារកស្សបត្ថេរ ជាបុត្ររបស់ធីតារបស់សេដ្ឋីម្នាក់នៅក្រុងរាជគ្រឹះ ។ ក្នុងកាលនោះ រឿងរ៉ាវមានសេចក្ដីដំណាលថា ធីតាសេដ្ឋីដែលជាមាតារបស់លោកប្រាថ្នាបព្វជ្ជាក្នុងព្រះសាសនា តាំងពីនាងនៅក្រមុំ ប៉ុន្តែនាងនិយាយអង្វរសូមអនុញ្ញាតមាតាបិតា មិនបានសោះ លុះដល់នាងមានស្វាមី ហើយផ្ដើមមានគភ៌ តែនាងមិនដឹងខ្លួន ក៏តាំងនិយាយអង្វរស្វាមីសូមអនុញ្ញាតទៅបួសទៀត ។ ស្វាមីក៏បានអនុញ្ញាតិយល់ព្រម ទើបនាងចេញទៅបួសជាភិក្ខុនី ក្នុងសំណាក់នាងភិក្ខុនីបែកខាងទេវទត្ត ។ [illegible]មក ផ្ទៃពោះនាងក៏ប្រាកដឡើង ទើបពួកនាងភិក្ខុនីមានសេចក្ដីរង្កៀស នាំខ្លួនទៅបង្ហាញដល់ព្រះទេវទត្ត ។ វិនិ[illegible]ថា នាងមិនមែនជាសមណី ត្រូវផ្សឹកចេញ ។ នាងភិក្ខុនីមានផ្ទៃពោះមិនសុខចិត្ត ព្រោះនាងសំគាល់ថា ខ្លួននាងបរិសុទ្ធស្អាត តាំងពីនាងបួសមក ។ ទើបភិក្ខុនីទាំងឡាយនាំនាងចូលទៅក្រាបបង្គំគាល់ព្រះបរមសាស្ដា ។ ទ្រង់ត្រាស់បង្គាប់ឱ្យព្រះឧបាលីជម្រះអធិករណ៍នោះ ។

ព្រះឧបាលីត្ថេរឱ្យចាត់រកមហាត្រកូលទាំងឡាយ ក្នុងនគរសាវត្ថី មាននាងវិសាខាមហាឧបាសិកាជាដើមមកជួបជុំគ្នាហើយ ទើបពិនិត្យពិសោធន៍ឱ្យឃើញការពិត ក៏បានដឹងជាក់ច្បាស់ថា នាងភិក្ខុនីនោះ ចាប់មានគភ៌មកតាំងពីនាងនៅជាគ្រហស្ថ ទើបលោកវិនិច្ឆ័យថា "សីលរបស់នាងភិក្ខុនីនេះបរិសុទ្ធឥតមន្ទិលទេ" ។

ព្រះបរមគ្រូទ្រង់ត្រាស់អនុមោទនាថា "ម្នាលឧបាលី អ្នកវិនិច្ឆ័យអធិករណ៍ត្រឹមត្រូវល្អហើយ ។ ឯនាងភិក្ខុនីនោះ លុះបានគភ៌គ្រប់កំណត់ហើយក៏ប្រសូតបុត្រប្រុសមួយ ។ ព្រះបាទបសេនទិកោសលទ្រង់ជ្រាប ក៏ទ្រង់ឱ្យគេមកទទួលយកទៅចិញ្ចឹមរក្សា ត្រាតែមានវ័យធំចំរើនឡើង ទើបទ្រង់នាំទៅបំពេញផ្នួសក្នុងសំណាក់ព្រះបរមសាស្ដា ។ លោកជាអ្នកសង្វាតព្យាយាមបំពេញសមណកិច្ចទាំងខាងផ្នែកគន្ថធុរៈ ទាំងខាងផ្នែកវិបស្សនាធុរៈ ។ តមកសម័យក្រោយ លោកបានស្ដាប់បញ្ហាព្យាករណ៍ ១៥៨ អំពីសំណាក់ព្រះបរមគ្រូក៏បានសម្រេចអរហត្តផល ព្រមដោយចតុប្បដិសម្ភិទាញ្ញាណ ហើយលោកចូលទៅអាស្រ័យនៅក្នុងព្រៃអន្ធវ័ន ។

ព្រះកុមារកស្សបត្ថេរនេះ មានសមត្ថភាពទាំងការសំដែងធម៌ដល់បរិស័ទទាំង ៤ បានយ៉ាងវិចិត្រពិស្ដារមានសេចក្ដីឧបមាព្រមទាំងហេតុផល ប៉ិនប្រសប់រកឧបាយទូន្មានបរិស័ទ ។ ព្រះបរមសាស្ដាទ្រង់ប្រារព្ធគុណធម៌នេះរបស់លោក ទើបទ្រង់សរសើរលោកថា ឆ្នើមជាងភិក្ខុទាំងឡាយខាងចិត្តកថាគឺពោលធម្មទេសនាយ៉ាងវិសេស លុះបានព្រះជន្មគ្រប់រាយុក្ខ័យ ហើយក៏បរិនិព្វាន ។

## ៥២- ប្រវត្តិព្រះមហាកោដ្ឋិតត្ថេរ

ព្រះមហាកោដ្ឋិតត្ថេរនេះ កើតក្នុងត្រកូលព្រាហ្មណ៍មហាសាលក្នុងក្រុងសាវត្ថី បិតាឈ្មោះអស្សសាយនព្រាហ្មណ៍ មាតាឈ្មោះនាងចន្ទវតីព្រាហ្មណី

លុះមានវ័យចំរើនហើយ បានសិក្សារចេះចប់គម្ពីរត្រៃវេទតាមលទ្ធិព្រាហ្មណ៍ ។ គ្រាមួយ កោដ្ឋិតមាណពបានចូលទៅគាល់ព្រះបរមសាស្តាស្តាប់ព្រះធម្មទេសនា កើតសទ្ធាជ្រះថ្លាក្នុងព្រះសាសនា ទើបចេញបព្វជ្ជាឧបសម្បទ ក្នុងសំណាក់ព្រះមហាមោគ្គល្លានត្ថេរ និងព្រះសារីបុត្តត្ថេរ ។ មានរឿងដំណាលទុកថា នៅវេលាលោកកោរកេសា លោកបានពិចារណាវិបស្សនាកម្មដ្ឋាន លះបង់តណ្ហាចេញបានក្នុងខណៈនោះ លុះផ្លាស់សំពត់សាដកចេញ ស្លៀកពាក់សំពត់កាសាវពស្ត្រ ក៏បានសម្រេចអរហត្តផល ព្រមដោយបដិសម្ភិទាញាណទាំង ៤ វិជ្ជា ៣ អភិញ្ញា វិមោក្ខ ៨ ។ ចាប់តាំងពីកាលនោះមក លោកយកចិត្តទុកដាក់ពីការសិក្សា កាលលោកចូលទៅរកព្រះមហាថេរធំៗ តែងចូលចិត្តសាកសួរប្រស្នាធម៌ក្នុងបដិសម្ភិទាទាំង ៤ សូម្បីលោកទៅគាល់ព្រះបរមសាស្តា ក៏ក្រាបទូលសួរក្នុងប្រស្នាធម៌ទាំងនេះដែរ ។

តមកសម័យក្រោយ ព្រះបរមសាស្តាទ្រង់ធ្វើមហាវេទល្លសូត្រឱ្យជាអត្ថុប្បត្តិហេតុហើយ ទើបទ្រង់តាំងលោកក្នុងឯតទគ្គដ្ឋាន គឺតំណែងឆ្នើមជាងភិក្ខុទាំងឡាយ ខាងបែកធ្លុះធ្លាយ ក្នុងបដិសម្ភិទាញាណទាំង ៤ ។ លុះលោកគង់នៅក្នុងព្រះសាសនាគ្រាតែដល់អាយុក្ខ័យហើយ ក៏រលត់ខ័ន្ធបរិនិព្វាន ។

## ៥៣-ប្រវត្តិព្រះសោភិតត្ថេរ

ព្រះថេរៈអង្គនេះកើតក្នុងត្រកូលព្រាហ្មណ៍នៅក្រុងសាវត្ថី មាននាមថាសោភិតមាណព ។ លុះចំរើនវ័យឡើង បានចូលទៅគាល់ព្រះបរមសាស្តា បានស្តាប់ព្រះធម៌ទេសនាដែលទ្រង់សំដែង ក៏កើតសទ្ធាជ្រះថ្លាចេញបព្វជ្ជាឧបសម្បទ

ក្នុងព្រះពុទ្ធសាសនា មានសេចក្តីព្យាយាមឧស្សាហ៍ចំរើនសមណធម៌ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ព្រមដោយបដិសម្ភិទាញាណទាំង ៤ ។ ព្រះថេរៈអង្គនេះ មានប្រក្រតីហែសន្សំនូវវិសីទាំង ៥ ប្រការ ស្ទាត់ជំនាញក្នុងបុព្វេនិវាសញ្ញាណ គឺការលើកជាតិពីមុនៗ មក ។ អាស្រ័យដំណើរនេះជាឧប្បត្តិហេតុ ទើបទ្រង់តាំងព្រះសោភិតត្ថេរក្នុងឯតទគ្គដ្ឋាន គឺជាឆ្នើមជាងភិក្ខុទាំងឡាយ ប៉ែកខាងលើកបុព្វេនិវាស ។ ព្រះសោភិតត្ថេរ មានជន្មាយុគ្រប់កំណត់កាលហើយ ទើបលោករំលត់ខ័ន្ធ បរិនិព្វាន ។

## ៥៤-ប្រវត្តិព្រះនន្ទុត្តេរ

ព្រះនន្ទុត្តេរ ជាបុត្រនៃត្រកូលព្រាហ្មណ៍មួយនៅក្រុងសាវត្ថី កាលចំរើនវ័យឡើង បានស្តាប់ព្រះធម្មទេសនា ក្នុងសំណាក់ព្រះបរមសាស្តា ក៏មានសទ្ធាជ្រះថ្លាក្នុងពុទ្ធសាសនា ទើបចេញបព្វជ្ជាឧបសម្ប័ទ ។ កាលលោកបានបួសហើយ តាំងនៅក្នុងសេចក្តីមិនប្រមាទ ឧស្សាហ៍ចំរើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ជាអសេខបុគ្គល ក្នុងព្រះសាសនា ជាអ្នកមានប្រក្រតីសន្សំនូវបុព្វេសនិវាសញ្ញាណស្ទាត់ជំនាញក្នុងការរលឹកជាតិក្នុងកាលមុន ហើយជាអ្នកឈ្លាសវៃក្នុងការសំដែងធម៌ដល់បរិស័ទទាំងមុនៗ គាប់ចិត្តនិងធម្មទេសនារបស់លោកណាស់ ។ មានសេចក្តីដំណាលថា លោកបានសំដែងធម៌ អំពីអាយតនៈទាំង ៦ ឱ្យនាងភិក្ខុនី ៥០០ រូបស្តាប់ បានសម្រេច

អរហត្តផលគ្រប់រូប ។ ព្រះបរមសាស្តាទ្រង់ជ្រាបច្បាស់សារព្វភាពរបស់លោកនេះ ជាដើមហេតុ ទើបទ្រង់តាំងលោកក្នុងតំណែងឯតទគ្គ គឺជាឆ្នើមជាងភិក្ខុទាំងឡាយប៉ែកខាងឱវាទដល់នាងភិក្ខុនី លុះលោកមានជន្មាយុសមគួរដល់កាលកំណត់ហើយ ទើបរំលត់ខ័ន្ធបរិនិព្វាន ។

# ៥៥~ប្រវត្តិព្រះមហាកប្បិនត្ថេរ

ព្រះមហាកប្បិនត្ថេរ ជាព្រះរាជឱរសរបស់ព្រះមហាក្សត្រក្នុងនគរកុក្កុដវតី ក្នុងបច្ចន្តជនបទ ។ ព្រះវររាជបិតាទីវង្គតទៅ លោកក៏បានឡើងគ្រប់គ្រងរាជ្យជាតំណតមក ។ ទ្រង់បានសណ្តាប់ពតិមាន អំពីពួកឈ្មួញក្រុងពារាណសី ថាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឧប្បត្តិឡើងក្នុងលោកហើយ ក៏ទ្រង់មានបីតិសោមនស្សយ៉ាងក្រៃលែង ទ្រង់ព្រះរាជទានរង្វាន់ដល់ពួកឈ្មួញហើយទើបទ្រង់ប្រគល់រាជសម្បត្តិដល់ព្រះអគ្គមហេសី សេ្តចព្រមទាំងព្រះរាជវង្សានុវង្ស និងសេវកាមាត្យរាជបរិវារស្តេចចេញទៅក្រាបទូលសូមឧសម្បទចំពោះព្រះបរមគ្រូ ឯនគរសាវត្ថី ។ លុះទ្រង់បានឧបសម្បទហើយ ទ្រង់ចំរើនសមណធម៌មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល ។

តមក មានរឿងដំណាលថា ព្រះនាងអនោជាទេវី ជាព្រះអគ្គមហេសីក៏បានលះបង់រាជសម្បត្តិ ព្រមដោយព្រះរាជវង្ស និងខ្ញុំរាជការនាងក្នុង ស្តេចចេញបព្វជ្ជាឧបសម្បទ ជាភិក្ខុនីក្នុងព្រះសាសនាដែរ ។ ព្រះពិជិតមារទ្រង់ប្រគល់ក្នុងសំណាក់នាងឧប្បលវណ្ណាថេរី ។

កាលព្រះមហាកប្បិនត្ថេរបានសម្រេចអរហត្តហើយ ក្នុងជាង់ដំបូង លោកមិនសូវហ៊ានទូន្មានអ្នកណាឡើយ ព្រោះមិនទាន់បានទទួលព្រះពុទ្ធានុញ្ញាតិ ។ ក្រោយមកព្រះអង្គទ្រង់អនុញ្ញាតិឱ្យលោកទូន្មានភិក្ខុជាបរិវាររបស់លោកមួយពាន់រូប បានសម្រេចអរហត្តផល ទើបព្រះដ៏មានបុណ្យទ្រង់ប្រារព្ធដល់សមត្ថភាពរបស់លោកនេះឯង ទ្រង់សរសើរលោកថាជាកំពូលនៃភិក្ខុទាំងប៉ែកខាងឱ្យឱវាទដល់ភិក្ខុបរិស័ទ។ លុះលោកមានព្រះជន្មដល់កំណត់អាយុក្ស័យហើយ ទើបរំលត់ខ័ន្ធបរិនិព្វាន ។

## ៥៦_ប្រវត្តិព្រះសាគតត្ថេរ

ព្រះសាគតត្ថេរ ជាបុត្រព្រាហ្មណ៍នៅក្រុងសាវត្ថី មាតាបិតាឱ្យឈ្មោះថា សាគតមាណព ។ លុះចំរើនវ័យធំឡើង បានស្តាប់ធម៌ទេសនាក្នុងសំណាក់ព្រះបរមសាស្តា កើតសទ្ធាជ្រះថ្លា ទើបចេញបព្វជ្ជាឧបសម្ប័ទជាបព្វជិត ញុំាងសមាបត្តិទាំង ៨ ប្រការឱ្យកើតឡើងហើយ បានចំរើនត្រាតែស្ទាត់ជំនាញក្នុងសមាបត្តិទាំង ៨ ប្រការនោះ ។

តមកថ្ងៃមួយ ព្រះបរមសាស្តាស្តេចត្រាច់ចារិកទៅកាន់ជនបទ ស្តេចដល់កំពង់ជិតខេត្តដែនកោសម្ពី ព្រមដោយភិក្ខុសង្ឃទ្រង់សម្រាកព្រះអង្គអស់មួយរាត្រីនៅកំពង់នោះ ។ ព្រះសាគតត្ថេរក៏តាមហែព្រះអង្គក្នុងឱកាសនោះដែរ ទើបលោកចូលទៅកាន់លំនៅនៃនាគរាជ១ ក៏សំដែងរិទ្ធិបង្ហុយផ្សែងភ្លើងផ្សព្វផ្សាយចូលទៅក្នុងលំនៅព្រះថេរៈ ១ ក៏ចូលតេជោកសិណបណ្តាលឱ្យកើត

ផ្សែងភ្លើងឡើងតទល់គ្នា ។ នៅទីបំផុតនាគរាជចុះចាញ់ព្រមលះបង់ពុះកំណាច ទទួលខ្លួនជាសិស្សហើយដល់ព្រះរតនត្រៃជាសរណៈ ។

ឯមហាជនអ្នកស្រុកកោសម្ពីបានដំណឹងថា អម្ពតិដ្ឋកនាគរាជនោះ ព្រះសាគតត្ថេរបានផ្ចាញ់ឱ្យអស់ពុតកំណោចហើយ ទើបនាំគ្នាទៅចាំទទួលព្រះបរមសាស្ដាថ្វាយគ្រឿងសក្ការបូជាដ៏ច្រើន ។ តពីនោះមក ពាំងនាំគ្នាចាត់រកសុរាមានសំបុរក្រហមដូចជើងព្រាប ដាក់ទុកនៅគ្រប់ៗ ផ្ទះ តាមពាក្យពន្យល់នៃពួកឆព្វគ្គិយភិក្ខុ ថាភិក្ខុឆាន់បាន មិនត្រូវអាបត្តិ ។ លុះព្រឹកឡើង ព្រះសាគតត្ថេរនិមន្តចូលទៅបិណ្ឌបាត ជនទាំងឡាយ ក៏នាំសុរានោះមកប្រគេន លោកក៏ទទួលឆាន់គ្រប់ៗ ផ្ទះមេ ដោយអំណាចទឹកសុរា ធ្វើឱ្យលោកស្រវឹងភ្លេចស្មារតីដួលរមៀលនៅកណ្ដាលផ្លូវឥតដឹងខ្លួន ។ ព្រះអង្គទ្រង់ជ្រាប ត្រាស់បង្គាប់ឱ្យពួកភិក្ខុទៅគ្រាហ៍លោកនាំខ្លួនមកវិហារ ។ ទ្រង់ត្មះតិះដៀលកណ្ដាលជំនុំភិក្ខុសង្ឃដោយអនេកបរិយាយហើយ ទើបទ្រង់បញ្ញត្តិសិក្ខាបទឈ្មោះថា សុរាបានសិក្ខាបទ ទុកជាច្បាប់សម្រាប់ភិក្ខុទាំងឡាយតរៀងមក ។

លុះដល់ព្រឹកឡើង លោកក៏បានស្វាងសុរាមានស្មារតីហើយ ក្រាបបង្គំទូលសូមខមាទោសញ៉ាំងព្រះបរមសាស្ដាឱ្យអត់ទោសហើយ កើតក្ដីសង្វេគស្លុតចិត្តនឹងកម្មដ៏លាមករបស់ខ្លួន ទើបលោកខំចំរើនវិបស្សនាកម្មដ្ឋានមិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល ។ កាលតមកព្រះដ៏មានបុណ្យស្ដេចប្រថាប់នៅជេតវនមហាវិហារ ទ្រង់ប្រោសប្រទានដំណែងឯតទគ្គដ្ឋានដល់ព្រះសាគតត្ថេរ ទុកជាឆ្នើមជាងភិក្ខុទាំងឡាយខាងឈ្លាសចូលតេជោកសិណសមាបត្តិ ។

គ្រងផ្ទះសំបែង ទើបគេចរត់ទៅសុំបព្វជ្ជាឧបសម្បទ ក្នុងសំណាក់ពួកអារញ្ញិកភិក្ខុ ។

លុះលោកបានបួសហើយ លោកខំចំរើនសមណធម៌នៅក្នុងព្រៃតិរអស់វេលាជាង ៣ ខែ ទើបបានសម្រេចអរហត្តផល ។ ព្រះបរមសាស្ដាទ្រង់ជ្រាប ស្ដេចទៅកាន់សំណាក់លោកជាមួយនឹងព្រះសារីបុត្រព្រមដោយភិក្ខុច្រើនរូប ។ លោកបានចាត់ការទទួលព្រះអង្គ ព្រមទាំងភិក្ខុសង្ឃដោយមាំមួន ។ ពេលសម័យក្រោយ លោកបានទទួលសេចក្ដីសរសើរពីព្រះពុទ្ធការថា ជាឆ្នើមជាងពួកភិក្ខុអ្នកនៅព្រៃ ។ លុះលោកមានជន្មាយុដល់កំណត់ហើយ ក៏រំលត់ខ័ន្ធបរិនិព្វាន ។

## ៥៩ ~ ប្រវត្តិព្រះសីវលិត្ថេរ

ព្រះសីវលិត្ថេរ ជាព្រះឱរសរបស់ព្រះនាងសុប្បវាសា ព្រះរាជធីតានៃព្រះចៅក្រុងកោលិយៈ ។ កាលលោកមកចាប់បដិសន្ធិ ក្នុងព្រះឧទរនៃព្រះវរមាតា ជាបហាបង្គេ ញុំាងព្រះវរមាតាឱ្យបរិបូណ៌ដោយលាភសក្ការៈដ៏ច្រើន ប៉ុន្តែនៅក្នុងគភ៌យូរណាស់ដល់ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ទើបប្រសូត ព្រោះកម្មចាស់តាមផ្ដល់ឱ្យផល ។ កាលដល់ថ្ងៃប្រសូតនោះ ព្រះវរមាតាប្រសូតងាយជាបំផុត ដូចជាទឹកហូរចេញពីក្អម ដោយហេតុនេះ ព្រះញាតិទាំងឡាយថ្វាយព្រះនាមតាមនិមិត្រនោះថា ព្រះសីវលិកុមារ ។ កាលមានព្រះជន្មចំរើនឡើងហើយ បានចេញទៅទ្រង់ព្រះផ្នួសក្នុងសំណាក់ព្រះសារីបុត្តត្ថេរ ឱ្យ

លោកមនសិការអំពីទុក្ខលក្ខណៈ ។ លោកចាប់យកធម៌ខនេះជាអារម្មណ៍ក្នុងខណៈជាត់កាំបិតកោរព្រះកេសាមួយកាំបិតដំបូងនោះ លោកបានសម្រេចសោតាបត្តិផល ។ ក្នុងខណៈកោរមួយកាំបិតទៀតជាគ្រាទីពីរ លោកបានសម្រេចសកទាគាមិផល ។ ក្នុងខណៈកោរមួយកាំបិតទៀតជាគ្រាទីបី លោកបានសម្រេចអនាគាមិផល ។ ក្នុងខណៈកោរព្រះកេសាហើយស្រេចលោកបានសម្រេចអរហត្តផលជាព្រះអសេខបុគ្គលក្នុងព្រះពុទ្ធសាសនា ។

ព្រះថេរៈអង្គនេះ ជាអ្នកមានអធ្យាស្រ័យធំទូលំទូលាយ គាប់ចិត្តនឹងការនាំព្រះភិក្ខុសង្ឃច្រើនៗ ឱ្យត្រេចទៅជាមួយនឹងលោក ដើម្បីជួយទំនុកបំរុងភិក្ខុទាំងឡាយឱ្យបានសុខសប្បាយ ដោយបច្ច័យលាភ ។ ទោះលោកនៅក្នុងទីណាក្តីនិមន្តទៅកាន់ទីណាក្តី រមែងបរិបូណ៌ដោយបច្ច័យលាភទាំង ៤ ដោយអានិសង្ស នៃទានបរិច្ចាគរបស់លោក ក្នុងបុព្វជាតិ ។ ក្នុងចំណោមពួកភិក្ខុបរិស័ទ មិនមានលោកអង្គណាប្រៀបផ្ទឹមស្មើនឹងខាងផ្លូវមានលាភច្រើន ។

អាស្រ័យហេតុនេះឯង ទើបព្រះដ៏មានបុណ្យទ្រង់សរសើរដំកើងលោកថាជាកំពូលនៃភិក្ខុទាំងឡាយ ដែលមានលាភច្រើន ។ លុះលោកមានជន្មាយុតាមសមគួរដល់អាយុក្ខ័យហើយ ទើបរំលត់ខ័ន្ធបរិនិព្វាន ។

## ៦០.ប្រវត្តិព្រះពាហិយទារុចិយត្ថេរ

ព្រះថេរៈអង្គនេះ កើតក្នុងផ្ទះនៃត្រកូលកុដុម្ពិក៍ ដែនពាហិយរដ្ឋ ។ កាលចំរើនវ័យឡើងប្រកបការចិញ្ចឹមជីវិត ដោយផ្លូវពាណិជកម្ម ។ គ្រាមួយលោកបានចុះសំពៅទៅជួយក្នុងខេត្តដែនសុវណ្ណភូមិ នៅមិនទាន់ដល់ប្រទេស

ពុងផ្លូវ នាវាក៏បែកធ្លុះធ្លាយក្នុងកណ្ដាលសមុទ្រសាគរ ។ ជនទាំងឡាយក្នុងសំពៅនោះ ក៏ទៅជាចំណីត្រីសមុទ្រអស់ទៅ នៅសល់តែខ្លួនលោកចាប់កោះបន្ទះក្ដារ ១ សន្ទឹក អណ្ដែតមកឡើងកំពង់សុប្បារកសដ្ឋនៈ លោកយកសារាយធ្វើសំពត់ស្លៀក កាន់អំបែងដើរសុំទានអាហារអ្នកស្រុក ។ ឯមហាជនបានឃើញលោកប្រព្រឹត្តដូច្នោះ ក៏យល់ថាជាព្រះអរហន្ត មានសេចក្ដីជ្រះថ្លាណាំគ្នាថ្វាយចំណុកបំរុងដោយបច្ច័យលាភ សំដែងអាការហាក់ដូចជាមិនត្រេកអរប្រព្រឹត្តជាសមណះអាក្រាត ។ គ្រាក្រោយមក ត្រឡប់មានគំនិតគិតឃើញថា [illegible] ពិតជាពុំធ្លាប់មានឡើយ ក៏កើតសង្វេគស្លុតចិត្ត ទើបចូលទៅគាល់ព្រះបរមគាតាឯនគរ[illegible] លុះបានស្ដាប់ធម្មទេសនាដែលទ្រង់សំដែងអំពីត្រៃសិក្ខា គឺសីល-សមាធិ-បញ្ញា លោកបានត្រិះរិះពិចារណាបញ្ជូនចិត្តទៅតាមក្រសែព្រះធម្មទេសនា ក៏បានសម្រេចអរហត្តផល ក្នុងទីអង្គុយនោះឯង ។ មានរឿងដំណាលថា លោកបានសម្រេចអរហត្តហើយ មិនទាន់បានបព្វជ្ជាឧបសម្បទ កំពុងត្រេចស្វែងរកបាត្រនឹងត្រៃចីវរ ចួនជាមានមេគោកូនខ្ចីដេញវាត់លោកនិព្វានទៅមុនបានឧបសម្បទ ។ សម័យក្រោយមក ព្រះបរមសាស្ដាទ្រង់សរសើរលោកថា ជាឆ្នើមជាងភិក្ខុទាំងឡាយ ប៉ែកខាងខិប្បាភិញ្ញា ជាអ្នកត្រាស់ដឹងធម៌ឆាប់រហ័ស ។

☆☆☆☆

# ៦១_ប្រវត្តិព្រះពាកុលត្ថេរ

ព្រះពាកុលត្ថេរ ជាបុត្រនៃមហាសេដ្ឋីនៅក្រុងកោសម្ពី ។ តាមប្រវត្តិមានរឿងដំណាលថា កាលលោកកើតមកបាន ៥ ថ្ងៃ មាតាបិតាធ្វើការមង្គលគោរសក់ព្រៃ ផ្ងូតទឹកកូនក្នុងទន្លេគង្គា ដើម្បីសាងលាភបុត្រ ។ ខណៈនោះ ត្រូវជាមានត្រីធំមួយបានឃើញទារកនោះសំគាល់ថាជាអាហារក៏ត្របាក់លេបចូលទៅក្នុងពោះ ។ ទារកនោះ មានបុញ្ញាភិនិហារច្រើនទើបមិនមានអន្តរាយអ្វីហាក់ដូចគេផ្ដេកលើកក្រោលក្នុងបន្ទប់ ។ ត្រីនោះលុះលេបទារកចូលទៅក៏កើតក្ដៅក្រហាយ ក៏ហែលរត់ចេញទៅយ៉ាងលឿនស្ទើរ ចូលទៅជាប់អួនរបស់ពួកអ្នកនេសាទត្រី ។ នាំត្រីចេញអំពីអួន ត្រីនោះក៏ស្លាប់ គេក៏នាំត្រីទៅលក់ឱ្យអ្នកស្រុក ដំឡៃ ១ ពាន់កហាបណៈ គ្មានអ្នកណាទទួលទិញ លុះនាំត្រីទៅដល់ផ្ទះសេដ្ឋីក្រុងពារាណសី១ ក៏ទទួលទិញត្រីនោះ ចាត់ឱ្យមនុស្សពន្លះពោះត្រីចេញស្រាប់តែឃើញទារកក្នុងពោះត្រី ទើបសេដ្ឋីឱ្យប្រកាសរកមាតាបិតារបស់ទារក មិនមានអ្នកណាមួយទទួលសោះ ទើបសេដ្ឋីក៏ចិញ្ចឹមរក្សាទារកនោះតមក ។

ឯមហាសេដ្ឋីស្រុកកោសម្ពីបានដឹងដំណឹងថា សេដ្ឋីក្រុងពារាណសីរើសបានកូនក្នុងពោះត្រី ក៏យល់ជាក់ច្បាស់ថាប្រាកដជាកូនរបស់ខ្លួនទើបទៅកាន់សំណាក់សេដ្ឋីក្រុងពារាណសី បានឃើញទារកក៏ស្គាល់ចាំបានហើយសុំទទួលយកទៅវិញ ។ ត្រកូលសេដ្ឋីទាំងពីរមិនសុខចិត្តតែរៀងខ្លួន កើតទៅជាវិវាទ

គ្នា ទើបនាំគ្នាឡើងក្រាបបង្គំទូលរឿងនោះដល់ព្រះចៅក្រុងពារាណសី ដើម្បីឱ្យទ្រង់វិនិច្ឆ័យសម្រេចដាច់ខាត ។ ឯព្រះចៅក្រុងពារាណសី មានព្រះតម្រាស់បង្គាប់ឱ្យត្រកូលសេដ្ឋីទាំងពីរជួយចិញ្ចឹមបីបាច់រក្សាទារកនោះទាំងសងខាង ហេតុនេះហើយបានជាលោកមាននាមថា ពាកុលៈ ប្រែថាមានប្រក្រតីនៅក្នុងត្រកូលទាំងពីរ ។ ត្រកូលសេដ្ឋីទាំងពីរក៏បានចាត់ចែងសង់ផ្ទះក្នុងស្រុករបស់ខ្លួនមួយខ្លងម្នាក់ ដើម្បីឱ្យពាកុលកុមារផ្លាស់ប្តូរនៅកំណត់រយៈ ៤ ខែ ព្រមដោយមនុស្សបម្រើទាំងប្រុស ស្រី ហើយក៏ទទួលជនដំណើរទៅវិញទៅមក កាលដល់កំណត់ ៤ ខែ ។

សម័យមួយ ព្រះបរមសាស្តាទ្រង់ប្រកាសផ្សាយព្រះសាសនាមកដល់ក្រុងពារាណសីស្រី ពាកុលកុមារព្រមដោយជនបរិវារចូលទៅគាល់ស្តាប់ព្រះធម្មទេសនា កើតសទ្ធាជ្រះថ្លាទើបក្រាបទូលសូមបព្វជ្ជាឧបសម្បទ ក្នុងពុទ្ធសាសនា លោកបានទទួលព្រះឱវាទក្នុងផ្លូវវិបស្សនាកម្មដ្ឋាន អំពីព្រះបរមសាស្តា បំពេញព្យាយាមអស់ ៧ ថ្ងៃ ក៏បានសម្រេចអរហត្តផល ជាអសេខ-បុគ្គលក្នុងព្រះពុទ្ធសាសនា ។ លោកជាអ្នកប្រព្រឹត្តនេសជ្ជិកធុតង្គ និងអារញ្ញិកធុតង្គយ៉ាងតឹងតែង តាំងអំពីលោកបួសមកប្រមាណ ៦០ ឆ្នាំហើយ មិនដែលគង់ចាំវស្សាក្នុងអាវាសជិតស្រុកឡើយ ហើយមិនដែលមានជម្ងឺដកាត់បៀតបៀនដល់ខ្លួនលោកសោះ មិនបាច់ខ្វល់ខ្វាយរក្សារាងកាយដោយភេសជ្ជៈ ដោយហោចទៅថ្នាំសម១ចំណិតក៏មិនដែលឆាន់ ទាំងនេះព្រោះតែពោលថាដោយអំណាចអានិសង្ឃ ដែលលោកបានឧបដ្ឋាកភិក្ខុជម្ងឺ ហើយបរិច្ចាគថ្នាំជាទាន

ក្នុងអតីតជាតិ ។

ព្រោះហេតុនេះឯង បានជាព្រះបរមសាស្ដាទ្រង់ត្រាស់សរសើរលោកថា ជាកំពូលនៃភិក្ខុទាំងឡាយដែលមានអាពាធតិច ។ ព្រះលោកមានជន្មាយុក្នុងព្រះសាសនា ដល់កំណត់អាយុក្ស័យហើយ ក៏បរិនិព្វាន ។ មានសេចក្ដីដំណាលថា កាលលោកនឹងនិព្វាននោះ លោកបានចូលតេជោសមាបត្តិ គង់និព្វានក្នុងកណ្ដាលព្រះភិក្ខុសង្ឃ ភ្លើងដែលកើតឡើងដោយបុញ្ញឫទ្ធិរបស់លោក បានឆេះរំលាយសរីរៈលោកឱ្យរលស់ទៅ ។

## ៦២. ប្រវត្តិព្រះទព្វមល្លបុត្តត្ថេរ

ព្រះថេរអង្គនេះ ជាព្រះឱរសរបស់ព្រះរាជទេវីជាមហេសីនៃព្រះបាទមល្លរាជ កាលព្រះជន្ម ៧ ខួបរាប់អំពីថ្ងៃប្រសូតមក លោកបានចូលទៅសូមអនុញ្ញាតព្រះមាតា បព្វជ្ជាជាសាមណេរក្នុងសំណាក់ព្រះបរមសាស្ដា បានទទួលព្រះឱវាទហើយ ចំរើនវិបស្សនាកម្មដ្ឋានបានសម្រេចអរហត្តព្រមដោយអភិញ្ញាទាំង ៦ និងបដិសម្ភិទា ៤ ក្នុងខណៈចុងកាំបិតកោរដាក់ដល់ព្រះសិរសា ។ អំណើះកាលតមក ព្រះដ៏មានបុណ្យទ្រង់សរសើរលោកថា ជាកំពូលនៃភិក្ខុទាំងឡាយខាងរៀបចំក្រាលសេនាសនៈ កាលលោកបានពិចារណាឃើញអាយុសង្ខារនឹងអស់បីជុំហើយ ទើបលោកសំដែងរិទ្ធិហោះឡើងទៅឯអាកាស រួចចូលតេជោសមាបត្តិ លុះចេញចាកសមាបត្តិហើយក៏រំលត់ខន្ធបរិនិព្វាន ទា កណ្ដាលអាកាសនុ៎ះឯង ។

ព្រះទព្វមល្លបុត្តត្ថេរនេះ បរិនិព្វានក្នុងវ័យមិនទាន់ចាស់ជរា មានកេចិ-
អាចារ្យពោលថា លោកត្រូវពួកភិក្ខុស្រុកមេត្តិយភូមិរកលេសចោទលោ
ដោយអាបត្តិបារាជិក មិនមានមូល កាលអធិករណ៍នេះស្ងប់រម្ងាប់ហើយនៅតែ
បបួលគ្នាជេរលោកទៀត ពួកភិក្ខុជាបុថុជ្ជនដែលជឿដល់ភិក្ខុមេត្តិយភូ
នោះ ក៏បានសេចក្តីរង្វៀសរើលងាយប្រមាថលោកដោយប្រការផ្សេងៗ
លោកគិតឃើញថា អាត្មាអញខំទ្រាំផ្ទុកភារៈដើម្បីប្រយោជន៍អ្វី គួរនិព្វានទេ
ល្អជាង ។ មានពួកកេចិអាចារ្យខ្លះទៀតពោលបដិសេធថា មិនសមហេតុស
ផល ធម្មតាព្រះខីណាស្រពលះបង់សោមនស្សទោមនស្សក្នុងលោកធម៌ហើយ
មិនរំជួលដោយពាក្យបង្វាចរបស់អ្នកដទៃ ហេតុដែលលោកនិព្វានពីវ័យក្មេ
ព្រោះអស់កិច្ចនឹងរក្សាបដែលទ្រទ្រង់ជន្មាយុតទៅទៀត[1] : រឿងនេះសូ
អ្នកត្រិះរិះពិនិត្យពិចារណាសន្និដ្ឋានដោយខ្លួនឯងផងចុះ ។

## ៦៣. ប្រវត្តិព្រះសុភូតិត្ថេរ

ព្រះថេរៈអង្គនេះ ជាបុត្រសុមនសេដ្ឋីនៅក្រុងសាវត្ថី លុះចំរើនវ័យឡើ
បានចូលទៅគាល់ព្រះបរមសាស្ដា បានស្ដាប់ព្រះធម្មទេសនាជាមួយនឹងអនាថ
បិណ្ឌិកសេដ្ឋី ក្នុងគ្រាធ្វើបុណ្យសម្ពោធជេតវនមហាវិហារក៏កើតសទ្ធាជ្រះថ្ល
ក្រាបទូលសូមបួសក្នុងព្រះសាសនា លុះបានបួសហើយ ក៏លោកខំសិក្សាវិន័យ
បិដកនឹងអភិធម្មបិដកត្រាតែបានចេះចាំស្ទាត់ជំនាញ រួចលោកគេចចេញទេ

---

១-ឧទាននិងអដ្ឋកថាឧទាន ។

ចំរើនសមណធម៌នៅក្នុងព្រៃមិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ។ តាមប្រក្រតី លោកជាអ្នកទ្រទ្រង់គុណធម៌ ២ ប្រការ គឺអរណវិហារស្នាក់នៅជាអ្នកខាងលោកុត្តរជ្ឈាន សម្រេចសម្រាន្តនៅដោយផុតពីកិលេសប្រការ ១ ជាទក្ខិណេយ្យបុគ្គលប្រការ ១ ។ ព្រោះអាស្រ័យគុណធម៌របស់លោកនេះឯងតមក ទើបលោកបានទទួលសេចក្ដីសរសើរអំពីព្រះបរមសាស្ដាថាជាកំពូលនៃភិក្ខុទាំងឡាយ ដោយគុណធម៌ពីរប្រការគឺអរណវិហារនឹងទក្ខិណេយ្យបុគ្គលដូចពោលមកហើយ ។ លុះលោកមានអាយុសង្ខារគ្រប់កំណត់ហើយក៏រំលត់ខ័ន្ធបរិនិព្វាន ។

## ៦៤-ប្រវត្តិព្រះភទ្ទិយរេវតត្ថេរ

ព្រះថេរៈអង្គនេះ កើតក្នុងត្រកូលដ៏ស្ដុកស្ដម្ភដោយភោគសម្បត្តិ ក្នុងក្រុងសាវត្ថី លុះចំរើនវ័យឡើង បានចូលទៅក្រាបថ្វាយបង្គំគាល់ព្រះសាស្ដា កើតសទ្ធាជ្រះថ្លា បានក្រាបទូលសូមឧបសម្បទក្នុងព្រះសាសនា ។ លុះលោកឧបសម្បទហើយតាំងនៅក្នុងសេចក្ដីមិនប្រមាទ ចំរើនសមណធម៌មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល ។ លោកជាអ្នកហែសង្ស័យក្នុងកប្បិយវត្ថុគឺរបស់ឬភស្តុភារដែលត្រឹមត្រូវតាមព្រះពុទ្ធានុញ្ញាតលោកហែសង្ស័យនឹងកប្បិយវត្ថុដែលបានមកនោះ លុះត្រាតែកាលណាលោកបានពិចារណាឃើញថាជាកប្បិយវត្ថុ ត្រឹមត្រូវតាមព្រះពុទ្ធានុញ្ញាតប្រាកដហើយ ទើបលោកហ៊ានបរិភោគប្រើប្រាស់ ។

ហេតុដូច្នេះហើយ បានជាព្រះថេរៈអង្គនេះ មាននាមបញ្ញត្តិថា ព្រះខទិរវនិយរេវត (ព្រះរេវត ព្រៃសង្វៀច) ។ លោកជាអ្នកស្ទាត់ជំនាញ ទាំងឈានលោកិយទាំងឈានលោកុត្តរ អាចចូលឈានសមាបត្តិដ៏ជាពុទ្ធវិស័យបានដោយច្រើនហេតុនេះបានជាព្រះបរមសាស្តាទ្រង់សរសើរលោកថា ជាកំពូលនៃភិក្ខុទាំងឡាយអ្នកត្រេកអរក្នុងឈានសមាបត្តិ ។

លុះលោកមានអាយុសង្ខារសមគួរដល់កាលវេលាហើយ គឺរំលត់ខន្ធបរិនិព្វាន ។

## ៦៥-ប្រវត្តិព្រះនាលកត្ថេរ

ព្រះថេរៈអង្គនេះ ជាបុត្ររបស់ប្អូនស្រីនៃអសិតតាបស ឬកាឡទេវិលតាបស នៅក្នុងក្រុងកបិលពស្តុ កាលកាឡទេវិលតាបសបានពិនិត្យឃើញព្រះមហាបុរស មានព្រះលក្ខណៈត្រូវតាមតម្រាព្យាករណ៍របស់ព្រាហ្មណ៍ហើយ ទើបនិយាយណែនាំនាលកមាណពក្មួយឱ្យចេញបួសប្រព្រឹត្តវត្តតាបសស្រាប់ហើយ រង់ចាំព្រះមហាបុរស បើស្តេចចេញទ្រង់ព្រះផ្នួសនឹងបានត្រាស់ជាព្រះពុទ្ធជាសាស្តាឯកក្នុងលោក ។ កាលព្រះអង្គបានត្រាស់ដឹងហើយនាលកបរិព្វាជកបានដំណឹង ក៏ចូលមកគាល់ទូលសួរបញ្ហាក្នុងមោនេយ្យបដិបត្តិ ។ ព្រះអង្គទ្រង់សំដែងមោនេយ្យបដិបត្តិ មានន័យជាអាទិថា គប្បីធ្វើចិត្តឱ្យស្មើទូទៅក្នុងសត្វបុគ្គលទាំងពួង មិនខឹងមិនទោមនស្សទាស់ចិត្ត កាលបើត្រូវបរិយាកាស ... ។ លុះចប់ព្រះធម្មទេសនា លោកក្រាបទូលសូមបួសក្នុងធម្មវិន័យ កាលបានបួស

ហើយ បានក្រាបទូលព្រះបរមសាស្តាទៅនៅព្រៃ តាំងសេចក្តីព្យាយាមយ៉ាងឧក្រិដ្ឋប្រព្រឹត្តជាមនុស្សថ្មីជានិច្ចមិនស្និទ្ធស្នាលនឹងអ្នកស្រុកមិនជាប់ចិត្តនឹងបុគ្គលឬនឹងទីលំនៅ ប្រកបដោយសន្តោសប្រាជ្ញាតិច ក្នុងការឃើញ-ការស្តាប់-ការសួរ មិនយូរប៉ុន្មាន បានសម្រេចព្រះអរហត្ត ១ មានជន្មាយុបាន ៧ ខែក៏បរិនិព្វាន ដោយឥរិយាបថឈរនៅចំពោះព្រះភក្ត្រព្រះដ៏មានបុណ្យ ។ លោកជាមហាសាវកអង្គ ១ ដែលបានបំពេញមោនេយ្យបដិបត្តិយ៉ាងឧក្រិដ្ឋក្នុងសាសនានេះ បានទទួលសេចក្តីសរសើរអំពីព្រះដ៏មានបុណ្យថា ជាកំពូលនៃពួកភិក្ខុដែលបំពេញមោនេយ្យបដិបត្តិ ។ លោកសំដែងទុកថា អ្នកបដិបត្តិក្នុងមោនេយ្យបដិបត្តិយ៉ាងឧក្រិដ្ឋ មានជីវិតរស់នៅបាន ៧ ខែយ៉ាងកណ្តាល ៧ ឆ្នាំ យ៉ាងទន់ទាប ១៦ ឆ្នាំ ហើយក្នុងសាសនារបស់ព្រះពុទ្ធ ១ អង្គ ៗ មានព្រះសាវកបែបនេះតែមួយអង្គប៉ុណ្ណោះ ។

# ៦៦-ប្រវត្តិព្រះអង្គុលិមាលត្ថេរ

ព្រះអង្គុលិមាលត្ថេរ ជាបុត្រនាងព្រាហ្មណីដ៏ជាភរិយារបស់ព្រាហ្មណ៍បុរោហិត របស់ព្រះបាទបសេនទិកោសល មាតាបិតាតាំងឈ្មោះថា អហិង្សកកុមារ ព្រោះកាលអហិង្សកកុមារប្រសូតចាកគភ៌នៃមាតា បណ្តាគ្រឿងសាស្ត្រាវុធដែលមានក្នុងទីក្រុងនោះ ព្រមទាំងព្រះខ័នរាជ្យរបស់ព្រះបាទបសេនទិកោសល មានពន្លឺភ្លឺច្រាលដាងអណ្តាតភ្លើង ។ ព្រាហ្មណ៍បុរោហិតជាបិតា ពិចារណាមើលឫក្សខាងលើក៏ដឹងជាក់ច្បាស់ថា បុត្ររបស់ខ្លួនកើតត្រូវ

ឫក្សចោរ ហើយនាំសេចក្តីនេះក្រាបបង្គំទូលព្រះបាទបសេនទិកោសលពេល ការពិត ។ ដោយហេតុជានិមិត្តអាក្រក់ ប៉ុន្តែគ្មានអន្តរាយដល់ជនណាមួយឡើយ ទើបព្រាហ្មណ៍តាំងនាមបុត្រថា "អហិំសកៈ"១ ប្រែថា "អ្នកមិនបៀតបៀន" ។

កាលអហិំសកុមារពេញវ័យឡើងមាតាបិតាចាត់បញ្ជូនខ្លួនឱ្យចេញទៅសិក្សាសិល្បសាស្ត្រក្នុងសំណាក់អាចារ្យទិសាបាមោក្ខ ស្រុកតក្កសិលា ។ អហិំសកុមារតាំងចិត្តរៀនសូត្រដោយគោរពប្រព្រឹត្តវត្តបដិបត្តិរៀបរយ ជាទីពេញចិត្តនៃអាចារ្យពេកណាស់ ។ ពួកកុមារដែលជាសិស្សជាមួយគ្នា កាលឃើញអហិំសកុមារគ្រាន់បើជាងខ្លួន ទាំងខាងផ្លូវរៀនសូត្រ ទាំងខាងផ្លូវប្រព្រឹត្ត ក៏មានចិត្តប្រណែនឈ្នានីស នាំគ្នារកឧបាយញុះញង់អាចារ្យឱ្យស្អប់ហើយកំចាត់ចេញ ។ អាចារ្យក៏ជឿទើបគិតរកឧបាយខ្ចីដៃអ្នកដទៃឱ្យប្រហារជីវិតកុមារ ដោយប្រាប់ឧបាយឱ្យអហិំសកុមារចេញទៅរកសម្លាប់មនុស្ស ហើយកាត់យកម្រាមដៃម្នាក់មួយៗ ឱ្យបានគ្រប់១ពាន់នាក់ ។ អហិំសកុមារទោះបីមានរង្វៀស ដោយខ្លួនជាតិជាព្រាហ្មណ៍ មិនគួរសម្លាប់មនុស្សឱ្យខុសពីប្រពៃណីព្រាហ្មណ៍ ក៏ត្រូវតែបង្ខំខ្លួនចិត្តធ្វើ ព្រោះចង់បានសម្រេចវិជ្ជាសិល្បសាស្ត្រ ដែលហៅថា វិស្ណុបន ។

កុមារនោះដើរចេញទៅកាប់សម្លាប់មនុស្សពីរបីនាក់ យកទៅដាក់ : ទៅព្យួរគល់ឈើ នោះមានចំនួនច្រើនហើយស្អុយរលួយអស់ទៅ ។ គ្រាក្រោយមក កុមារនោះសម្លាប់ការនោះហើយ ក៏កាត់យកម្រាមដៃដោតក្រងជា

ចង្កោមពាក់ទីងក រាប់បានចំនួនប្រាបដែលដល់ ៩៩៩ ប្រាប នៅខ្វះតែម្រាមមួយទៀតនឹងបានគ្រប់ ១០០០ ទើបមានឈ្មោះតាមនិមិត្រនោះថា អង្គុលិមាលចោរ ។

ដំណើរដែលនាំឱ្យពាក់ស្ពឹតវទ្ធត់ស្ញប់ស្ញែងនេះ បានសាយចេញទៅក្នុងស្រុកនិគមជនបទផ្សេងៗ ។ ព្រះបាទបសេនទិកោសលទ្រង់ជ្រាបទ្រង់ចាត់ឱ្យត្រៀមរេហ៍ពល នឹងលើកចេញចោមចាប់សម្លាប់អង្គុលិមាលចោរ ឯនាងព្រាហ្មណីជាមាតាបានដឹងពត៌មាននេះ ក៏យល់ថាភ័យអន្តរាយនឹងមានដល់កូន ទើបនាងប្រញាប់ប្រញាល់ចេញទៅមុនកងទ័ព ដើម្បីប្រាប់ហេតុឱ្យកូនបានដឹងខ្លួន ។ តាមប្រវត្តិមានសេចក្ដីដំណាលថា ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ទ្រង់ជ្រាបថាអង្គុលិមាលចោរធ្វើមាតុឃាតកកម្ម ផុតរបូតចាកមគ្គផលមិនខាន ទើបស្ដេចប្រញាប់ទៅប្រោស បានជួបនឹងអង្គុលិមាលក្នុងពេលព្រលឹមស្រាងៗ ។ អង្គុលិមាលគ្រាន់តែក្រឡេកឃើញព្រះអង្គ ក៏ដេញតាមស្ទៅសំដៅព្រះអង្គប៉ងនឹងកាត់យកម្រាមព្រះហស្ដព្រះអង្គឱ្យបានគ្រប់ចំនួន ១០០០ ប្រាប ។ ពោរកថាដោយអំណាចព្រះបាដិហារ្យ អង្គុលិមាលរត់ចេញតាមយ៉ាងណាៗ ក៏មិនទាន់ដល់ហត់ណាស់ក៏ស្រែកហៅឱ្យព្រះអង្គឈប់ ។ ព្រះដ៏មានបុណ្យមានព្រះពុទ្ធដីកាថា "ព្រះអង្គឈប់ហើយតើ !" តែគេដេញតាមមិនទាន់ ទើបចោទព្រះបរមសាស្ដាថាត្រាស់មុសាវាទ ។ ព្រះអង្គត្រាស់តបថា "តថាគតឈប់ចាកអំពើអកុសលទាំងឡាយដែលឱ្យផលជាទុក្ខមកយូរហើយ អ្នកឯងទេតើដែលមិនទាន់ឈប់ចាកបាបធម៌ដូច្នោះ" ។ ព្រះពុទ្ធដីកាប៉ុណ្ណោះ ធ្វើឱ្យអង្គុលិមាល

ភ្ញាក់ស្មារតីរលឹកឃើញទោសរបស់ខ្លួន ទើបដោះគ្រឿងអាវុធនិងក្រងម្រាមដៃចេញហើយយកទៅបោះចោលក្នុងប្រឡាយ រួចមកក្រាបថ្វាយបង្គំទូលសូមបព្វជ្ជាឧបសម្បទ ។ ព្រះអង្គទ្រង់អនុញ្ញាតឲ្យបួសជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទាហើយ ទ្រង់នាំមកព្រះវិហារជេតពន ។

ដល់ព្រឹកឡើងលោកនិមន្តទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី អ្នកស្រុកនានា ឃើញលោកនាំគ្នាគិតភិតភ័យភ្ញាក់ផ្អើល រត់ចូលទៅក្នុងកំពែងព្រះនគរ ហើយនាំគ្នាបិទទ្វារនគរទាំងតូចទាំងធំ បានសូរស័ព្ទនិយាយលាន់ឮផ្សេងៗ ខ្លះថា អង្គុលិមាលបួសខ្លួនជាភិក្ខុ ដើម្បីឲ្យរួចពីរាជភ័យ ខ្លះថា អង្គុលិមាលចូលមកក្រុងចង់ប្រទុស្តរ៉ាយមនុស្សនៅក្នុងក្រុង ។ លោកនិមន្តទៅដល់ទីណា ក៏មានសំឡេងឮស៊ានដល់ទីនោះ គ្មានជនណាមួយមានសទ្ធាប្រគេនចង្ហាន់លោកមួយវែកឡើយ លោកអង្គណានិមន្តទៅជាមួយនឹងលោកក្នុងថ្ងៃនោះ សឹងអត់ចង្ហាន់គ្រប់រូប គួរឲ្យអាសូរករុណាពន់ពេក ។ មួយជាមានជោគល្អ លោកបានធ្វើឲ្យស្ត្រីម្នាក់ប្រសូតបុត្របានដោយងាយ គឺនាងនោះប្រសូតងាយស្រួលណាស់ ដូចជាគេចាក់ទឹកចេញពីក្អម ។ បាលីដែលលោកសូត្រនោះដូច្នេះ "យតោហំ ភគិនិ អរិយាយ ជាតិយា ជាតោ នាភិជានាមិ សញ្ចិច្ច បាណំ ជីវិតា វោរោបេតា តេន សច្ចេន សោត្ថិ តេ ហោតុ សោត្ថិ គព្ភស្ស[១]" ។ ប្រែថា "ប្អូនស្រី. ចាប់ដើ

១ គាថានេះ គេនិយមប្រើក្នុងពិធីមង្គល ហើយប្រើជាគាថាផ្លុំទឹកមន្ត សម្រាប់ស្ត្រីគភ៌ពេលមកដល់គ្រាផ្ទៃនេះក៏បានខ្លះ ។

តាំងពីអាត្មាបានកើតដោយអរិយជាតិ ហើយអាត្មាមិនដែលបានផ្ដាច់ជីវិតសត្វឡើយ ដោយអំណាចពាក្យសត្យនោះ សូមសេចក្ដីសួស្ដីចូរមានដល់នាងដល់គភ៌របស់នាងផងចុះ" ។

តាំងអំពីកាលនោះមក មានគេនិយមរាប់អានលោក លែងខ្លាចលោកដូចកាលពីមុននោះទៀត កាលលោកបានស្រួលខាងផ្លូវចិញ្ចឹមជីវិតហើយ ក៏ខំតាំងចិត្តចំរើនសមណធម៌ ឥតធុញទ្រាន់ ប៉ុន្តែចិត្តលោករាយមាយមិនអាចរួបរួមឱ្យកើតសមាធិ ព្រោះពួកខ្មោចមនុស្សដល់លោកបានសម្លាប់មកប្រាកដជានិមិត្ត ឱ្យកើតសេចក្ដីក្ដៅក្រហាយស្ដាយក្រោយជានិច្ច ។ ព្រះបរមសាស្ដាទ្រង់ជ្រាប ទើបទ្រង់ណែនាំឱ្យលោកព្យាយាមលះបង់អារម្មណ៍ដែលកន្លងទៅហើយ កុំនឹកដល់អារម្មណ៍មិនទាន់មានមកដល់ ឱ្យពិចារណាតែកិច្ចការដែលប្រាកដនៅចំពោះមុខ ។ លោកប្រើសតិពិចារណាសីលនឹងកម្មទៀតៗ របស់លោកជាបច្ចុប្បន្នមិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល រាប់ចូលក្នុងពួកមហាសាវករង្គមួយ លោកបានទទួលសេចក្ដីសរសើរអំពីព្រះបរមសាស្ដាថាជាកំពូលនៃពួកភិក្ខុជាសាបីបរិភោគ មិនជាទោសនៃពណ្ណា ។ លុះលោកបានជន្មាយុក្នុងព្រះសាសនា សមគួរដល់កាលកំណត់ហើយ ក៏រំលត់ខន្ធបរិនិព្វាន ។

*****

## ៦៧.ប្រវត្តិព្រះភគុ

ព្រះថេរៈអង្គនេះ កើតក្នុងសាក្យត្រកូលនាក្រុងកបិលពស្តុ ។ ភគុ-សាក្យកុមារកោនសទ្ធាជ្រះថ្លាបានចូលបួសក្នុងពុទ្ធសាសនាជាមួយក្សត្រសាក្យដទៃទៀត ៤ អង្គ ។ ភគុកុមារកាលបើបានបួសហើយ ខំចំរើនវិបស្សនាកម្មដ្ឋានរហូតដល់បានសម្រេចអរហត្ត ជាអសេខបុគ្គល ។

## ៦៨.ប្រវត្តិព្រះកម្ពិលៈ

ព្រះកិម្ពិលៈបានកើតក្នុងសាក្យត្រកូល នាក្រុងកបិលពស្តុ មានវ័យចំរើនឡើងបានចេញទៅបួសជាមួយក្សត្រសាក្យដទៃ ៤ អង្គមានអនុរុទ្ធជាដើម ។ លុះបួសហើយខំចំរើនវិបស្សនាកម្មដ្ឋាន ដរាបបានសម្រេចព្រះអរហត្តជាអសេខបុគ្គល ។

## ៦៩.ប្រវត្តិព្រះលកុណ្ឌកភទ្ទិយៈ

ព្រះថេរៈអង្គនេះ ជាបុត្រអ្នកមានសម្បត្តិស្តុកស្តម្ភម្នាក់ក្នុងក្រុងសាវត្ថី។ ថ្ងៃមួយលកុណ្ឌកុមារបានទៅស្តាប់ធម្មទេសនាព្រះបរមសាស្តាជាមួយពួកឧបាសក-ឧបាសិកា កើតសេចក្តីជ្រះថ្លាបានចូលទៅបួសក្នុងពុទ្ធសាសនា ។ លុះបួសរួចហើយសិក្សាកម្មដ្ឋានក្នុងសំណាក់ព្រះបរមគ្រូមិនយូរប៉ុន្មានបានសម្រេចសោតាបត្តិផល ។ តមកលោកបានសន្ទនាធម៌កថាជាមួយព្រះសារីបុត្រ បានធ្វើចិត្តឱ្យរលត់ផុតអាសវក្កិលេស បានសម្រេចអរហត្តផល ជាអសេខបុគ្គល ។ លោកបានទទួលឋានៈជាឯតទគ្គៈ ប៉ែកខាងមានសម្លេងពិរោះ ។

## ៧០~ប្រវត្តិព្រះកុណ្ឌធាន

ព្រះថេរៈអង្គនេះ កើតក្នុងត្រកូលព្រាហ្មណ៍នាក្រុងសាវត្ថី នាមដើមថា ធានមាណព ។ ធានមាណពមានវ័យចំរើនឡើងបានសិក្សាចេះចប់គម្ពីរត្រៃវេទ ។ តមកបានចូលក្នុងពុទ្ធសាសនា ។ ចាប់តាំងពីបួសហើយ ស្រាប់តែមានរូបស្ត្រីម្នាក់ដើរតាមលោកជានិច្ច តែខ្លួនលោកមិនបានឃើញទេ ។ កាលដែលលោកចូលទៅបិណ្ឌបាតក្នុងភូមិ អ្នកស្រុកដែលប្រគេនចង្ហាន់តែងនិយាយថា នេះជាចំណែកលោក នេះជាចំណែកសម្លាញ់លោក ។ តាំងពីពេលនោះមកគេតែងនាំគ្នាហៅលោកថា កុណ្ឌធាន ។ រឿននេះបានធ្វើឱ្យភិក្ខុក្នុងសង្ឃមណ្ឌលមានសេចក្តីរង្កៀសជាខ្លាំង ។ ព្រះដ៏មានព្រះភាគទ្រង់បានជ្រាប ហើយហៅភិក្ខុទាំងអស់មកសំដែងប្រាប់អំពីបុព្វកម្មរបស់កុណ្ឌធាន ។ លុះស្តាប់ចប់ហើយ កុណ្ឌធានភិក្ខុ បានសម្រេចព្រះអរហត្តផល ។ លោកបានទទួលតំណែងជាឯតទគ្គៈ ខាងអ្នកបានចាប់ស្លាកជាបឋម ។

## ៧១~ ប្រវត្តិព្រះបិលិន្ទវច្ឆៈ

ព្រះថេរៈអង្គនេះ កើតក្នុងត្រកូលព្រាហ្មណ៍វច្ឆគោត្រឈ្មោះដើម "បិលិន្ទៈ" រួមនឹងគោត្រផងជា "បិលិន្ទវច្ឆៈ" ។ កាលលោកមានវ័យចំរើនឡើងមានសេចក្តីជ្រះថ្លាបានចូលបួសក្នុងពុទ្ធសាសនា ខំបំពេញសេចក្តីព្យាយាមចំរើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានបានសម្រេចអរហត្តផល ។ តាំងពីកាលនោះមកព្រះបិលិន្ទវច្ឆត្ថេរតែងហៅភិក្ខុទាំងឡាយថា "វសលៈ" ប្រែថា "គម្រក់" ជា

ពាក្យថោកទាប ។ ភិក្ខុទាំងឡាយទោមនស្សនាំគ្នាក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា អ្នកទាំងឡាយកុំលើកទោស កុំប្រកាន់ទោសចំពោះបិលិន្ទវច្ឆភិក្ខុឡើយ ព្រោះភិក្ខុនេះធ្លាប់កើតក្នុងត្រកូលព្រាហ្មណ៍អស់៥០០ ជាតិ ពួកព្រាហ្មណ៍តែងនិយាយយ៉ាងនេះ ។

ព្រះបិលិន្ទវច្ឆៈ បានទទួលឋានៈជាឯតទគ្គៈ ខាងជាទីស្រឡាញ់ពេញចិត្តនៃពពួកទេវតា ។

## ៧២-ប្រវត្តិព្រះឧទាយី

ព្រះថេរៈអង្គនេះ ពុំមានប្រវត្តិអ្វីបញ្ជាក់ឱ្យច្បាស់លាស់ ក្នុងពេលនៅជាយរាវាសឡើយ ។

លោកបួសហើយមានឈ្មោះល្បីល្បាញខាងការសំដែងធម៌ជាទីគាប់ចិត្តដល់បរិស័ទទាំងឡាយ ព្រោះលោកបានតម្កល់នូវធម៌ ៥ ប្រការក្នុងខ្លួនលោកជានិច្ច ។ លោកមានជន្មាយុក្នុងពុទ្ធសាសនាត្រាតែសមគួរដល់កាលកំណត់ទើបរំលត់ខន្ធបរិនិព្វាន ។

## ៧៣-ប្រវត្តិព្រះឧបវាណៈ

ព្រះថេរៈអង្គនេះ ពុំមានប្រវត្តិក្នុងពេលមុនបួសទេ ។ រឿងរ៉ាវរបស់លោកមានក្នុងពេលបួសរួចហើយ ។ ព្រះឧបវាណត្ថេរនេះធ្លាប់បានជាពុទ្ធដ្ឋាកព្រះបរមគ្រូក្នុងពេលជិតបរិនិព្វាន ។ ពេលនោះមានដំណាលថា ព្រះឧបវាណត្ថេរកំពុងបក់ផ្លិតថ្វាយព្រះអង្គ១ បានបណ្តេញឱ្យគេចចេញអំពីព្រះភ័ក្ត្រព្រះអង្គ

ក្នុងពេលដែលពពួកទេវតាកំពុងបកបោយរោយផាប់ ។ ព្រះថេរៈអង្គនេះ បាន ព្រះជន្មាយុរហូតដល់ក្រោយពុទ្ធបរិនិព្វានទើបបរិនិព្វាន ។

## ៧៤-ប្រវត្តិព្រះមេឃិយៈ

ព្រះថេរៈអង្គនេះ កាលនៅជាគ្រហស្ថពុំមានប្រវត្តិអ្វីច្បាស់លាស់ទេ លុះដល់បួសរួចហើយទើបមាន ។

ព្រះថេរៈអង្គនេះធ្លាប់ជាពុទ្ធុបដ្ឋាកៈ១រូបដែរ ដូចមានសេចក្តីបញ្ជាក់ថា កាលលោកនិមន្តទៅបិណ្ឌបាតបានឃើញចំការស្វាយមួយ មានម្លប់ដ៏ត្រជាក់ គួរជាទីរីករាយចិត្ត លោកចង់ទៅធ្វើសមណធម៌នៅទីនោះ ទើបចូលទៅក្រាបបង្គំលាព្រះសាស្តា ព្រះអង្គទ្រង់ឃាត់ថា ឥឡូវនៅតែម្នាក់ឯងរង់ចាំមានភិក្ខុដទៃមកផ្លាស់វេនឧបដ្ឋាកជំនួសសិន. ទ្រង់មានព្រះពុទ្ធដីកាដូច្នេះ ៣ ដង មេឃិយៈមិនស្តាប់ហើយគេចចេញទៅ ។ មេឃិយត្រេចរីនសមណធម៌នៅទីនោះ មិនបានសម្រេចផលអ្វីទេ ព្រោះមានវិតក្ក ៣ យ៉ាងចូលមកញាំញីចិត្ត ទើបត្រឡប់មកក្រាបបង្គំទូលព្រះសាស្តាវិញ ។ ព្រះអង្គទ្រង់ទូន្មានទូវវិធីរម្ងាប់វិតក្ក ៣ ប្រការជាអនេកបរិយាយ ។ មេឃិយៈឋិតនៅក្នុងព្រះឱវាទរបស់ព្រះអង្គ ខំចំរើនវិបស្សនាកម្មដ្ឋាន មិនយូរប៉ុន្មានបានសម្រេចអរហត្តផលជាអសេខបុគ្គល ។

## ៧៥-ប្រវត្តិព្រះនាគិតៈ

ព្រះថេរៈអង្គនេះពុំមានប្រវត្តិច្បាស់ក្នុងពេលមុនបួសទេ ។ កាលបួស

ប៉ុន្តែមានបញ្ជាក់ថា ព្រះថេរៈអង្គនេះធ្លាប់បានជាឧបដ្ឋាកៈព្រះបរមសាស្តាក្នុង ពេលដែលព្រះអង្គ បួយអញ្ជើញដោយភិក្ខុសង្ឃត្រាច់ទៅកាន់កោសលជនបទ ។ ពេលនោះពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកផល្លាមង្គលៈនាំគ្នាចាត់ចែងត្រៀង បាយទឹកភោជនាហារជាដើមចូលទៅគាល់ព្រះអង្គ ហើយនាំគ្នានិយាយពាក្យពូ ទ្រហឹងអឺងកងនៅខាងក្រៅក្លោងទ្វារវត្ត ។ ព្រះបរមសាស្តាទ្រង់បន្ទូលចំពោះ នាគិតៈជាឧបដ្ឋាកៈ ១ ពេលក្រោយទូលពាបធ្វើរឿង .... ។

ព្រះនាគិតៈនេះ លោកបានសម្រេចព្រះអរហត្តផលជាអសេខបុគ្គល ១ អង្គក្នុងពុទ្ធសាសនា ប៉ុន្តែពុំបានដឹងថាលោកបានសម្រេចនៅពេលណាឡើយ ។

## ៧៦. ប្រវត្តិព្រះចុន្ទៈ

ព្រះថេរៈអង្គនេះជាបុត្រវង្គន្តព្រាហ្មណ៍ មាតានាមនាងសារីព្រាហ្មណី នៅក្នុងស្រុកនាលន្ទៈ មគធរដ្ឋ ត្រូវជាប្អូនព្រះសារីបុត្រ ។ ឆាបដើមថា ចុន្ទៈ តមកបាននាមមួយថ្មីទៀតថា មហាចុន្ទៈ ។ លោកធ្លាប់បានធ្វើជាពុទ្ធុបដ្ឋាកៈ ក្នុងពេលដែលព្រះដ៏មានបុណ្យស្តេចយាងទៅបរិនិព្វានទៅនាក្រុងកុសិនារា ។ មហាចុន្ទនេះជាធម្មកថិកមួយអង្គ ។ លោកបានចូលទៅក្រាបទូលសួរអំពីទិដ្ឋិ ដែលជាប់ទាក់ទងនឹងខ្លួន ជាប់ទាក់ទងនឹងលោក តើត្រូវធ្វើមនសិការដូចម្តេច ទើបលះបង់ទិដ្ឋិទាំងនោះបានដាច់ខាត ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងវិធីដុសខាត់កិលេសឱ្យលោកស្តាប់ជាអនេកបរិយាយ ។ ទីបំផុតលោកបាន សម្រេចព្រះអរហត្ត ។

ក្នុងពេលដែលព្រះសារីបុត្រ ជាបងទៅបរិនិព្វាន ឯស្រុកកំណើតដើម្បី

ព្រោសមាតាលោក មហាធុនៈនេះបានចិញ្ចឹមទៅជាប្តីដែរ ។ ពេលនោះ មហាធុនៈបានប្រមូលបាត្រចីវរ ព្រមទាំងអដ្ឋិធាតុព្រះសារីបុត្តត្ថេរ នាំយកថ្វាយដល់ព្រះបរមសាស្តា ។

## ៧៧-ប្រវត្តិព្រះយសោជៈ

ព្រះយសោជៈនេះ កើតក្នុងត្រកូលអ្នកនេសាទ នាក្រុងសាវត្ថី. បិតាលោកជានាយកនៃអ្នកនេសាទ ៥០០ ត្រកូល ។ កាលលោកប្រសូត. មានទារកនៃនាយនេសាទទាំង ៥០០ បានកើតក្នុងថ្ងៃជាមួយគ្នាដែរ ។ មាតាយសោជៈកុមារបានចំរុងចំរើនទារកទាំង ៥០០ នោះ ហៅការចេញព្រែមើក ដោះជាដើម ដោយមានបំណងថា ថ្ងៃមុខទារកទាំងនោះនឹងបានជាគូកនទឹងកូនរបស់ខ្លួន ។ កុមារទាំងនេះមានវ័យធំឡើងបានរកស៊ីចាប់ត្រីជាមួយគ្នា ។ ថ្ងៃមួយពួកកុមារទាំងនេះចាប់បានត្រីមួយយ៉ាងធំ មានពណ៌ក្រហមដូចមាស តែមានមាត់ស្អុយ ហើយបាននាំគ្នាយកត្រីនេះ ទៅថ្វាយព្រះបរមសាស្តាទត ។ ព្រះពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ត្រាសថា ត្រីនេះពីជាតិមុនគឺភិក្ខុកបិលៈ ដែលជាអ្នកមានបរិស័ទ បរិវារច្រើនតែខ្ជីខ្ជាក្នុងធម្មវិន័យនៃសាសនាព្រះពុទ្ធទ្រង់ព្រះនាម កស្សបៈ ។

កុមារទាំង ៥០០ នាក់កើតសង្វេគ មានសេចក្តីជ្រះថ្លាក្រាបទូលសូមបព្វជ្ជា ឧបសម្បទា ។ លុះបួសរួចហើយយសោជៈនិងមិត្រទាំង ៥០០ ខំធ្វើសមណធម៌ ចំរើនវិបស្សនាកម្មដ្ឋានដរាបដល់បានសម្រេចព្រះអរហត្ត ។

## ៧៨_ប្រវត្តិព្រះសភិយៈ

ព្រះសភិយៈនេះ មិនមានដឹងថាជាបុត្ររបស់លោកណា ? មានជាតិភូមិនៅទីណាទេ គ្រាន់តែបានដឹងថាលោកជាបរិព្វាជកឈ្មោះសភិយៈ ។ សភិយបរិព្វាជកបានដោះស្រាយប្រស្នាទេវតាដែលត្រូវជាញាតិក្នុងជាតិមុនមិនរួច បានដើរសាកសួរមេគណាចារ្យធំៗ មានគ្រូទាំង ៦ ជាដើម ។ មេគណាចារ្យទាំងនោះឆ្លើយមិនរួចសោះ ។ តមកទើបយកប្រស្នានេះទៅក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគនាក្រុងរាជគ្រឹះ ។ ព្រះដ៏មានបុណ្យទ្រង់ដោះស្រាយគ្រប់ៗខ ។ នៅទីបំផុតព្យាករណ៍សភិយបរិព្វាជកកើតសទ្ធាជ្រះថ្លា បានសុំបព្វជ្ជាឧបសម្បទា (តាមបណ្តាំទេវតាថា បើសមណព្រាហ្មណ៍ណាដោះស្រាយរួច ចូរប្រព្រឹត្តព្រហ្មចរិយធម៌របស់សមណព្រាហ្មណ៍នោះ) ។ ព្រះបរមគ្រូទ្រង់ឱ្យនៅតិរ្ថិយបរិវាសកំណត់ ៤ ខែសិនសឹមបួស ។ លុះបួសរួចហើយខំចំរើនវិបស្សនាកម្មដ្ឋាន ដរាបបានសម្រេចព្រះអរហត្តផល ជាអសេខបុគ្គល ។

## ៧៩_ប្រវត្តិព្រះសេលៈ

ព្រះសេលៈនេះ មានជាតិជាព្រាហ្មណ៍ ឈ្មោះសេលព្រាហ្មណ៍ បានសិក្សាចេះចប់ត្រៃវេទយ៉ាងស្ទាត់ជំនាញ ហើយបានជាគណាចារ្យមួយយ៉ាងធំ បង្រៀនវិជ្ជាត្រៃវេទដល់សិស្សប្រមាណ ៣០០ នាក់ ។ សេលព្រាហ្មណ៍បានពិនិត្យមហាបុរិសលក្ខណៈរបស់ព្រះដ៏មានបុណ្យ ក្នុងវេលាដែលគេហើយជណិយជាបរិស័ទខ្លួនបាននិមន្តព្រះអង្គព្រមទាំងភិក្ខុសង្ឃ ១២៥០ អង្គមកទទួលចង្ហាន់

ក្នុងអាស្រមរបស់ខ្លួន ។ លុះពិនិត្យឃើញលក្ខណៈនេះហើយ កើតសទ្ធាជ្រះថ្លា សូមឧបសម្បទាក្នុងធម្មវិន័យពុទ្ធសាសនា ខំចំរើនវិបស្សនាលុះត្រាបានសម្រេចព្រះអរហត្តផល ។

## ៤០-ប្រវត្តិព្រះមហាបន្ថេរ:

ព្រះថេរៈអង្គនេះ ពុំមានរឿងរ៉ាវអ្វីឱ្យច្បាស់លាស់ទេ ទាំងក្នុងពេលមុនបួស និងបួសរួចហើយ ។ គេគ្រាន់តែបានដឹងថា លោកបានសម្រេចព្រះអរហត្តផល ជាអសេខបុគ្គល ។

( មហាបន្ថេរៈនេះ ប្រហែលជាអតីតព្រះរាជាបន្ថេរៈដែលជាបិតាព្រះបាទឧទេនទេដឹង? )

អនុពុទ្ធប្រវត្តិចប់ដោយសង្ខេបប៉ុណ្ណោះ

*****

ការផ្សាយសៀវភៅ នេះជា eBook បាន បង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ក្សរុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **ម៉ាន ជាន្ទី**

តុលា ឆ្នាំ ២០១៥

គាំទ្រដោយ កូនប្រុស ស្រី

លោក ស៊ី ដារា និងលោកស្រី សុន ដារី ព្រមទាំងលោកស្រី បុប្ផា ដឹឡូប៉ែស

ដើម្បី ឧទិសកុសល ដល់វិញ្ញាណក្ខន្ធ

លោកឪពុក សង្វារ ដឺ ឡូប៉ីស និងលោកម្តាយ ឱន សៅខុន

សូមអរគុណ

ខ្ទៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org

## មានជាវដុំ និង ជាវរាយ

**សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "បណ្ណាគារត្រៃរតន៍"**

#136E0 វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ: **012 706 581**

**097 905 00 55**

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ៗ